ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ប្រតិភូកាកបាទក្រហមកម្ពុជាទស្សនកិច្ច «បណ្ណាល័យសម្ដេចម៉ែ»
- ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកទស្សនកិច្ចមជ្ឈមណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ
- ឯកអគ្គរាជទូតអូស្ដ្រាលីទស្សនកិច្ចអន្លង់វែង
- គម្រោងប្រវត្តិសាស្ដ្រគ្រួសារ នៅខេត្តព្រៃវែង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៥៤ ខែកុម្ភៈ ឆ្នាំ២០២១

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៥៤ ខែកុម្ភៈ ឆ្នាំ២០២១

## មាតិកា

**សំបុត្រ**

◆ តួនាទីគ្រូបង្រៀន សម្រាប់ការផ្សះផ្សា.......១

**ផ្នែកឯកសារ**

◆ អៀត ប៊ុនលី សមាជិកសន្តិសុខឃុំចក ........ ៥

**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**

◆ ចិន បឿនៈ អតីតកងទ័ពដែលបានរៀនជំនាញបើកយន្តហោះចម្បាំងនៅប្រទេសចិន............. ៨

◆ ឯកអគ្គរាជទូតជប៉ុនធ្វើទស្សនកិច្ចនៅ «បណ្ណាល័យសម្ដេចម៉ែ»...................... ១៤

◆ សែ បត អតីតកងទ័ពស្ម័គ្រចិត្តវៀតណាម .. ១៧

◆ ប្រតិភូភាកបាទក្រហមកម្ពុជាទស្សនកិច្ច «បណ្ណាល័យសម្ដេចម៉ែ»...................... ១៩

◆ ខ្មែរក្រហមធ្វើឲ្យខ្ញុំជាប់ឈ្មោះមហាចោរ ....២៤

◆ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកទស្សនកិច្ចមជ្ឈមណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ.... ២៨

◆ ឯកអគ្គរាជទូតអូស្ត្រាលីទស្សនកិច្ចអន្លង់.... ៣៣

**ផ្នែកច្បាប់**

◆ សាលក្រមសំណុំរឿង០០២/០២ ............ ៣៦

**ផ្នែកវេទិកាសាធារណៈ**

◆ «វេទិកាប្រវត្តិសាស្ត្រគ្រួសារ» ក្នុងស្រុកអន្លង់វែង .......................... ៤៦

◆ គម្រោងប្រវត្តិសាស្ត្រគ្រួសារនៅខេត្តព្រៃ .... ៥០

◆ វេទិកាសហគមន៍ភូមិទំនប់លើ.............. ៥៧

**ផ្នែកស្រាវជ្រាវរកគ្រួសារ**

«ដេះដង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

◆ មាស សារិន ៖ លេខាធិការ .................. ៦០



ម៉ៅ មុន្នីរក្សា ភេទប្រុស អាយុ១៩ឆ្នាំ គឺជានិស្សិតឆ្នាំទី១ ផ្នែកគណនេយ្យ នៅសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ បានផ្ដល់បទសម្ភាសន៍ដល់ក្រុមការងារគម្រោងប្រវត្តិសាស្ត្រគ្រួសារ បន្ទាប់ពីបានស្ដាប់ សុន មករា រៀបរាប់ពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម។ (អ៊ុន សុដាវី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧/៥៣.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្មេរលេខនេះ៖** ផេង ពង្សរ៉ាស៊ី, កែវ សុភី, រី លក្ខិណា, ផាត ចាន់សុនិតា, សុខ វណ្ណៈ, សុភ័ក្ត្រ ភាណា, ឡុង ដានី, សួត វិចិត្រ, វេនី ខកហៀល, ប៉ាង ពីរីន្ត និង ហ៊ាន ពិសី

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដារ៉ារដ្ឋ មេត្តា, **អ្នកបកប្រែ៖** អ៊ុន សុដាវី **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** អ៊ុន សុដាវី **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# គួនាទីគ្រូបង្រៀន សម្រាប់ការផ្សះផ្សាគ្រួសារ
## ទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងបង្កើតចំណេះដឹង អំពីប្រវត្តិសាស្ត្រខ្មែរក្រហម

*ផេង ពង្សរ៉ាស៊ី*



ក្រុមការងារនៃការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តព្រៃវែង នៃកម្មវិធីអប់រំស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានជួបនិងសម្ភាសគ្រូបង្រៀននៅតាមផ្ទះរបស់គាត់នៅក្នុងស្រុកមេសាង និងស្រុកឯទៀតក្នុងខេត្តព្រៃវែង ក្រោមគម្រោងស្តីពី «វេទិកាប្រវត្តិសាស្ត្រគ្រួសារ» កាលពីខែមករា ឆ្នាំ២០២១។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្របតាមផែនការយុទ្ធសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ឆ្នាំ២០២១ ក្នុងការអនុវត្តគម្រោងស្តីពីការអប់រំអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងអនុវត្តតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាក្រសួងសុខាភិបាល ទាក់ទងនឹងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ និងការការពារខ្លួនពីការឆ្លងជំងឺនេះ ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តព្រៃវែង នៃកម្មវិធីអប់រំស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានអនុវត្តគម្រោងស្តីពី «វេទិកាប្រវត្តិសាស្ត្រគ្រួសារ» ជាមួយគ្រូបង្រៀននៅក្នុងស្រុកមេសាង និងស្រុកឯទៀតក្នុងខេត្តព្រៃវែងពីខែមករា ឆ្នាំ

២០២១ តទៅ។ គម្រោងនេះត្រូវបានរៀបចំឡើងដើម្បីធានាថា ការផ្សះផ្សាផ្លូវចិត្តក្នុងសង្គមគ្រួសារ ត្រូវបានយកចិត្តទុកដាក់ ហើយការស្វែងយល់និងចងចាំពីប្រវត្តិសាស្ត្រខ្មែរក្រហម ត្រូវបានពង្រីកឥតឈប់ឈរទៅកាន់មនុស្សជំនាន់ក្រោយដែលពុំធ្លាប់ឆ្លងកាត់របបខ្មែរក្រហម។ ការចងចាំពីប្រវត្តិសាស្ត្រនេះ គឺមានសារសំខាន់ខ្លាំងណាស់ សម្រាប់ការអភិវឌ្ឍប្រទេសដោយគ្មានអំពើហិង្សា អំពើប្រល័យពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗ ដែលកើតចេញពីការរំលោភសិទ្ធិពីធម្មជាតិ និងសិទ្ធិជាបុគ្គលរបស់មនុស្ស។

គ្រូបង្រៀនទាំងអស់ គឺជាទិសដៅនៃការចុះជួបនិងសម្ភាស ក្នុងនោះគ្រូបង្រៀនដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម គឺជាអត្ថិភាពនៃការណាត់ជួបសម្រាប់ការអនុវត្តគម្រោងដំបូងរបស់ការិយាល័យ ស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តព្រៃវែង ព្រោះថាលោកគ្រូអ្នកគ្រូមិនត្រឹមតែជាគ្រូបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាសាក្សីរស់នៃរបបកម្ពុជាប្រជាធិបតេយ្យទៀតផង។ មកដល់ពេលនេះ ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តព្រៃវែង បានជួបសម្ភាសជាមួយគ្រូបង្រៀនដែលជាជនរងគ្រោះក្នុងរបបខ្មែរក្រហម ចំនួន១៩នាក់រួចមកហើយ នៅតាមគេហដ្ឋានផ្ទាល់ខ្លួនរបស់គ្រូបង្រៀនម្នាក់ៗ។ រាល់ការណាត់ជួបម្តងៗ ក្រុមការងារតែងតែទទួលបានការសហការយ៉ាងល្អ និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ក្រុមការងារ។

កិច្ចសម្ភាសដែលបានមកពីគ្រូបង្រៀនម្នាក់ៗ គឺជាសាច់រឿងបុគ្គលនិងគ្រួសារដ៏មានតម្លៃបំផុត និងមិនអាចកាត់ថ្លៃបានឡើយ។ ជាការពិតណាស់ ដែលថាមនុស្សម្នាក់មានសាច់រឿងមួយ ហើយមនុស្ស៥លាននាក់ មានសាច់រឿង៥លាន។ នៅពេលដែលសាច់រឿងទាំងអស់ ត្រូវបានសិក្សា និងចងក្រងទុកជាឯកសារប្រវត្តិសាស្ត្រ ប្រទេសកម្ពុជានឹងអាចថែរក្សាប្រវត្តិសាស្ត្រនេះរាប់រយពាន់ឆ្នាំទៅមុខទៀត ហើយសាច់រឿងទាំងអស់ នៅតែជាមេរៀនជីវិតដ៏មានឥទ្ធិពលសម្រាប់មនុស្សជំនាន់ក្រោយៗមកទៀត ក្នុងការរៀនសូត្រពីបទពិសោធន៍របស់មនុស្សជំនាន់មុនដែលពោរពេញដោយទុក្ខលំបាកវេទនា និរាសព្រាត់ប្រាស់ សាហាវឃោរឃៅ អមនុស្សធម៌ និងសម្លាប់រង្គាល។ មេរៀនទាំងនេះ គឺជាប្រទីបបំភ្លឺផ្លូវដល់យុវជនជំនាន់ក្រោយៗ ឲ្យចេះគិតគូរពីអនាគតខ្លួន គ្រួសារ សហគមន៍និងប្រទេសជាតិ និងពិចារណាពីយុទ្ធសាស្ត្រដឹកនាំដែលអាចនាំយកប្រទេសកម្ពុជាចៀសផុតពីអំពើហិង្សា ទារុណកម្មឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

ពេលវេលាដ៏មានតម្លៃរបស់គ្រូបង្រៀនជាមួយក្រុមការងារ គឺជាពេលវេលាដ៏វិសេសវិសាលបំផុតនៃការបង្រៀនកូនចៅរបស់ខ្លួនឲ្យស្វែងយល់កាន់តែស៊ីជម្រៅថែមទៀត ពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគ្រប់គ្រងដោយ ប៉ុល ពត ពីចន្លោះឆ្នាំ១៩៧៥ដល់១៩៧៩។ ក្រុមការងាររបស់ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តព្រៃវែង បានបង្កើតឱកាសនេះ



និងលើកកម្ពស់ឲ្យមានការពិភាក្សា ឬការសន្ទនាអន្តរជំនាន់រវាងគ្រូបង្រៀន និងក្រុមគ្រួសារផ្ទាល់ នៅក្រោមដំបូលផ្ទះតែមួយៗ ឱកាសនេះ សបញ្ជាក់ឲ្យឃើញថា លោកគ្រូអ្នកគ្រូមិនត្រឹមតែជាគ្រូបង្រៀនតាមសាលារៀន និងជាឪពុកម្តាយ ឬជីដូនជីតារបស់កូនៗ និងចៅៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាគ្រូបង្រៀនក្រៅប្រព័ន្ធ ក្រៅម៉ោង និងគ្មានប្រាក់ឧបត្ថម្ភសម្រាប់សមាជិកគ្រួសារ និងអ្នកជិតខាងខ្លួនៗ កិច្ចការងារដែលមិនអាចកាត់ថ្លៃបានរបស់លោកគ្រូអ្នកគ្រូ គឺជាកិច្ចការស្ម័គ្រចិត្តដ៏សប្បុរសដែលបង្ហាញឲ្យឃើញពីការប្រើប្រាស់ពេលវេលាដ៏មានតម្លៃ ដើម្បីកសាងប្រវត្តិសាស្ត្រមួយសម្រាប់ក្មេងៗជំនាន់ក្រោយ ជាពិសេសកូន ចៅ និងក្មេងៗដែលជាអ្នកជិតខាង ដែលកំពុងរស់នៅក្នុងភូមិជងរបងជាមួយគ្នានាពេលបច្ចុប្បន្នៗ









ក្រុមការងារនៃការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តព្រៃវែង នៃកម្មវិធីអប់រំស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានជួប និងសម្ភាសគ្រូបង្រៀននៅតាមផ្ទះរបស់គាត់នៅក្នុងស្រុកមេសាង និងស្រុកឯទៀតក្នុងខេត្តព្រៃវែង ក្រោមគម្រោងស្តីពី «វេទិកាប្រវត្តិសាស្ត្រគ្រួសារ» កាលពីខែមករា ឆ្នាំ២០២១ៗ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



អ្នកគ្រូ ប៉ែន សុគុណ គឺជានាយិកានៃវិទ្យាល័យអង្គរស ក្នុងស្រុកមេសាង ខេត្តព្រៃវែង។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តព្រៃវែង បានចាត់ទុកកិច្ចការនេះថា មិនត្រឹមតែជាសកម្មភាពនៃការផ្សារភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្រូបង្រៀន ដែលជាអតីតជនរងគ្រោះនៃរបបខ្មែរក្រហម និងការរំឭកឡើងវិញពីប្រវត្តិបុគ្គលនិងប្រវត្តិសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការសំណេះសំណាលជាលក្ខណៈគ្រួសារ និងសហគមន៍ តាមរបៀបនៃការប្រកាន់ខ្ជាប់នូវប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ និងសាសនា ដែលរួមបញ្ចូលទាំងការសួរសុខទុក្ខ ការពិភាក្សាពីបញ្ហាសុខភាពបុគ្គល និងការផ្តល់វិធានការ ឬវិធីសាស្ត្របន្ថែមសម្រាប់ការការពារខ្លួនពីការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលកំពុងរាតត្បាតនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។

ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តព្រៃវែង សូមសម្តែងនូវការដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកគ្រូអ្នកគ្រូទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួមក្នុងការពិភាក្សា និងផ្តល់បទសម្ភាសទាក់ទងនឹងដំណើរជីវិតឆ្លងកាត់របបខ្មែរក្រហម ក្នុងគម្រោងស្តីពី «វេទិកាប្រវត្តិសាស្ត្រគ្រួសារ»។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លោកគ្រូអ្នកគ្រូជាច្រើននាក់ទៀត ដែលពុំទាន់ទទួលបានការណាត់ជួប ឬចូលរួមនៅក្នុងគម្រោងនេះ នឹងផ្តល់ការសហការយ៉ាងរឹងមាំនិងកក់ក្តៅដល់ក្រុមការងារនៃការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តព្រៃវែង ក្នុងពេលដ៏ខ្លីខាងមុខ។

ស្ថិតក្នុងទស្សនវិស័យដ៏វែងឆ្ងាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជនរងគ្រោះនៃរបបខ្មែរក្រហមទាំងអស់នឹងត្រូវបានថែទាំសុខភាព។ ក្នុងន័យនេះ ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមខេត្តព្រៃវែង បានត្រៀមខ្លួនរួចជាស្រេចក្នុងការភ្ជាប់ទំនាក់ទំនងជាមួយលោកគ្រូអ្នកគ្រូទាំងអស់ ទៅនឹងដំណើរការនៃការត្រួតពិនិត្យសុខភាព និងពិគ្រោះពីបញ្ហាសុខភាព ដើម្បីធានាបានថា លោកគ្រូអ្នកគ្រូមានសុខភាពកាន់តែល្អប្រសើរឡើង និងអាចមានពេលវេលាដ៏យូរអង្វែងតទៅទៀត ក្នុងការសាបព្រួសចំណេះដឹង និងបទពិសោធន៍ដល់ក្មេងៗជំនាន់ក្រោយ។

# អៀត ប៊ុនលី

## សមាជិកសន្តិសុខឃុំចក ស្រុកអូររាំងឪ

*វ៉េង សុភី*



កងទ័ពបដិវត្តន៍ខ្មែរក្រហមនៅសមរភូមិ ក្នុងភូមិភាគបូព៌ា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អៀតប៊ុនលី ភេទប្រុស មានអាយុ២៨ឆ្នាំ នៅក្នុងឆ្នាំ១៩៧៧។ ខ្ញុំមានស្រុកកំណើតនៅភូមិចក ឃុំចក ស្រុកអូររាំងឪ ខេត្តកំពង់ចាម បច្ចុប្បន្ន ខេត្តត្បូងឃ្មុំ។ ខ្ញុំមានបងប្អូនបង្កើតចំនួនប្រាំបីនាក់ គឺប្រុសចំនួនប្រាំពីរនាក់ និងស្រីចំនួនពីរនាក់។ បងប្អូនរបស់ខ្ញុំមានគ្រួសារចំនួនពីរនាក់ និងនៅលីវចំនួនប្រាំពីរនាក់។ នៅក្នុងចំណោមបងប្អូនទាំងអស់ មានបងប្អូនចំនួនបីនាក់បានចូលធ្វើបដិវត្តន៍។ បងប្រុសម្នាក់ចូលធ្វើជាទាហានឈ្មោះ ថន បច្ចុប្បន្នធ្វើជាកម្មករនៅចម្ការកៅស៊ូក្រែប នៅស្រុកមេមត់។

ខ្ញុំមានឪពុកឈ្មោះ ធួ អាយុ៥៥ឆ្នាំ និងម្តាយឈ្មោះ សៀត អាយុ៥០ឆ្នាំ។ ឪពុកម្តាយរបស់ខ្ញុំធ្វើស្រែ។ ខ្ញុំបានចូលធ្វើបដិវត្តន៍នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៧១ តាមរយៈឈ្មោះ យ៉ាន គឺជាអ្នកនាំចូល។ យ៉ាន មាននាទីគឺជាប្រធានឃុំចក ស្រុកអូររាំងឪ ។ មុនដំបូងខ្ញុំបានទទួលការអប់រំពីឈ្មោះយ៉ាន។ យ៉ាន បានអប់រំខ្ញុំអំពីការធ្វើបដិវត្តន៍មានការលំបាកស្មុគស្មាញ សម្រាប់ប្រជាជន និងកងទ័ព។ នៅក្នុងតំបន់រំដោះ ការរស់នៅមានការខ្វះខាត ស្លៀកពាក់ ការស៊ីចុក មិនគ្រប់គ្រាន់ និង

គ្មានសិទ្ធិសេរីភាពឡើយ។ ដូច្នេះការសប្បាយរីករាយរបស់យើងក៏មិនមានដែរ។ ចំណែកឯសម្ភារសិក និងស្បៀងអាហារសម្រាប់ធ្វើសង្គ្រាមជាមួយសត្រូវមានតិចតួច មិនអាចវាយយកឈ្នះសត្រូវបានទេ។ ប្រសិនបើពិនិត្យមើលប្រជាជន និងកងទ័ពនៅទីក្រុងភ្នំពេញវិញ គឺរស់នៅសប្បាយចិត្ត និងហូបចុកគ្រប់គ្រាន់។ កងទ័ពមានបុណ្យស័ក្តិ មានប្រាក់ខែ មិនតែប៉ុណ្ណោះសម្ភារធ្វើសង្គ្រាមទំនើបៗគ្រប់គ្រាន់។ ក្រោយពីខ្ញុំបានស្តាប់ការអប់រំរបស់ យ៉ាន មកខ្ញុំក៏យល់ស្របតាមយោបល់នេះទាំងស្រុង។ ខ្ញុំបានធ្វើការសម្រេចចិត្តធ្វើសកម្មភាពប្រឆាំងជាដាច់ខាតជាមួយបដិវត្តន៍។ បន្ទាប់មកខ្ញុំ បានឡើងធ្វើជាឈ្លបនៅឃុំចកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ យ៉ាន ។

តមកទៀតខ្ញុំត្រូវបានចាត់តាំងឲ្យនៅក្នុងកងវរសេនាតូចលេខ ២២៥ ប្រចាំតំបន់២២។ នៅក្នុងកងវរសេនាតូចលេខ២២៥របស់ខ្ញុំគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ ស្រ៊ិន ដែលមានតួនាទីជានយោបាយកងវរសេនាតូចលេខ ២២៥។ កងវរសេនាតូចលេខ ២២៥ នេះ បច្ចុប្បន្នអង្គការបញ្ចូលទៅក្នុងកងវរសេនាធំលេខ ១៥២ ដែលមានអ្នកទទួលខុសត្រូវឈ្មោះ ស្រ៊ិន ដដែល។

នៅខែកក្កដា ឆ្នាំ១៩៧២ យ៉ាន បានខទ្មេសនាម និងបញ្ចូលខ្ញុំជាសមាជិកខ្មែរស នៅមន្ទីរឃុំចក។ យប់នោះមានអ្នកចូលរួមមួយចំនួន គឺឈ្មោះ ផុន នាទីជាអនុប្រធានសន្តិសុខឃុំចក ស្រុកអូររាំងឪ, ឈ្មោះ ថុន នាទីជាសមាជិកឈ្លបឃុំចក ស្រុកអូររាំងឪ និង ខ្ញុំ ព្រមទាំងអ្នកចូលរួមប្រជុំមានឈ្មោះ ខែម ម៉ា នាទីជាអនុប្រធានឃុំចកស្រុកអូររាំងឪ, ឈ្មោះជ័យ នាទីជាប្រធានឈ្លបឃុំចក ស្រុកអូររាំងឪ, ឈ្មោះ ជា នាទីជាអនុប្រធានឃុំចក ស្រុកអូររាំងឪ។ ផែនការ និងខ្លឹមសារដែលខ្ញុំបានចូលជាខ្មែរស គឺនៅពេលយាមត្រូវចាប់ប្រជាជនមិនឲ្យដើររកស៊ី, ធ្វើយ៉ាងណាឲ្យប្រជាជនមានទំនាស់ជាមួយអង្គការ, ត្រូវបំផុសប្រជាជនឲ្យមានទំនាស់ជាមួយប្រធានភូមិពីរឿងធ្វើសំបុត្រ, ត្រូវបំផ្លាញសម្ភារនៅក្នុងមន្ទីរ, ដើរ កៀងគររកម្លាំងសេរីឲ្យបានច្រើនដើម្បីងាយស្រួល នឹងបញ្ចូលជាខ្មែរស។

ក្រោយពីខ្ញុំបានចូលជាខ្មែរស ខ្ញុំបានចូលរួមសកម្មភាពប្រជុំចំនួនបីលើកគឺ៖ ទី១).នៅខែសីហា ឆ្នាំ១៩៧២។ ខ្ញុំបានប្រជុំនៅក្នុងភូមិចម្ងាក់ ស្រុកអូររាំងឪ ។ យ៉ាន បានចូលរួមប្រជុំចាប់ពីម៉ោងប្រាំបីដល់ម៉ោង ១១:០០យប់ ដែលមានសមាជិកចូលរួមឈ្មោះ ផុន នាទីអនុប្រធានសន្តិសុខឃុំចក, ថុន នាទី សមាជិកឈ្លបឃុំចក និងខ្ញុំ។ លើកទី២). នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧២ ដែលការប្រជុំនៅវាលស្រែក្នុងភូមិវាលកើត ឃុំចក ដែលមានឈ្មោះ ខែមម៉ា មាននាទីជាប្រធានឃុំចក។ ការប្រជុំលើកទី៣) នៅក្នុងខែមករា ឆ្នាំ១៩៧៣ ប្រជុំនៅវាលស្រែស្តែ ឃុំកោះញែក ស្រុកអូររាំងឪ។ ប្រជុំលើកទីបីនេះមានប្រធានដឹកនាំប្រជុំឈ្មោះ ជ័យ មាននាទី ជាប្រធានឈ្លបឃុំចក។ ខ្លឹមសារសំខាន់នៅក្នុងការប្រជុំទាំងបីលើកគឺ៖ ត្រូវបំផុសយុទ្ធជនឲ្យមានទំនាស់ជាមួយអង្គការពីរឿងធ្វើការងារ, ត្រូវដើរបំផុសយុទ្ធជនឲ្យខ្លាចសមរភូមិ, បំផុសយុទ្ធជនឲ្យមានជំទាស់ជាមួយបក្ខជនអំពីរឿងចូលក្រុមសហករណ៍, ជំទាស់ជាមួយមេភូមិពីបញ្ហាដើរទៅណាមកណាមិនបាន, ត្រូវដើរកម្ទេកម្លាំងបដិវត្តន៍, ពេលចូលធ្វើទ័ពបំផុសទ័ពឲ្យខ្លាចសមរភូមិ, ប្រើសញ្ញាសម្គាល់ខ្មែរ ស គឺមូរដៃអាវខាងឆ្វេងផ្លត់ ឯដៃខាងស្តាំមិន បាច់មូរទេ។

ខ្ញុំបានធ្វើសកម្មភាពជាច្រើននៅក្នុងតួនាទីជាឈ្លបឃុំចក ដូចជា បំផុសយុវជនភូមិមិនឲ្យទៅមុខ, មិនឲ្យជឿជាក់លើអង្គការ, ចាប់ប្រជាជន ១០នាក់ ចងដោយគ្មានមូលហេតុ, បំផុសប្រជាជនធ្វើបាតុកម្មប្រឆាំងនឹងបក្សពីរឿងប្រមូលកម្លាំងចូលក្រុមសហករណ៍, ខ្ញុំបានបំផុសកសាង អប់រំកម្លាំងបានចំនួន ៥នាក់ បន្ថែមទៀត ដោយ ២នាក់រួមមានឈ្មោះ បេង នាទីជាយុទ្ធជនឈ្លបឃុំចក ស្រុកអូររាំងឪ, ឈ្មោះហឿន នាទីជាប្រធានពួកឃុំចក បច្ចុប្បន្នស្លាប់ បញ្ចូលជាខ្មែរសេរីនៅខែកញ្ញា ឆ្នាំ១៩៧២ នៅភូមិស្រែស្តែ ឃុំកោះញែក និង៣នាក់ទៀតបានអប់រំតែមិនទាន់បញ្ចូលជាខ្មែរស មានឈ្មោះ យ៉ែន នាទីជាយុទ្ធជនឈ្លបឃុំចក ស្រុកអូររាំងឪ, ឈ្មោះខឿន នាទីជាប្រធានពួកឈ្លបឃុំចក ស្រុកអូររាំងឪ, ឈ្មោះអុន នាទីជាយុទ្ធជនឈ្លបឃុំចក ស្រុកអូររាំងឪ។

ក្រោយមកខ្ញុំក៏ត្រូវបានខ្មែរក្រហមជ្រើសរើសឱ្យចូលជាសមាជិក សេ.អ៊ី.អា នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ដោយមានអ្នកចូលរួមចំនួនបីនាក់ៗ យើងចូល សេ.អ៊ី.អា នៅភូមិកៀនឃ្លាំង ឬបន្ទាយថ្មីខាងកើតស្ពានជ្រោយចង្វារ។ អ្នកចូលរួមមានឈ្មោះ យឿន នាទីនីរសារកងធំ១៩០ វរសេនាតូចលេខ២២៥ វរសេនាធំលេខ១៥២, ឈ្មោះ សារ៉េត នាទីជាយុទ្ធជនពេទ្យ វរសេនាតូចលេខ ២២៥ និងខ្ញុំ។ នៅពេលចូល សេ.អ៊ី.អា នេះ ឈ្មោះស្រ៊ន បានប្រាប់ថា នៅក្នុងកងវរសេនាតូចលេខ២២៥ នេះ មាន សេ.អ៊ី.អា ចូលមុន ស្រ៊ន ចំនួន៥នាក់ហើយ គឺមានឈ្មោះលីម នាទីជាយោធាកងតូចទី៣ កងធំទី១៩០ វរសេនាតូចលេខ២២៥ បច្ចុប្បន្ននៅកងដដែលនៅធ្វើស្រែខាងកើតស្ពានជ្រោយចង្វារ, ឈ្មោះ ផល់ នាទីជាយុទ្ធជនពិការ នៅក្នុងមន្ទីរវរសេនាធំលេខ១៥២ បច្ចុប្បន្ននៅដេកពេទ្យ នៅក្នុងមន្ទីរពេទ្យ ព-៩៨, ឈ្មោះ រឿន នាទីជាយុទ្ធជន នៅរោងជាងធ្វើសម្ភារកសិកម្មប្រចាំមន្ទីរ វរសេនាធំលេខ១៥២, ឈ្មោះធី នាទីជានយោបាយកងតូចស៊ើបការណ៍ប្រចាំកងវរសេនាតូចលេខ២២៥ វរសេនាធំលេខ១៥២, ឈ្មោះអឿន នាទីជាប្រធានក្រុមខាងរោងជាងធ្វើកាណូតប្រចាំវរសេនាធំលេខ១៥២។ ពេលនោះ ខ្ញុំមិនបានធ្វើសកម្មភាពជាមួយគ្នាទេ។ ពេលចូលជា សេ.អ៊ី.អា ខ្ញុំបានធ្វើសកម្មភាពជាច្រើន ដូចជា បំផុសយុទ្ធជននៅក្នុងអង្គភាពឲ្យទំនាស់ជាមួយអង្គការពីរឿងធ្វើការងារគ្មានពេលសម្រាក, បំផុសបុរសនិងនារីឲ្យទំនាស់ជាមួយបក្សពីរឿងមិនរៀបការឲ្យ, បំផ្លាញសម្ភារ, ត្រូវកៀងគរក្រុមសេរីឲ្យបានច្រើន ដើម្បីងាយស្រួលបញ្ចូលជា សេ.អ៊ី.អា។

ខ្ញុំបានបំផុស និងអប់រំកសាងកម្លាំងបានចំនួនប្រាំនាក់ និងមិនទាន់ចូលជា សេ.អ៊ី.អា ចំនួនបីនាក់មានឈ្មោះ អុន នាទីជាយុទ្ធជនកងតូចទី៣ កងធំ១៩០ វរសេនាតូចលេខ២២៥ វរសេនាធំលេខ ១៥២, ឈ្មោះ ជឿន នាទីជាយុទ្ធជនកងតូចទី៣ កងធំ ១៩០ វរសេនាតូចលេខ ២២៥ វរសេនាធំលេខ ១៥២, ឈ្មោះ ផន នាទីជាប្រធានពួកកងតូចទី០២ កងធំ១៩០ វរសេនាតូចលេខ២២៥ វរសេនាធំលេខ១៥២ និង២នាក់ទៀត មានឈ្មោះ ហេង នាទីប្រធានពួក កងតូចទី៣ កងធំ១៩០ វរសេនាតូចលេខ២២៥ វរសេនាធំលេខ១៥២, ឈ្មោះនី នាទីជាយុទ្ធជនកងតូចទី៣ កងធំ១៩០ វរសេនាតូចលេខ២២៥ វរសេនាធំលេខ ១៥២ ហើយបានបញ្ចូលជា សេ.អ៊ី.អា នៅខែកញ្ញា ១៩៧៦ នៅភូមិកៀនឃ្លាំង ខាងកើតស្ពានជ្រោយចង្វារ ដោយក្នុងពេលនោះមានឈ្មោះ ស្រ៊ន បានចូលរួមក្នុងកម្មវិធីនេះដែរ។ កំណត់ហេតុចម្លើយសារភាពនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៧៧។

កំណត់ចំណាំ ៖ អត្ថបទនេះ ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ J00452។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ អៀត ប៊ុនលី ពិតប្រាកដណានោះទេ។

**ពាក្យស្លោក ផ្នែកជីវភាពប្រជាជន៖**

**កម្មាភិបាលល្អ និងគណៈកម្មាធិការល្អ គឺស្មោះស្ម័គ្រដោះស្រាយ និងលើកស្ទួយជីវភាព មហាជនបានល្អ គ្រប់ផ្នែកនិងគ្រប់ពេលវេលា ដោយគោលជំហរទទួលខុសត្រូវ និងថ្លៃប្រឌិតគំនិតផ្តើមខ្ពស់។**

◇◇◇◇◇◇◇◇◇◇◇◇◇◇◇◇

**ពាក្យស្លោក ផ្នែកការពារប្រទេស៖**

**អ្វីៗដែលប៉ះពាល់ដល់ជាតិ ប្រជាជនបដិវត្តន៍ និងបក្ស មិនត្រូវគិតគូរធ្វើឱ្យសោះ!**

# ចិន បឿនៈ អតីតកងទ័ពដែលបានរៀនជំនាញបើកយន្តហោះចម្បាំងនៅប្រទេសចិន

*រី លក្ខិណា*



ចិន បឿន អាយុ៦៥ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិស៊ឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ១ - ជីវិតពីកុមារភាព

ខ្ញុំឈ្មោះ ចិន បឿន អាយុ៦៥ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិស៊ឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ប្រពន្ធរបស់ខ្ញុំឈ្មោះ មែន សាវ៉ន អាយុ ៤៧ឆ្នាំ។ ខ្ញុំមានកូនចំនួនបួននាក់ ស្រីចំនួនមួយនាក់ និងប្រុសចំនួនបីនាក់។ ខ្ញុំមានស្រុកកំណើតនៅភូមិគោកចាន់ ឃុំល្វាក្រាំង ស្រុកវ៉ារិន ខេត្តសៀមរាប។ ឪពុករបស់ខ្ញុំឈ្មោះ ម៉ម ចិន និងម្តាយឈ្មោះ ពែក ព្រឹន។ ខ្ញុំមានបងប្អូនប្រាំពីរនាក់ ស្រីចំនួនបីនាក់ និងប្រុសចំនួន ៤នាក់។ ក្នុងចំណោមបងប្អូនប្រាំពីរនាក់ ខ្ញុំជាកូនពៅ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៨ «ចាស់» នៅសាលាបឋមសិក្សាគោកចាន់។ ខ្ញុំឈប់រៀនព្រោះតែប្រទេសកើតមានសង្គ្រាម រដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០។ បន្ទាប់ពីឈប់រៀន ខ្ញុំបានជួយឪពុកម្តាយធ្វើការងារស្រែចម្ការ។

## ២ - ខ្មែរក្រហមបានចូលមកដល់ភូមិជាលើកដំបូង និងចូលបដិវត្តន៍

នៅពេលមានសង្គ្រាមស៊ីវិលបានកើតឡើងនៅឆ្នាំ ១៩៧០ ក្រុមចលនារណសិរ្សរំដោះជាតិបានចូលមកដល់ភូមិរបស់ខ្ញុំ។ តាមការឃោសនានោះបានឲ្យដឹងថា មេដឹកនាំចលនារណសិរ្សរំដោះជាតិ រួមមាន សម្តេចព្រះ នរោត្តម សីហនុ, លោកខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់។ នៅខណៈពេលនោះ ខ្ញុំបានឃើញទាហាន លន់ នល់ ចូលមកក្នុងភូមិរបស់ខ្ញុំដែរ។ ខ្ញុំ និងយុវជនផ្សេងទៀតបានចូលក្នុងចលនារណសិរ្សរំដោះជាតិ នៅឆ្នាំ១៩៧១ តាមរយៈលោកគ្រូរបស់ខ្ញុំឈ្មោះ សាមឿន។ លោកគ្រូ សាមឿន មានស្រុកកំណើតនៅកំពង់ធំ និងបានមកបង្រៀនសិស្សនៅក្នុងភូមិរបស់ខ្ញុំ។ លោកគ្រូ សាមឿន បានរៀបការប្រពន្ធដែលជាអ្នកភូមិរបស់ខ្ញុំ ក្រោយមក លោកគ្រូ សាមឿនបានក្លាយជាប្រធានឃុំល្វាក្រាំង នៃ

ចលនារណសិរ្សរំដោះជាតិ។ លោកគ្រូ សាមឿន បានការចាត់តាំងខ្ញុំ និងយុវជនផ្សេងទៀតឲ្យកាន់កាំភ្លើងយាមក្នុងភូមិនៅពេលយប់។ ខ្ញុំនៅចងចាំថា មានចម្រៀងមួយបទដែលបំផុសចិត្តគំនិតខ្ញុំ ក៏ដូចជាយុវជនផ្សេងទៀតក្នុងភូមិឲ្យចូលបម្រើបដិវត្តន៍។ ចម្រៀងនោះមានន័យថា «ពុកម៉ែអើយ! ពុកម៉ែខំធ្វើការគ្មានល្ហែរ ទាំងយប់ទាំងថ្ងៃ ដៃម្ខាងបង្កបង្កើនផល ដៃម្ខាងជួយទៅខាងមុខ»។

ជាទូទៅនៅពេលព្រលប់ៗ កម្មាភិបាលខ្មែរក្រហមតែងតែដឹកនាំ យុវជន និងយុវនារីនៅក្នុងភូមិឲ្យហ្វឹកហាត់សម្តែងសិល្បៈជាក្រុមតូចៗ សម្រាប់សម្តែងពេលមានមីទ្ទីញម្តងៗ។ មុនពេលបើកមីទ្ទីញ ក្រុមសិល្បៈដែលមានរូបខ្ញុំដែរនោះបានសម្តែងរឿងអប់រំខ្លីៗ។ បន្ទាប់មកមេដឹកនាំខ្មែរក្រហមនៅថ្នាក់ឃុំ ថ្នាក់ស្រុកបានឡើងចាប់អារម្មណ៍ ដោយបាននិយាយថា «**ជម្រាបសួរលោកឪពុក អ្នកម្តាយជាទីស្នេហាជាទីគោរព។ ស្រុកយើងកើតមានសង្គ្រាមគឺ លន់ នល់ បានធ្លាក់សម្តេចព្រះ នរោត្តម សីហនុ តើពុកម៉ែស្រឡាញ់សម្តេច សីហនុទេ?**» ប្រជាជនដែលបានមកចូលរួមប្រជុំ បានឆ្លើយទាំងអស់គ្នាថា «ស្រឡាញ់»។ ទាំងគេ ទាំងខ្ញុំ ស្រឡាញ់សម្តេច សីហនុ ខ្លាំងណាស់។ ចាប់ពីឆ្នាំ១៩៧១ ខ្ញុំបានឃើញវត្តមានកងទ័ពវៀតកុង (កងទ័ពវៀតណាមខាងជើង) ចូលមកក្នុងភូមិរបស់ខ្ញុំ ហើយការប្រយុទ្ធគ្នាបានចាប់ផ្តើមឡើងតាំងពីពេលនោះមក។ បន្ទាយរបស់ទាហាន លន់ នល់ មានទីតាំងស្ថិតនៅភូមិតាដេវ ក្នុងស្រុកអន្លង់វែង ដែលមានចម្ងាយប្រមាណ ២០ គីឡូម៉ែត្រពីភូមិរបស់ខ្ញុំ។ ខ្ញុំ និងអ្នកភូមិផ្សេងទៀតធ្លាប់បានបររទេះគោទៅរកត្រីនៅតាមបឹងបួរដែលមានទីតាំងនៅក្បែរៗនឹងភូមិតាដេវ និងស្រុកអន្លង់វែង ហើយបានឃើញបន្ទាយទាហាន លន់ នល់។

## ៣ - ការចូលធ្វើកងទ័ពខ្មែរក្រហម

នៅឆ្នាំ១៩៧២ ខ្មែរក្រហមបានរៀបចំបង្កើតកងទ័ពក្នុងភូមិរបស់ខ្ញុំ ដោយខ្មែរក្រហមបានចាត់តាំងឲ្យយុវជនបី-បួននាក់ស្លៀកពាក់ខោអាវខ្មៅ និងមានកាំភ្លើងកាវ៉ាប៊ីនមួយដើមគ្រាប់បែកពីបីគ្រាប់ដើរបំផុសប្រជាជនឲ្យប្រឆាំងនឹងយួនឈ្លានពានទឹកដីយើង។ម្យ៉ាងទៀត ខ្មែរក្រហមក៏បានឃោសនានយោបាយតាមរយៈការសម្តែងសិល្បៈ ដូចជា ឲ្យឪពុកម្តាយបញ្ជូនកូនចៅទៅសមរភូមិមុខ។ នៅក្នុងឆ្នាំ១៩៧២នេះដែរ ខ្មែរក្រហមបានផ្លាស់ខ្ញុំឲ្យមកស្រុកវ៉ារិន ធ្វើជាគ្រូបង្រៀននៅភូមិឫស្សីស្វាយស។ កាលនោះគណៈស្រុកវ៉ារិន មានឈ្មោះ សួន។ ខ្ញុំបង្រៀនកូនសិស្សបានរយៈពេលប្រាំទៅប្រាំមួយខែ ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនត្រឡប់ទៅឃុំល្វាក្រាំងវិញ។

នៅចុងឆ្នាំ១៩៧២ ខ្ញុំ និងយុវជនមកពីតាមភូមិស្រុកផ្សេងៗបានបញ្ជូនចូលក្នុងកងទ័ពមជ្ឈិម។ កាលនោះកងទ័ពមជ្ឈិមមានចំនួនប្រមាណ៦០០ទៅ៧០០នាក់។ គណៈបញ្ជាការកងទ័ពមជ្ឈិម គឺជាជនជាតិដើមភាគតិចមកពីភូមិភាគឦសានមានឈ្មោះ តាធិន, តាឡី និង តាតឿង។ នៅពេលនោះ កងទ័ពមជ្ឈិមគឺជាកងវរសេនាតូចឯករាជ្យបោះទីតាំងនៅសៀមរាប-អង្គរ។ ចំណែកខ្ញុំត្រូវបានបញ្ចូលក្នុងកងពិសេស ដែលមានសមាជិកសរុបប្រមាណ ២០ នាក់ ។ កងពិសេសរបស់ខ្ញុំបានទទួលការបង្ហាត់បង្រៀនផ្ទាល់ពីគណបញ្ជាការកងវរសេនាតូចផ្ទាល់តែម្តង។ មេបញ្ជាការកងវរសេនាតូចទាំងនោះបានរៀបរាប់ប្រវត្តិដែលកងទ័ពខ្មែរក្រហមធ្លាប់បានប្រយុទ្ធជាមួយទាហាន លន់ នល់ នៅសមរភូមិចេនឡាទី១ និងចេនឡាទី២ តាមបណ្តោយផ្លូវជាតិលេខ៦ ចាប់ពីស្គន់ក្នុងខេត្តកំពង់ចាម មកដល់ស្រុកសន្ទុកក្នុងខេត្តកំពង់ធំ។ ខ្ញុំបានហាត់រៀនយុទ្ធសាស្ត្រកងទ័ពបានរយៈពេលបួនទៅប្រាំខែ នៅបរិវេណអង្គរតូច និងអង្គរធំ។ នៅអំឡុងពេលហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រកងទ័ព គឺ ទី១) ត្រូវមានសម្ភារនៅជាប់នឹងខ្លួនរួមមាន គ្រាប់កាំភ្លើង, ឆ្នាំងបាយ, ចប, កាំបិតបុព្វថៅ និងអង្រឹង។ ពេលឮសូរជួងម៉ឺងៗត្រូវយកសម្ភារនៅជាប់នឹងខ្លួនទៅជាមួយ។ ទី២) ហាត់ក្បួនរាវមីនខុទាហរណ៍ថា មីនកប់ក្នុងដី, មីនខ្សែ ឬមីនខ្យល់។ ទី៣) រៀនដើរក្នុងទឹកនៅពេលយប់កុំឲ្យឮសំឡេង។ ទី៤) ហាត់វាយតាមបន្ទាយ លូនក្រាប រើសដុំថ្មគប់ និងវិធីវាយសម្រុកចូលក្នុងបន្ទាយ។ ទី៥) រៀនអំពីវិធីបន្លំខ្លួន ដូចជា

បន្ទំជាមួយនឹងស្មៅ ដើមឈើ។ ពេលដែលខ្មាំងមកជិត ត្រូវក្រោកឡើងបាញ់តែម្តង។ ចុងក្រោយគឺរៀនអំពីវិធីគប់គ្រាប់បែក ខណៈពេលកំពុងវាយជាទ្រង់ទ្រាយផ្កាវីក។

បន្ទាប់ពីហ្វឹកហាត់ចប់ តាធិន ដែលជាមេបញ្ជាការធំបានចាត់តាំងខ្ញុំឲ្យទៅរៀនវិជ្ជាពេទ្យ ដើម្បីឡើងទៅសមរភូមិប្រចាំជាមួយកងទ័ព។ ខ្ញុំធ្លាប់ប្រចាំការនៅខ្សែត្រៀមម្តុំបារាយណ៍ទឹកថ្លារយៈពេល៦ខែ ប៉ុន្តែមិនធ្លាប់បានប្រយុទ្ធគ្នាទេ។ បន្ទាប់មកខ្ញុំត្រូវបានដកឲ្យមកនៅខ្សែត្រៀមភ្នំក្រោមម្តង។ សមរភូមិនៅភ្នំក្រោម គឺប្រើប្រាស់កាំភ្លើងសុទ្ធតែថ្មីៗទើបនឹងបើកចេញពីឃ្លាំងមានដូចជា កាំភ្លើងអាកា, កាំភ្លើងសេកាសេ និងរ៉ែប៉ាំងដេផលិតនៅប្រទេសចិន។ នៅពេលនោះយើងបានបែរមកវាយជាមួយវៀតកុង (វៀតណាមខាងជើង) ប៉ុន្តែខ្ញុំមិនដែលបានចូលរួមប្រយុទ្ធផ្ទាល់ឡើយ។ នៅឆ្នាំ១៩៧៣ មានការប្រកាសឲ្យកងទ័ពវៀតកុងដកចេញពីប្រទេសកម្ពុជា ពីព្រោះលែងមានការទម្លាក់គ្រាប់បែកបេ-៥២ របស់សហរដ្ឋអាមេរិកទៀតហើយ។ ចំណែកអង្គភាពរបស់ខ្ញុំ ក៏ត្រូវបានដកចេញពីសៀមរាប-អង្គរ មកបោះទីតាំងនៅខាងលិចភ្នំពេញដែរ។ កងទ័ពរបស់ខ្ញុំចាប់ផ្តើមដំណើរពីសៀមរាបអង្គរ មកតាមខេត្តព្រះវិហារ និងខេត្តកំពង់ធំ បន្ទាប់មកឆ្លងទន្លេសាបហើយបន្តតាមព្រៃគ្រីខេត្តកំពង់ឆ្នាំងរហូតមកដល់សាលាលេខ៥។ អង្គភាពរបស់ខ្ញុំបានមកបោះទីតាំងនៅភូមិទួលសុភី ស្ថិតនៅក្បែរខេត្តផ្កុ។ ពេលធ្វើដំណើរតាមផ្លូវ ខ្ញុំបានសាកសួរប្រជាជនអំពីទាហាន លន់ នល់ ជាហូហែរ បើសិនជាមានទាហាន លន់ នល់ នៅខាងមុខ ខ្ញុំត្រូវដើរចូលក្នុងព្រៃ បើមិនមានទាហាន លន់ នល់ ទេ ខ្ញុំដើរតាមថ្នល់ជាតិ ប៉ុន្តែនៅពេលខ្លះ ក៏បានជួបជាមួយទាហាន លន់ នល់ ដោយចៃដន្យ និងបានប្រយុទ្ធគ្នាទៀតផង។

ក្រោយមកអង្គភាពរបស់ខ្ញុំបានបន្តដំណើរដល់ខាងលិចទីក្រុងភ្នំពេញ។ ខ្ញុំត្រូវបានចាត់តាំងឲ្យឈរជើងនៅម្តុំទំនប់កប់ស្រូវ។ នៅខណៈពេលនោះខ្មែរក្រហមបានរៀបចំជាកងវរសេនាធំថ្មីមួយចំណុះឲ្យកងពល១១ប្រចាំនៅភូមិភាគពិសេស ដើម្បីត្រៀមវាយចូលទីក្រុងភ្នំពេញ។ កងវរសេនាធំថ្មីនោះរួមមាន ៤កងវរសេនាតូច គឺវ-១, វ-២, វ-៣ និងវ-៤។ ខ្ញុំស្ថិតនៅក្នុងវរសេនាតូចលេខ៤ (វ-៤) ដោយមាន តាធិន ជាប្រធាន វ-៤ ហើយតា ឡី ជាប្រធានវ-៣ ។ ចំណែកប្រធាននិងអនុប្រធានកងវរសេនាធំថ្មីមានឈ្មោះ តាសារឿន និង តាសាន។ ប្រធានដឹកជញ្ជូនរបស់កងវរសេនាធំរួមមាន យាយរិន និងយាយម៉ែន។ ការងាររបស់ខ្ញុំ គឺទប់ទល់នៅខ្សែត្រៀមកុំឲ្យមានការដកថយក្រោយ។ វ-៤ របស់ខ្ញុំមានភារកិច្ចដើរវាយទាហាននៅតាមបន្ទាយ។ នៅពេលដឹងថាមានបន្ទាយទាហាន លន់ នល់ បោះទីតាំងនៅកន្លែងណា ក្រុមខ្ញុំត្រូវទៅឡោមព័ទ្ធបន្ទាយនោះ។

នៅចុងឆ្នាំ១៩៧៤ កងវរសេនាធំថ្មីនេះត្រូវបានបង្កើតជាកងពល១៤ដែលមាន តាសារឿន គឺជាប្រធាន និង តាសាន ជាអនុប្រធានកងពល។ ចំណែក តាធិន និង តា ឡី បានឡើងជាប្រធានវរសេនាធំរបស់កងពល ១៤ ប្រចាំភូមិភាគពិសេស។

ខ្ញុំឈរជើងនៅតំបន់ទំនប់កប់ស្រូវ រហូតដល់ខ្មែរក្រហមវាយបែកទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នៅពេលវាយចូលមកទីក្រុងភ្នំពេញ មុខព្រួញរបស់ខ្ញុំចូលតាមបុរី១០០ខ្នង នៅពោធិ៍ចិនតុង។ ខ្ញុំមិនបានចូលប្រយុទ្ធទេ ពីព្រោះខ្ញុំធ្វើជាពេទ្យប្រចាំនៅខ្សែត្រៀម។ នៅពេលចាប់ផ្តើមប្រយុទ្ធនៅសមរភូមិម្តងៗ មេបញ្ជាការបានប្រាប់ខ្ញុំឲ្យត្រៀមឧបករណ៍សម្រាប់សង្គ្រោះអ្នកត្រូវរបួស គឺខ្ញុំលូនចូលទៅរុំអ្នករបួស និងអូសចេញមកក្រៅ ដើម្បីព្យួរសេរ៉ូម និងបញ្ជូនបន្តមកកន្លែងស្នាក់ការនៅខាងក្រោយ។ នៅពេលរៀបចំបញ្ជូនអ្នករបួសមកដល់កន្លែងស្នាក់ការហើយ ខ្ញុំត្រូវត្រឡប់ទៅសមរភូមិមុខវិញ។ ខ្ញុំក៏មានភារកិច្ចជួយដាំបាយដាក់ក្នុងស្មុគយកទៅឲ្យកងទ័ពជួរមុខនៅពេលដែលអ្នកទាំងនោះកំពុងជាប់ដៃប្រយុទ្ធ ឬឡោមព័ទ្ធបន្ទាយទាហាន លន់ នល់ ម្តងៗ។ ពេលវាយចូលទីក្រុងភ្នំពេញនោះកងទ័ពខ្មែរក្រហម រួមមាន កងទ័ពភូមិភាគបូព៌ា កងទ័ពភូមិភាគនិរតី ភូមិភាគឧត្តរ និងកងទ័ពភូមិភាគពិសេស។

## ៤ - ខ្មែរក្រហមទទួលបានជ័យជម្នះ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

កងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ខ្ញុំចូលមកតាមពោធិ៍ចិនតុងរហូតដល់ផ្លូវកម្ពុជាក្រោម តាមពេទ្យលោកសង្ឃ និងបន្តមកស្នាក់នៅមុំសាលារៀនសន្ធរម៉ុក។ ពេលដែលចូលដល់ភ្នំពេញភ្លាមមេបញ្ជាការរបស់ពួកខ្ញុំបានទៅប្រជុំ។ បន្ទាប់ពីត្រឡប់មកពីប្រជុំវិញ ស្រាប់តែមានផែនការឲ្យជម្លៀសប្រជាពលរដ្ឋចេញពីទីក្រុងភ្នំពេញ។ រូបខ្ញុំដែលជាពេទ្យយោធា ត្រូវបានមេបញ្ជាការចាត់តាំងឲ្យនៅប្រចាំការនៅអង្គភាព និងជួយរៀបចំផ្ទះសម្បែង។ ខ្ញុំឃើញប្រជាពលរដ្ឋបានចាកចេញពីផ្ទះរបស់ពួកគាត់ប្រហែល ១០ ថ្ងៃ ទើបចេញអស់ និងស្ងាត់ទីក្រុងភ្នំពេញតែម្តង។ ពេលដែលប្រជាជនធ្វើដំណើរតាមផ្លូវកម្ពុជាក្រោមនោះ ខ្ញុំបានឃើញមានទាំងទាហាន, មន្ត្រីរដ្ឋការ និងប្រជាជន។ បន្ទាប់មកប្រធានកងពលបានបញ្ជាខ្ញុំឲ្យដើររើតាមផ្ទះប្រជាជនយករបស់របរ ដូចជា ទូរទឹកកក, ម៉ាស៊ីនដេរ, កង្ហារ មកដាក់មុំ។ ក្រោយមកអង្គភាពរបស់ខ្ញុំត្រូវបានផ្លាស់ឲ្យទៅធ្វើស្រែនៅឃ្មួញ។ ចាប់តាំងពីពេលនោះមកខ្ញុំបានចូលមកទីក្រុងភ្នំពេញតែម្តងម្កាលដើម្បីបើកថ្នាំពេទ្យតែប៉ុណ្ណោះ។

## ៥ - ការធ្វើដំណើរទៅសិក្សានៅប្រទេសចិន

នៅអំឡុងខែមិថុនា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានជ្រើសរើសឲ្យមករៀនសូត្រនៅស្ពាតអូឡាំពិករយៈពេលពីរខែ បន្ទាប់មកបានទៅរៀននៅពោធិ៍ចិនតុងទៀត។ ពេលនៅពោធិ៍ចិនតុង ខ្ញុំត្រូវអង្គការចាត់តាំងឲ្យរើដែក កាត់ស្មៅ កន្លែងណាមានភក់ត្រូវបារសម្អាតឲ្យស្អាត។ បន្ទាប់មកទើបមានការជ្រើសរើសកម្លាំងមកពីគ្រប់អង្គភាពចំនួន ៥០០នាក់ មកពិនិត្យសុខភាព ដើម្បីបញ្ជូនឲ្យទៅរៀននៅប្រទេសចិន ផ្នែកបើកយន្តហោះចម្បាំងធុន៩, ធុន៦, ផ្នែកខទ្ធម្កាចក្រ, ផ្នែកជាងជួសជុល, ផ្នែកខគុនិយម និងខ្លះទៀតត្រូវរៀនខាងផ្នែកការងារនៅព្រលានយន្តហោះ។ ជំនាញការចិនបានមកពិនិត្យសុខភាពដោយផ្ទាល់ រួមមានពិនិត្យមើលភ្នែក, ច្រមុះ, អណ្តាត, ត្រចៀក, ប្រដាប់ភេទ, ឈាម និង ពិនិត្យមេរោគ។ កងទ័ពដែលមានសុខភាពល្អទើបជាប់ ចំពោះអ្នកដែលមានសុខភាពមិនល្អ ត្រូវត្រឡប់ទៅតាមអង្គភាពដើមវិញ។ ការពិនិត្យសុខភាពនោះត្រូវរង់ចាំរយៈពេលមួយខែទើបចេញលទ្ធផល។ ចំពោះអ្នកជាប់ត្រូវចាប់ផ្តើមកាត់សម្លៀកបំពាក់ រកស្បែកជើងប៉ូ, អាវធំ និងត្រៀមវ៉ាលីសម្រាប់ដាក់ខោអាវ។ ខ្ញុំ និងកងទ័ព៨៩នាក់ទៀតបានជាប់ផ្នែករៀនបើកយន្តហោះចម្បាំងធុន៦។ ចំណែកផ្នែករៀនបើកយន្តហោះចម្បាំងធុន ៥ ក៏មានកងទ័ពចំនួន៩០នាក់ត្រូវទៅរៀនសូត្រដែរ។

ប្រហែលជានៅចុងឆ្នាំ១៩៧៥ ខ្ញុំ និងកងទ័ពផ្សេងទៀតបានធ្វើដំណើរចេញពីពោធិ៍ចិនតុងសំដៅទៅទីក្រុងសឺដែជីងប្រទេសចិន។ ពេលដំបូងសិស្សទាំងអស់ត្រូវរៀនភាសាចិន។ បន្ទាប់មកខ្ញុំ និងកូនសិស្សផ្សេងទៀតត្រូវរៀនបើកយន្តហោះចម្បាំងគេ២៨ ដោយរៀន អនុវត្តបើកបរដាក់ស្តែងតែម្តង។ ពេលរៀនបើកបរមិនមានគ្រោះថ្នាក់អ្វីទេ ពីព្រោះមានគ្រូមួយនាក់ សិស្សបីនាក់ និងអ្នកបកប្រែមួយនាក់នៅក្នុងយន្តហោះ។ អ្នកបកប្រែឈ្មោះ ឡោ លី គឺជាជនជាតិចិន។ គ្រូបង្រៀនរបស់ខ្ញុំឈ្មោះ ឡោ ឆាងមិញ។ ក្នុងចំណោមសិស្សដែលទៅពីប្រទេសកម្ពុជាចំនួន៥០នាក់ បានរៀនចប់និងប្រឡងជាប់តែ១៥នាក់ប៉ុណ្ណោះ។ ចំណែកអ្នកដែលប្រឡងមិនជាប់ ត្រូវទៅរៀននៅផ្នែកថតរូប, ផ្នែកជាងជុសជុលគ្រឿងម៉ាស៊ីនយន្តហោះ, ផ្នែកសព្វាវុធ រៀបចំគ្រាប់ដាក់ក្នុងយន្តហោះ និងផ្នែកវិទ្យុទាក់ទងជាដើម។

បន្ទាប់ពីរៀនចប់នៅទីក្រុងសឺដែជីង ខ្ញុំត្រូវឡើងមករៀននៅខេត្តហ៊ឺប៉ីបន្តទៀត។ ពេលមករៀននៅខេត្តហ៊ឺប៉ីគឺខ្ញុំរៀនបើកយន្តហោះប្រដេញធុន ៦ ។ បន្ទាប់ពីខ្ញុំបានបញ្ចប់វគ្គបើកបរយន្តហោះប្រដេញធុន៦នៅខេត្តហ៊ឺប៉ី ខ្ញុំត្រូវបានបញ្ជូនមករៀនផ្នែកយន្តហោះប្រដេញធុន ៥ នៅខេត្តឆាងជាំង ដែលជាខេត្តមួយនៅជាប់មាត់សមុទ្របន្ត

ទៀតៗ យន្តហោះប្រដេញធុន៥ សម្រាប់ទម្លាក់គ្រាប់បែក ប្រភេទដូចគ្រាប់បែកបេ-៥២ ដែរៗ អ្នកដែលបានរៀនបើកបរយន្តហោះប្រដេញធុន ៥ និងធុន ៦ ជំនាន់ ជាមួយខ្ញុំ រួមមាន៖ យាង, ភឿន, ឆែម, ផាត, វន, ហម, ជឿន, រឿន, ពយ, គ្រី, ឡោ, រស្មី (កូនប្រុស សុនសេន) , អៀងវុធ (កូនប្រុស អៀង សារី) និងកូនប្រុស ចេង អន ភ្លេចឈ្មោះៗ

## ៦ - ការធ្វើដំណើរត្រឡប់មកពីប្រទេសចិន និងការហ្វឹកហាត់បើកយន្តហោះចម្បាំងសាកល្បងនៅពោធិ៍ចិនតុង

នៅខែកក្កដា ឆ្នាំ១៩៧៨ ខ្ញុំត្រឡប់ពីប្រទេសចិនមកប្រទេសកម្ពុជាវិញ ខ្ញុំមកស្នាក់នៅជិតផ្សារអូរឡាំពិក ប៉ុន្តែត្រូវទៅហ្វឹកហាត់បើកយន្តហោះប្រដេញនៅពោធិ៍ចិនតុងៗ រៀងរាល់ព្រឹកពួកខ្ញុំទាំង ១៥នាក់ ត្រូវជិះឡានទៅពោធិ៍ចិនតុងៗ នៅព្រលានពោធិ៍ចិនតុងមានយន្តហោះប្រដេញចំនួន៧គ្រឿង ដែលជាប្រភេទយន្តហោះប្រដេញធុន៥ និងធុន៦ៗ នៅពេលនោះយន្តហោះប្រដេញដែលអាចប្រើប្រាស់បានមានតែបីគ្រឿង ចំណែកបួនគ្រឿងទៀតកំពុងរៀបចំដម្លើងមិនទាន់រួចរាល់ៗ ពួកខ្ញុំតែងតែបើកបរយន្តហោះប្រដេញទាំង៣គ្រឿងនោះសាកល្បងឡើងចុះៗ នៅព្រលានពោធិ៍ចិនតុងជាមួយគ្រូចិនៗ ខ្ញុំនៅចាំឈ្មោះគ្រូចិនចំនួន២នាក់ដែលបានបង្ហាត់បង្រៀននៅព្រលានយន្តហោះពោធិ៍ចិនតុង គឺលោកគ្រូ ចាង ឆាងយ៉ែន និងលោកគ្រូ លី ឈីម៉ីងៗ ជួនកាលពួកខ្ញុំបានបើកសាកល្បងពីភ្នំពេញទៅកំពង់ចាម និងពីកំពង់ចាមទៅកំពង់ធំៗ ខ្ញុំធ្លាប់បានបើកយន្តហោះប្រដេញទៅខាងសៀមរាបអង្គរ រួចបន្តមកខេត្តបាត់ដំបង ចូលមកខាងភ្នំឱរ៉ាល់ បន្ទាប់មកបានចុះចតនៅព្រលានពោធិ៍ចិនតុងក្នុងថេរវេលា៤៥នាទីៗ ពួកខ្ញុំមានគម្រោងបើកយន្តហោះទៅទម្លាក់គ្រាប់នៅស្រុកមេមត់ដែរ ប៉ុន្តែដល់ថ្ងៃត្រូវចេញដំណើរ គឺស្អែកឡើងកងទ័ពវៀតណាមបានចូលមកដល់ទីក្រុងភ្នំពេញតែម្តងៗ នៅចុងឆ្នាំ១៩៧៨ និងដើមឆ្នាំ១៩៧៩ កងទ័ពជើងអាកាសខ្មែរក្រហមបានបើកយន្តហោះស្ទាបកាត់ធុនតេ២៨ ទៅទម្លាក់គ្រាប់នៅព្រំដែនកម្ពុជា-វៀតណាម ក្នុងស្រុកមេមត់ៗ កងទ័ពជើងអាកាសខ្មែរក្រហមទាំងនោះរួមមាន៖ ឈ្មោះ ធី, វ៉ែង និង មឿនៗ ឈ្មោះ វ៉ែង បានបើកយន្តហោះស្ទាបកាត់តេ ២៨ ទៅទម្លាក់គ្រាប់នៅស្រុកមេមត់ និងត្រូវកងទ័ពវៀតណាមបាញ់យន្តហោះធ្លាក់ៗ ចំណែក វ៉ែង ត្រូវភ្លើងឆេះពេញខ្លួន និងបានកងទ័ពខ្មែរក្រហមផ្សេងទៀតយកឡានទៅជួយសង្គ្រោះទាន់ពេលវេលាៗ សព្វថ្ងៃឈ្មោះ វ៉ែង, ធី និង មឿន រស់នៅក្នុងស្រុកសំឡូតៗ នៅក្នុងឆ្នាំ១៩៧៨ ខ្មែរក្រហមក៏បានបង្រៀនបើកបរយន្តហោះទម្លាក់គ្រាប់នៅព្រលានយន្តហោះវាលបែកចាន ខេត្តបាត់ដំបងដែរៗ នៅខេត្តបាត់ដំបងមានយន្តហោះស្ទាបកាត់តេ២៨ចំនួន៦គ្រឿងៗ ចំណែកនៅព្រលានយន្តហោះពោធិ៍ចិនតុងមានយន្តហោះស្ទាបកាត់តេ ២៨ ចំនួន៣-៤ គ្រឿងដែរៗ គានឹម គឺជាអ្នកគ្រប់គ្រងនៅព្រលានយន្តហោះវាលបែកចាន និងជាអ្នកបង្រៀនកងទ័ពអាកាសប្រចាំនៅព្រលាននោះៗ

មុនពេលដែលវៀតណាមចូលមកដល់ភ្នំពេញ ខ្មែរក្រហមមានគម្រោងរៀបចំនាំពួកខ្ញុំត្រឡប់ទៅប្រទេសចិនវិញ ប៉ុន្តែត្រូវអាក់ខានដោយសារ សម្តេចឪ និងព្រះរាជសានុវង្សត្រូវយាងចាកចេញទៅមុនៗ ចំណែកពួកខ្ញុំត្រូវរង់ចាំទៅតាមក្រោយៗ ជាអកុសលកងទ័ពវៀតណាមបានចូលមកដល់ទីក្រុងភ្នំពេញ ពួកខ្ញុំទាំង ១៥នាក់ត្រូវឡើងឡានភៀសខ្លួនមកខាងខេត្តបាត់ដំបងៗ

## ៧ - ការតស៊ូនៅក្នុងព្រៃ ក្រោយឆ្នាំ១៩៧៩

មុនមកដល់បាត់ដំបង ឡានពួកខ្ញុំបានខូចនៅកំពង់ឆ្នាំង ដូច្នេះការធ្វើដំណើរទម្រាំមកដល់ខេត្តបាត់ដំបងគឺនៅពេលយប់ៗ ព្រឹកព្រលឹមឡើងពួកខ្ញុំក៏បានបន្តដំណើរទៅភ្នំសំពៅ ហើយខ្មែរក្រហមចាប់ផ្តើមបែងចែកកម្លាំងៗ ដោយសារពីមុនខ្ញុំធ្លាប់ធ្វើជាពេទ្យ ខ្ញុំត្រូវចាត់តាំងឲ្យនៅក្នុងអង្គភាពពេទ្យៗ ចំណែកអ្នកផ្សេងៗទៀត គឺនៅតាមកងរៀងៗខ្លួនៗ ទោះជាធ្វើជាពេទ្យ ប៉ុន្តែខ្មែរក្រហមក៏បានចែកអាវុធឲ្យខ្ញុំកាន់ដែរៗ ក្រោយមកពួកយើងបានចូលសមរភូមិ ខ្ញុំ និង អៀងវុធ ត្រូវរបួសដេកពេទ្យដូចគ្នាៗ ចេញ

ពីពេទ្យមកវិញ យើងបានបែកគ្នាខ្ញុំមកនៅក្នុងវរសេនាតូចដែលមាន តាអង ជាប្រធាន។ តាអង ធ្លាប់បានប្រចាំការនៅព្រលានយន្តហោះវាលបែកចានខេត្តបាត់ដំបង។ ក្រោយមកពួកយើងចេះតែគេចពីកងទ័ពវៀតណាមចូលទៅក្នុងព្រៃរហូតដល់តំបន់សំឡូត។ កងរបស់ពួកខ្ញុំមានលេខ ៥៥៥។ តាម៉េត ជាប្រធានកងពលធំ ចំណែក តានឹម និង តាអង ប្រធានវរសេនាធំ។ ពេលដែលខ្ញុំនៅសំឡូត អៀង វុធ បានផ្ញើសំបុត្រឲ្យខ្ញុំទៅនៅជាមួយគាត់ជាច្រើនដង ប៉ុន្តែខ្ញុំទៅមិនរួចព្រោះមីនច្រើនពេក ហើយម្យ៉ាងទៀត តាអង មិនអនុញ្ញាតឲ្យទៅនៅជាមួយ អៀង វុធ។ ខ្ញុំនៅធ្វើពេទ្យប្រចាំនៅឃុំតាសាញ បច្ចុប្បន្នគឺជាសាលាស្រុកសំឡូត។

នៅឆ្នាំ១៩៨៨ ខ្ញុំបានជាន់មីននៅសំឡូត ត្រូវពិការជើងម្ខាង និងបានសម្រាកព្យាបាលនៅមន្ទីរពេទ្យក្នុងតំបន់សំឡូត។ បន្ទាប់ពីជាសះស្បើយ ខ្ញុំបានឈប់ធ្វើពេទ្យ និងបានផ្លាស់មកធ្វើជាគ្រូបង្រៀនវិញ ពីព្រោះកងទ័ពខ្មែរក្រហមក៏ចង់ឲ្យកូនចៅចេះដឹងដែរ។ ពួកគេបានយកកូនមកឲ្យខ្ញុំបង្រៀន និងជួយឧបត្ថម្ភដល់ខ្ញុំបន្តិចបន្តួច។ នៅពេលនោះខ្ញុំបង្រៀនក្មេងៗចំនួន៣ថ្នាក់ នៅបឋមសិក្សា គឺថ្នាក់ទី១២ ទី១១ ទី១០ និងទី៩ (ប្រព័ន្ធចាស់)។ ការបង្រៀនជំនាន់សង្គ្រាម គឺគ្រាន់តែអាចឲ្យក្មេងៗអាចចេះអាន និងសរសេរបានតែប៉ុណ្ណោះ។ ខ្ញុំបានរស់នៅសំឡូតរហូតដល់ឆ្នាំ១៩៩៥ ទើបខ្ញុំផ្លាស់មករស់នៅខាងកោះកុង(បច្ចុប្បន្នស្រុកវាលវែង) ព្រោះតែដឹងថាភាគីរាជរដ្ឋាភិបាលកម្ពុជា និងខ្មែរក្រហម បានចាប់ផ្តើមចចារត្រូវរ៉ូវគ្នាបណ្តើរៗ។ ប្រធានកងពលរបស់ខ្មែរក្រហមបានចាត់តាំងឲ្យពង្រាយកម្លាំងមករស់នៅតាមតំបន់ដីធ្លីថ្មីតាមកង និងអង្គភាពរៀងៗខ្លួន។ អង្គភាពរបស់ខ្ញុំមានសមាជិកជាង១០០នាក់ គឺជាកងវរសេនាធំឯករាជ្យដែលគ្រប់គ្រងដោយមេបញ្ជាការឈ្មោះ គីម ពៅ។ គីម ពៅ ត្រូវបានថ្នាក់លើចាត់តាំងឲ្យមកសហការជាមួយអង្គភាពរបស់ អួន យ៉ង់ នៅតំបន់ថ្មដា។ មុខព្រួញរបស់គីម ពៅ ចាប់ពីតំបន់អូរសោមទៅទល់នឹងមាត់សមុទ្រក្នុងទឹកដីខេត្តកោះកុង។ ពេលមកដល់ដំបូង កងរបស់ខ្ញុំនិងក្រុមគ្រួសារបានស្នាក់នៅម្តុំស្ទឹងថ្មី ក្នុងភូមិសាស្ត្រឃុំប្រម៉ោយបច្ចុប្បន្ន។ គ្រួសារខ្ញុំ និងគ្រួសារផ្សេងៗទៀតបានរស់នៅក្បែរមាត់ស្ទឹង ពីព្រោះងាយស្រួលរកត្រីសាច់ធ្វើម្ហូបអាហារ និងមានប្រភពទឹកប្រើប្រាស់ប្រចាំថ្ងៃ។

ពេលនៅម្តុំស្ទឹងថ្មី ខ្ញុំនៅតែបង្រៀនកូនចៅរបស់កងទ័ពដដែល។ កូនសិស្សរបស់ខ្ញុំមានចំនួនប្រហែល៥០នាក់។ ខ្ញុំបានសៀវភៅពីរ-បីក្បាល ពីឈ្មោះ សឿង ដែលបានទទួលសៀវភៅមកពីថ្នាក់លើ។ ខ្ញុំ និងខ្មែរក្រហមដទៃទៀតបានចូលរួមធ្វើសមាហរណកម្មលើកទី១ នៅប្រម៉ោយក្នុងឆ្នាំ១៩៩៦។ បន្ទាប់ពីមានព្រឹត្តិការណ៍ថ្ងៃទី ៥-៦ កក្កដា ឆ្នាំ១៩៩៧ ក្រុមគ្រួសារខ្ញុំ និងគ្រួសារខ្មែរក្រហមផ្សេងទៀតបានភៀសខ្លួនចូលទៅរស់នៅក្នុងប្រទេសថៃជាមួយអង្គភាពរបស់ អួន យ៉ង់។ នៅចុងក្រោយខ្ញុំ និងខ្មែរក្រហមដទៃទៀតបានចូលរួមធ្វើសមាហរណកម្មជាលើកទី២ នៅព្រំដែនកម្ពុជា-ថៃ នៅឆ្នាំ១៩៩៨។

នៅឆ្នាំ១៩៩៩ ខ្ញុំ និងក្រុមគ្រួសារបានត្រឡប់ពីព្រំដែនមករស់នៅស្រុកវាលវែង និងបានចូលបង្រៀនកូនសិស្សនៅសាលាចំនួន៣ នៅភូមិទួលគ្រួស តាំងយ៉ និងដូននាគ។ នៅឆ្នាំ២០០០ មន្ទីរអប់រំស្រុកវាលវែងបានរៀបចំឲ្យខ្ញុំទៅរៀនបំពេញវិជ្ជាជាគ្រូបង្រៀនក្របខណ្ឌ ។ ខ្ញុំឡើងទៅរៀនបំពេញវិជ្ជានៅខេត្តពោធិ៍សាត់រយៈពេលពីរខែ។ បន្ទាប់មកខ្ញុំបានទៅរៀននៅភ្នំពេញបន្តទៀត ទើបទទួលបានប្រាក់បៀវត្សរ៍ដូចគ្រូបង្រៀនផ្សេងទៀត។ ខ្ញុំបានបង្រៀននៅសាលាបឋមសិក្សាតាំងយ៉ែរហូតដល់ឆ្នាំ២០០៩ ទើបខ្ញុំបានក្របខណ្ឌជានាយកសាលាបឋមសិក្សាតាំងយ៉ែ។ ខ្ញុំចូលនិវត្តន៍នៅឆ្នាំ២០១៥ ប៉ុន្តែខ្ញុំបន្តជាបុគ្គលិកបណ្តែត និងបានជួយបង្រៀនកូនសិស្សរហូតដល់ឆ្នាំ២០១៩ ទើបឈប់សម្រាកទាំងស្រុង។

# ឯកអគ្គរាជទូតជប៉ុនធ្វើទស្សនកិច្ចនៅ «បណ្ណាល័យសម្តេចម៉ែ»

ផាត ចាន់សុនិតា



*ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជាលោក មិកាមិ ម៉ាសាហ៊ីរ៉ូ ដឹកនាំក្រុមការងាររបស់លោក រួមមានលោក ម៉ូរី ណូប៊ូ លេខាទី១, អ្នកនាង គូស៊ូណូគី ម៉ារីយ៉ា លេខាទី៣ និង លោក អ៊ីម៉ាដា អាគីណូរី អ្នកសិក្សាស្រាវជ្រាវ និងជាទីប្រឹក្សារបស់លោកមកទស្សកិច្ចនៅ «បណ្ណាល័យសម្តេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២១។ (សូរិចិត្រ មេត្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ប្រទេសជប៉ុន ធ្លាប់ជាម្ចាស់ជំនួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លើផ្នែកសម្ភារការិយាល័យ និងសន្តិសុខអគារ នៅមុនពេលដែលមានតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម។

នារសៀលថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២១ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាមានកិត្តិយសទទួលស្វាគមន៍ លោក មិកាមិ ម៉ាសាហ៊ីរ៉ូ ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជា ដែលបានដឹកនាំក្រុមការងាររបស់លោក រួមមានលោក ម៉ូរី ណូប៊ូ លេខាទី១, អ្នកនាង គូស៊ូណូគី ម៉ារីយ៉ា លេខាទី៣ និង លោក អ៊ីម៉ាដា អាគីណូរី អ្នកសិក្សាស្រាវជ្រាវ និងជាទីប្រឹក្សារបស់លោកមកទស្សកិច្ចនៅ «បណ្ណាល័យសម្តេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

ដំណើរទស្សនកិច្ចចាប់ផ្តើម ដោយការផ្តល់ព័ត៌មានលម្អិតអំពីពិព័រណ៍នៃព្រះឆាយាល័ក្ខណ៍របស់សម្តេចព្រះបរមរតនកោដ្ឋ ព្រះវររាជបិតាជាតិខ្មែរ, សម្តេចព្រះ





ឯកអគ្គរាជទូតជប៉ុនប្រចាំនៅកម្ពុជាលោក មិកាមិ ម៉ាសាហ៊ីរ៉ូ ដឹកនាំក្រុមការងាររបស់លោក រួមមានលោក ម៉ូរី ណូប៊ូ លេខាទី១, អ្នកនាង គូស៊ូណូគី ម៉ារីយ៉ា លេខាទី៣ និងលោក អ៊ីម៉ាដា អាគីណូរី អ្នកសិក្សាស្រាវជ្រាវ និងជាទីប្រឹក្សារបស់លោកមកទស្សកិច្ចនៅ «បណ្ណាល័យសម្តេចម៉ែ» នៃវិទ្យាស្ថានស្លឹករឹតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ ២០២១។ (សូវិចិត្រ មេត្តាមជ្ឈមណ្ឌលឯកសារកម្ពុជា)





វររាជមាតាជាតិខ្មែរ និងរាជវង្សានុវង្សផ្តល់ដោយបណ្ឌិត ហូលីយ៉ូ អេ. ដែលជ្រេស អតីតអ្នកសរសេរព្រះរាជជីវប្រវត្តិរបស់សម្តេចព្រះបរមរតនកោដ្ឋ អមជាមួយនឹងភ្លេងដែលជាព្រះរាជនិពន្ធរបស់សម្តេចព្រះបរមរតនកោដ្ឋ។

ផ្ទាំងព្រះឆាយាល័ក្ខណ៍ពិពរណ៍និងភ្លេង បានរំឭកដល់ព្រះរាជប្រវត្តិស្នេហាររវាងសម្តេចឪនិងសម្តេចម៉ែ ដែលបានកត់ត្រាទុកអំពីជំពូកមួយដែលមានចំណងជើងថា «ស្នេហាមួយដែលមិនមែនជារឿងព្រេងនិទាន» នៅក្នុងសៀវភៅ «សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថសីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល៖ ព្រះរាជដំណើរជីវិតពោរពេញទៅដោយព្រឹត្តិការណ៍»។ ជំពូកនេះលើកឡើងអំពីចម្រៀងពីរបទគឺ «រាត្រីដែលបានជួបភ័ក្ត្រ» ជាព្រះរាជនិពន្ធរបស់សម្តេចព្រះបរមរតនកោដ្ឋសម្រាប់ព្រះរាជពិធីវិវាហមង្គលនៃទ្រង់ទាំងពីរ និងបទ «ម៉ូនីកា» ប្រទានដល់សម្តេចម៉ែ ដើម្បីសម្តែងព្រះរាជហឫទ័យស្នេហារបស់ព្រះអង្គចំពោះទ្រង់។ ចាប់តាំងពីរៀបអភិសេកមក សម្តេចម៉ែតែងតែនៅក្បែរព្រះកាយរបស់ព្រះស្វាមីគ្រប់ពេល ដោយឆ្លងកាត់នូវអនុស្សាវរីយ៍ផ្អែមល្ហែងជូរចត់រួមគ្នាដូចនៅក្នុងព្រះឆាយាល័ក្ខណ៍បានបង្ហាញ។ នេះគឺជារឿងស្នេហាអមតៈ យកឈ្នះរាល់ឧបសគ្គនិងមិនប្រែប្រួល ដែលកើតមានក្នុងព្រះជីវិតពិតរបស់ទ្រង់។

បន្ទាប់មក លោក ឆាំង យុ បានបង្ហាញដល់ភ្ញៀវកិត្តិយសនូវបណ្ណាល័យ និងបរិក្ខារដែលរួមមានដូចជា ម៉ាស៊ីនផ្ទុកឯកសារទម្រង់ជាឌីជីថល ឯកសារទម្រង់ដើម ឯកសាររូបថត ឯកសារវីដេអូនិងឯកសារជាសំឡេងនានា។

លោក ឆាំង យុ បានរៀបរាប់យ៉ាងលម្អិតអំពីបេសកកម្មយូរអង្វែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការលើកកម្ពស់យុត្តិធម៌ ការចងចាំ និងការផ្សះផ្សាតាមរយៈការប្រមូលចងក្រងភស្តុតាងជាប្រវត្តិសាស្ត្រទាក់ទងនឹងអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលក្រុមការងារបាននិងកំពុងបន្តអនុវត្ត។ លោកស្រី សូ ហ្វារីណា បានបង្ហាញអំពីទីតាំងស្រាវជ្រាវ, មជ្ឈមណ្ឌលស្រាវជ្រាវនិងបណ្ណាល័យខ្មែរក្រហមនៅតាមបណ្តាខេត្តទាំង១០។

លោកឯកអគ្គរាជទូត មិកាមិ ម៉ាសាហ៊ីរ៉ូ តំណាងឲ្យស្ថានទូតជប៉ុនប្រចាំនៅកម្ពុជាបានបន្សល់ទុកចំណារអនុស្សាវរីយ៍លើសៀវភៅក្រាំងមាសរបស់ «បណ្ណាល័យសម្តេចម៉ែ» ដែលមានខ្លឹមសារដូចតទៅ៖

**"សូមអរគុណយ៉ាងជ្រាលជ្រៅចំពោះការអញ្ជើញរូបខ្ញុំ និងសហការីរបស់ខ្ញុំមកកាន់បណ្ណាល័យដ៏ស្រស់ស្អាតក្នុងថ្ងៃនេះ។ ខ្ញុំមានការគោតស្ញប់ស្ញែងយ៉ាងខ្លាំងចំពោះពិព័រណ៌ និងការងារដែលអនុវត្តន៍ឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំគិតថា បណ្ណាល័យនេះគឺជាការចូលរួមចំណែកដ៏វិសេសវិសាលមួយសម្រាប់អនាគតមនុស្សជំនាន់ក្រោយទូទាំងពិភពលោក។**

*ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ -*
*ឯកអគ្គរាជទូត មិកាមិ ម៉ាសាហ៊ីរ៉ូ"*






# សៃ បត
# អតីតកងទ័ពស្ម័គ្រចិត្តវៀតណាម

**សុខ វណ្ណៈ**

សៃ បត មានអាយុ៦៤ឆ្នាំ សព្វថ្ងៃរស់នៅភូមិចង្កុំ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ បត មានប្រពន្ធឈ្មោះ សន ខ្វិល អាយុ៥០ឆ្នាំ និងមានកូនចំនួនបីនាក់ ប្រុសពីរ ស្រីមួយ។ សព្វថ្ងៃ បត បានប្រកបមុខរបរធ្វើស្រែចម្ការ។ សៃ បត បានរៀបរាប់រឿងរ៉ាវជីវិតដែលបានឆ្លងកាត់ដូចខាងក្រោម៖

ឪពុករបស់ខ្ញុំ មានឈ្មោះ ស្រីក សៃ មានអាយុ ៨៤ ឆ្នាំ មានស្រុកកំណើតនៅភូមិតាតេ ប្រទេសវៀតណាម។ ឪពុកខ្ញុំគឺជាកូនកាត់ស្ទៀង និងវៀតណាម រីឯម្តាយឈ្មោះ យ៉េត សៅ ជាកូនកាត់ខ្មែរស្ទៀងមានស្រុកកំណើតនៅភូមិចង្កុំ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ ខ្ញុំមានបងប្អូនបង្កើត៩នាក់ ស្រី៣នាក់ និងប្រុស៦នាក់។ ខ្ញុំធ្លាប់បានរៀនអក្សរខ្មែរតិចតួច។ ខ្ញុំចេះអាន និងសរសេរអក្សរខ្មែរ ហើយថែមទាំងចេះភាសាវៀតណាមទៀត។

ខ្ញុំធំដឹងក្តីនៅពេលប្រទេសជាតិកើតមានសង្គ្រាម។ កាលខ្ញុំអាយុ១០ឆ្នាំ ខ្ញុំរស់នៅជាមួយឪពុកម្តាយនៅក្នុងទឹកដីប្រទេសវៀតណាម។ ឪពុករបស់ខ្ញុំធ្លាប់ធ្វើជាទាហានជើងក្រហមរបស់បារាំង។ ឪពុករបស់ខ្ញុំត្រូវបានអាជ្ញាធរវៀតណាមចោទប្រកាន់ថា មាននិន្នាការប្រឆាំងរដ្ឋាភិបាលវៀតណាម។ ក្រោយមកត្រូវបានអាជ្ញាធរវៀតណាមគំរាមកំហែង និងតាមចាប់ខ្លួនគាត់ជាច្រើនលើក។ ពេលនោះបងប្អូនជនជាតិស្ទៀងជាច្រើននាក់បានទៅជួយនិយាយ និងជួយតវ៉ាជាមួយអាជ្ញាធរវៀតណាមទើបឪពុករបស់ខ្ញុំបានរួចផុតពីការចោទប្រកាន់។ ដោយគិតថាមិនអាចរស់នៅប្រទេសវៀតណាមបានតទៅទៀត ឪពុករបស់ខ្ញុំក៏សម្រេចចិត្តមករស់នៅស្រុកកំណើតខាងម្តាយរបស់ខ្ញុំនៅស្រុកខ្មែរវិញ។

នៅឆ្នាំ១៩៦២ ខ្ញុំនិងគ្រួសារបានចាកចេញពីប្រទេសវៀតណាមមករស់នៅម្តុំភូមិសាស្ត្រ ភូមិចង្កុំ និងភូមិកោះថ្ម ស្ថិតនៅក្នុងឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម ដែលពេលនោះមិនទាន់មានប្រជាជនរស់នៅច្រើនទេ គឺភូមិ



សៃ បត មានអាយុ៦៤ឆ្នាំ សព្វថ្ងៃរស់នៅភូមិចង្កុំ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នីមួយៗមានប្រជាជនរស់នៅប្រមាណ ៣០ ទៅ ៤០ គ្រួសារប៉ុណ្ណោះ។ ប្រជាជនចូលចិត្តរស់នៅផ្តុំគ្នាជាក្រុម។ ភូមិនីមួយៗមានផ្ទៃដីធំទូលាយលាតសន្ធឹងរហូតដល់ព្រំប្រទល់ប្រទេសវៀតណាម។ កាលនោះនៅក្នុងភូមិមានព្រៃដុះជុំជិត មានដើមឈើធំៗ និងមានសត្វព្រៃជាច្រើនប្រភេទ។ ប្រជាជនភាគច្រើននៅតំបន់នេះគឺជាកូនកាត់ស្ទៀង ប្រកបមុខរបរកាប់ដីធ្វើចម្ការ និងធ្វើស្រែដោយបុកដីដាំស្រូវនៅក្នុងព្រៃ ដូចជនជាតិភាគតិចព្នងដែរ។ សម័យនោះដីធំទូលាយ ចំណែកប្រជាជនមានចំនួនតិច ដូច្នេះហើយប្រជាជនបានធ្វើស្រែចម្ការចល័តទីតាំង និងមិនមានកម្មសិទ្ធិលើដីឡើយ។ ប្រជាជនបានកាប់ដីធ្វើចម្ការ និងដាំស្រូវម្តងបុពីរដងនៅលើទីតាំងមួយ បន្ទាប់មកក៏នាំគ្នាផ្លាស់ទៅកន្លែងថ្មីទៀត ដោយសារប្រជាជនគិតថាបើដាំនៅកន្លែងដដែលៗដំណាំមិនសូវលូតលាស់ល្អ។

នៅឆ្នាំ១៩៦៣ សង្គ្រាមនៅប្រទេសវៀតណាមកាន់តែរីករាលដាលខ្លាំងឡើង។ ខ្ញុំបានដឹងថា កងទ័ពវៀតកុងមួយចំនួនធំបានមកលាក់ខ្លួនក្នុងព្រៃនៅលើទឹកដីរបស់ខ្មែរ។ ខ្ញុំនិងបងប្អូនប្រជាជននៅក្នុងភូមិបាននាំគ្នា

ទិញអង្ករ និងថ្នាំពេទ្យយកទៅលក់បន្តឲ្យកងទ័ពវៀតកុងបានចំណេញប្រាក់យ៉ាងច្រើន។ ប៉ុន្តែខ្ញុំក៏ត្រូវប្រថុយគ្រោះថ្នាក់ដែល ដោយសារមានយន្តហោះទម្លាក់គ្រាប់បែកបេ ៥២ របស់សហរដ្ឋអាមេរិច ហោះមកទម្លាក់គ្រាប់នៅទីតាំងកងទ័ពវៀតកុងលាក់ខ្លួន។

នៅឆ្នាំ១៩៧០ នៅប្រទេសខ្មែរក៏កើតមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់ សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ដែលដឹកនាំដោយលោកសេនាប្រមុខ លន់ នល់។ ពេលនោះប្រជាជននៅតាមស្រុកស្រែចម្ការខឹងសម្បារ លន់ នល់ យ៉ាងខ្លាំង ហើយបាននាំគ្នាជិះឡាននៅធ្វើបាតុកម្មតវ៉ាដើម្បីទាមទារឲ្យសម្តេចឪត្រឡប់មកវិញ។ កាលនោះមានកម្លាំងយុវជនរួមទាំងមនុស្សចាស់មួយចំនួនបានទៅតវ៉ារហូតដល់ស្រុកស្នួល ខេត្តក្រចេះ ហើយត្រូវបានទាហាន លន់ នល់ បាញ់បង្ក្រាបបណ្តាលឲ្យស្លាប់និងរបួសមនុស្សជាច្រើន។ ដោយឃើញសភាពការណ៍មិនស្រួល ប្រជាជនបាននាំគ្នាត្រឡប់មកផ្ទះរៀងៗខ្លួនវិញ។

នៅចន្លោះឆ្នាំ១៩៧១ និង ឆ្នាំ១៩៧៣ មានយន្តហោះមកទម្លាក់គ្រាប់បែកជាច្រើនកន្លែងនៅតាមព្រៃដែលសំដៅរកកន្លែងកងទ័ពវៀតកុងលាក់ខ្លួន។ ខ្ញុំបានឃើញទាហានអាមេរិកាំងដើរនៅក្នុងភូមិរបស់ខ្ញុំ ហើយថែមទាំងមកតាំងបន្ទាយនៅខាងជើងភូមិកោះថ្ម និងនៅក្នុងភូមិមួយចំនួនទៀតក្នុងរយៈពេលខ្លី។

អំឡុងឆ្នាំ១៩៧៤ កម្លាំងរបស់ខ្មែរក្រហមជាច្រើននាក់បានចូលមករស់នៅក្នុងភូមិស្ថិតនៅជាយដែន និងនៅទីប្រជុំជន។ ពេលនោះដោយសារខ្លាចខ្មែរក្រហមបង្ខំឲ្យកូនចៅចូលបម្រើយោធា និងបម្រើបដិវត្តន៍ ឪពុករបស់ខ្ញុំបាននិយាយលួងលោមម្តាយរបស់ខ្ញុំឲ្យត្រឡប់ទៅរស់នៅប្រទេសវៀតណាមមួយរយៈសិន។ ពេលនោះម្តាយរបស់ខ្ញុំព្រមទាំងបងប្អូនខ្ញុំមិនចង់ទៅតាមឪពុកខ្ញុំទេ ប៉ុន្តែដោយសារឪពុករបស់ខ្ញុំបានលួងលោមខ្លាំងពេកទើបម្តាយខ្ញុំបានយល់ព្រមទៅរស់នៅប្រទេសវៀតណាម។

នៅឆ្នាំ១៩៧៦ ខ្ញុំបានជាប់ជាកាតព្វកិច្ចបម្រើកងទ័ពវៀតណាម និងបានចូលរៀនសាលាយោធា នៅហូយាវ។ ពេលរៀនចប់ ខ្ញុំត្រូវបានបញ្ជូនមកការពារព្រំដែនដែលជាប់ព្រំប្រទល់ប្រទេសខ្មែរ។ ខ្ញុំធ្លាប់បានប្រយុទ្ធជាមួយយោធាខ្មែរក្រហមជាច្រើនលើកច្រើនសារនៅចន្លោះពីឆ្នាំ១៩៧៧ ដល់ ឆ្នាំ១៩៧៨ ដែលការវាយប្រយុទ្ធគ្នានោះបានកើតឡើងតាំងពីឆ្នាំ១៩៧៦មកម្ល៉េះ។

នៅឆ្នាំ១៩៧៩ ខ្ញុំបានវាយជាមួយយោធាខ្មែរក្រហមនៅតាមព្រំដែន និងបន្តចូលមកប្រទេសកម្ពុជាតាមស្រុកស្នួល ខេត្តក្រចេះ។ ពេលនោះខ្ញុំបានសង្កេតឃើញថាប្រជាជនភាគច្រើនស្គមស្គាំង និងគ្មានខោអាវស្លៀកពាក់សមរម្យឡើយ។ ពេលនោះខ្ញុំបាននិយាយភាសាខ្មែរទៅកាន់ប្រជាជនដែលបានឈរមើលកងទ័ពវៀតណាម។ ប្រជាជនបាននាំគ្នាសើច និង សប្បាយរីករាយពេលឮខ្ញុំនិយាយភាសាខ្មែរច្បាស់។ ខ្ញុំនិងកងទ័ពវៀតណាមដែលនៅសេសសល់របបអង្ករបីបាវនៅរថយន្ត ហើយយើងក៏បានផ្តល់អង្ករទាំងនោះឲ្យប្រជាជនដើម្បីចែកគ្នា។ បន្ទាប់មក ខ្ញុំបានធ្វើដំណើរបន្តទៅដល់ខេត្តក្រចេះ។ មិនយូរប៉ុន្មានអង្គភាពយោធារបស់ខ្ញុំបានចល័តមកបោះទីតាំងនៅទីរួមខេត្តកំពង់ចាម ដោយពេលនោះខ្ញុំមានឋានន្តរសក្តិពាក់ដោយបីជាន់។

នៅចន្លោះពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨០ ប្រជាជនកាន់តែច្រើនបានចូលមករស់នៅក្នុងខេត្តកំពង់ចាម ប៉ុន្តែក៏មានយោធាខ្មែរក្រហមមកលាក់ខ្លួនជាមួយប្រជាជនទាំងនោះ និងបានបង្កការអុកឡុកធ្វើឲ្យកងទ័ពវៀតណាមពិបាកទប់ទល់ដែរ។ ជារឿយៗកងកម្លាំងខ្មែរក្រហមបានវាយឆ្មក់ ដែលធ្វើឲ្យខ្ញុំមានការភ័យខ្លាចដែរ។ នៅឆ្នាំ១៩៨០ ដោយសារនឹកភូមិកំណើតខាងម្តាយនៅភូមិចង្កុំ ខ្ញុំបានរត់ចេញពីអង្គភាពកងទ័ព មកជួបជាមួយបងប្អូន អ៊ំ ពូ មីង ខាងម្តាយ និងលែងត្រឡប់ទៅវៀតណាមទៀត។

នៅរវាងឆ្នាំ១៩៨២ និងឆ្នាំ១៩៨៣ ខ្ញុំបានទៅយកឪពុកម្តាយ និងបងប្អូនដែលរស់នៅប្រទេសវៀតណាមមករស់នៅស្រុកខ្មែរវិញ។ ដំបូងឪពុកខ្ញុំប្រកែកមិនព្រមមក ប៉ុន្តែនៅទីបំផុតគាត់បានមកតាមម្តាយរបស់ខ្ញុំមករស់នៅស្រុកខ្មែរ។ ខ្ញុំបានរស់នៅជាមួយឪពុកម្តាយ និងបងប្អូន ដោយប្រកបមុខរបរធ្វើស្រែចម្ការនៅភូមិចង្កុំ។

នៅឆ្នាំ១៩៨៧ ខ្ញុំបានចូលធ្វើជាប៉ូលិសនៅឃុំទន្លូងម្តងទៀត ហើយបានទៅយាមការពារព្រំដែននៅជិតទន្លេចាម និងម្តុំដើមត្រយឹងដែលជាកន្លែងសម្តេចតេជោ ហ៊ុន សែន បន់ស្រន់សូមសេចក្តីសុខមុនចាកចេញពីប្រទេសកម្ពុជាចូលទៅក្នុងទឹកដីវៀតណាម។

នៅឆ្នាំ២០០០ ខ្ញុំឈប់ធ្វើជាប៉ូលិសហើយក្រោយមកបានធ្វើជាប្រធានភូមិចង្កុំ និងបានរស់នៅជុំជាមួយប្រពន្ធកូនរហូតមក។

# ប្រតិភូកាកបាទក្រហមកម្ពុជាទស្សនកិច្ច «បណ្ណាល័យសម្តេចម៉ែ»

*សុភ័ក្រ្ត ភាណា*



*គណៈប្រតិភូចំនួន១៥រូប ដឹកនាំលោកជំទាវ ពុំ ចន្ទីនី អគ្គលេខាធិការកាកបាទក្រហមកម្ពុជា បានមកធ្វើទស្សនកិច្ច «បណ្ណាល័យសម្តេចម៉ែ» នាព្រឹកថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១។ (សូរិចិត្រ មេត្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

*លោកជំទាវ ពុំ ចន្ទីនី អគ្គលេខាធិការកាកបាទក្រហមកម្ពុជា បានដឹកនាំគណៈប្រតិភូចំនួន ១៥ រូប មកធ្វើទស្សនកិច្ច «បណ្ណាល័យសម្តេចម៉ែ» នាព្រឹកថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០២១។*

*អស់រយៈកាលជាច្រើនឆ្នាំកន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជា ធ្លាប់បានសហការជាមួយនឹងកាកបាទក្រហមកម្ពុជា ក្នុងការស្វែងរកសាច់ញាតិក្រុមគ្រួសារប្រជាជនកម្ពុជា ដែលបានបាត់បង់ ឬព្រាត់ប្រាស់ដោយសារសង្គ្រាមនិងអំពើប្រល័យពូជសាសន៍ៗ មកទល់បច្ចុប្បន្ន អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ប្រមាណ ២៣០នាក់ បានដាក់ពាក្យស្វែងរកសាច់ញាតិតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា។*

*គួររំឭកថា ភាគច្រើននៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម គឺជាស្ត្រីនិងកុមារ។ ស្ត្រីកម្ពុជាបានខិតខំប្រឹងប្រែង ដោយមិនរួញរាក្នុងការស្តារ លើកស្ទួយនិងកសាងប្រទេសជាតិសាជាថ្មី តាមរយៈការចិញ្ចឹមបីបាច់គ្រួសារ ក្តាប់យកនិងពង្រីកឱកាសសេដ្ឋកិច្ចអភិរក្ស ការពារ និងពង្រឹងសហគមន៍ វប្បធម៌ និង*

ប្រទេសជាតិរបស់ខ្លួន ក្រោយពេលដែលរបបខ្មែរក្រហមបានដួលរលំទៅនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ស្ត្រីកម្ពុជា គឺជានិមិត្តរូបនៃដួងព្រលឹងជាតិកម្ពុជា។ បណ្ណាល័យសម្តេចម៉ែ បង្កើតឡើងដើម្បីឧទ្ទិសដល់ស្ត្រីកម្ពុជា ទាំងនៅក្នុងអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។























ប្រតិភូទាំង១៥រូប ទទួលបានការរាក់ទាក់រាក់ទាក់សូមស្វាគមន៍យ៉ាងកក់ក្តៅ និងបានទស្សនាពិព័រណ៍ព្រះឆាយាលក្ខណ៍សម្តេចព្រះបរមរតនកោដ្ឋនិងរាជវង្សានុវង្ស, ពិព័រណ៍នៃប្លង់រចនាអគារវិទ្យាស្ថានស្លឹករឹត ដែលគឺជាមជ្ឈ-មណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍ រចនាឡើងដោយលោកស្រី ហ្សាហា ហាឌីដ, បរិក្ខារតម្កល់ឯកសារ ព្រមទាំងទទួលជ្រាបព័ត៌មាននានាអំពីការិយាល័យនៅតាមបណ្តាខេត្តទាំង១០ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបង្ហាញដោយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងលោកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា។

នៅមុនពេលបញ្ចប់ ក្រុមប្រតិភូនិងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានពិភាក្សាលើប្រធានបទដ៏មានសារសំខាន់មួយចំនួនស្តីអំពីការលើកកម្ពស់តួនាទីនិងការផ្តល់ឱកាសដល់ស្ត្រីនៅក្នុងសង្គម។ កិច្ចពិភាក្សាក៏បានផ្តោតទៅលើគម្រោងបច្ចុប្បន្ននិងបន្តបន្ទាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជាគម្រោងលើកកម្ពស់សុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងគម្រោងជំរុញការចូលរួមរបស់ស្ត្រីនៅតាមសហគមន៍ដាច់ស្រយាលជាអាទិ៍ ព្រមទាំងកិច្ចសហការនាពេលអនាគតរវាងស្ថាប័នទាំងពីរ។

ទស្សនកិច្ចបានប្រព្រឹត្តទៅដោយរលូន និងក្នុងបរិយាកាសសោមនស្សរីករាយ។ ជាកិច្ចបញ្ចប់ លោកជំទាវ ពុំ ចន្ទីនី តំណាងឲ្យកាកបាទក្រហមកម្ពុជានិងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា បានចារចំណារអនុស្សាវរីយ៍លើសៀវភៅគ្រាំងមានរបស់ «បណ្ណាល័យសម្តេចម៉ែ» ដែលមានខ្លឹមសារដូចតទៅ៖







"ក្នុងនាមគណៈប្រតិភូ កាកបាទក្រហមកម្ពុជា ដែលបានមកធ្វើទស្សនកិច្ចនៅ «បណ្ណាល័យសម្តេចម៉ែ» នាថ្ងៃនេះ យើងខ្ញុំទាំងអស់គ្នាមានសេចក្តីកោតសរសើរ ចំពោះគំនិតផ្តួចផ្តើមនិងសមិទ្ធផលដែលបានស្រាវជ្រាវដ៏សម្បូរបែប ដើម្បីទុកជាប្រវត្តិសាស្ត្រសម្រាប់អនាគតកូនខ្មែរ រាប់ជំនាន់តទៅមុខទៀត កុំឱ្យភ្លេចនូវអតីតកាលដ៏ជូរចត់ ដ៏ខ្មៅងងឹតតែមួយនៅក្នុងប្រទេសកម្ពុជា។

នេះក៏ជាមេរៀនដកពិសោធន៍ឱ្យជំនាន់ក្រោយៗ ខិតខំ ដើម្បីថែរក្សាសន្តិភាព ស្ថេរភាពរបស់ប្រទេសជាតិតរៀងទៅ។

*ធ្វើនៅថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០២១*

*អគ្គលេខាធិការកាកបាទក្រហមកម្ពុជា*

**ពុំ ចន្នីនី**"

# ខ្មែរក្រហមធ្វើឱ្យខ្ញុំជាប់ឈ្មោះ មហាចោរ

*កែវ សុភី*

***«ពោត ស្ករស ក្ដាម បន្លែ ផ្លែឈើ សូម្បីតែសំបុត្ររបស់អង្គការហាមមិនឱ្យបើកមើលក៏ខ្ញុំលួចផាំងអស់។ រាល់ថ្ងៃនេះ អ្នកភូមិស្គាល់ខ្ញុំដោយសារតែប្រវត្តិជាចោររបស់អង្គការ និងហៅតៗគ្នាមកដល់សម័យនេះ ថា យាយមហាចោរ»*** ។

ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងាររបស់ការិយាល័យស្រាវជ្រាវ និងបណ្ណាល័យ ឯកសារខ្មែរក្រហមខេត្តតាកែវ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅជួបសម្ភាសន៍ជនរងគ្រោះនៃរបបខ្មែរក្រហម ក្រោមគម្រោងវេទិកាប្រវត្តិសាស្ត្រគ្រួសារ ក្នុងភូមិព្រៃកគាដ ឃុំគោកធ្លក ស្រុកអង្គរបុរី ខេត្តតាកែវ។ នៅពេលទៅដល់ក្នុងភូមិ ក្រុមការងារបានធ្វើការសាកសួរលោកយាយ លោកតា អ៊ំ ពូ មីង ដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម និងសុំអនុញ្ញាតឲ្យគាត់ចែករំលែករឿងរ៉ាវដែលគាត់ធ្លាប់ជួបប្រទះដល់ក្រុមការងារ និងក្មេងៗក្នុងភូមិ។ ក្រុមការងារបានជួបយាយ អៀម សៅ អាយុ៧១ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រៃកគាដ ឃុំគោកធ្លក ស្រុកអង្គរបុរី ខេត្តតាកែវ។ អៀម សៅ មានសម្បុរខ្មៅស្រអែម សក់រួញ មានរាងស្គមខ្ពស់។ អៀម សៅ បានផ្ដល់បទសម្ភាសន៍ដល់ក្រុមការងាររបស់នាងខ្ញុំ រួមជាមួយកាយវិការគ្រាប់របស់គាត់ដែលហាក់ដូចជារឿងរ៉ាវរបស់គាត់ក្នុងរបបខ្មែរក្រហមទើបនឹងកើតឡើងថ្មីៗ។ អៀម សៅ ត្រូវបានប្រជាជនក្នុងភូមិហៅឈ្មោះគាត់ថា «យាយមហាចោរ» ដែលជាប់ឈ្មោះរហូតមកដល់សព្វថ្ងៃនេះ។

អៀម សៅ បានរៀបរាប់ថា ខ្ញុំកើតនៅភូមិកំពង់ពោធិ៍ ឃុំអង្គរបុរី ស្រុកអង្គរបុរី ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ អៀម ញ៉ែង និងម្ដាយឈ្មោះ ចាន់ និងមានបងប្អូនបង្កើតចំនួន៤នាក់។ ខ្ញុំមានប្ដីឈ្មោះ ញ៉ែង ស្រ៊ិ និងមានកូនចំនួន៤នាក់ ប្រុស២នាក់ ស្រី២នាក់។



*អៀម សៅ បានផ្ដល់បទសម្ភាសន៍ដល់ក្រុមការងារគម្រោងវេទិកាប្រវត្តិសាស្ត្រគ្រួសារ នៅក្នុងភូមិព្រៃកគាដ ឃុំគោកធ្លក ស្រុកអង្គរបុរី ខេត្តតាកែវ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១។ (លី កុកឆាយ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

កាលពីក្មេងខ្ញុំបានរៀនត្រឹមថ្នាក់ទី ៩ ។ សម័យនោះឪពុករបស់ខ្ញុំមិនឲ្យកូនប្រុសទៅរៀនទេ ព្រោះខ្លាចកូនប្រុសមានសង្សារ ប៉ុន្តែគាត់យល់ព្រមឲ្យខ្ញុំទៅរៀន។

ខ្ញុំបានទៅរៀនភាសាខ្មែរនៅសាលាអង្គរបុរី ហើយឆ្លៀតពេលទំនេរខ្ញុំបានលួចរៀនភាសាវៀតណាម ដោយសារខ្ញុំចង់ចេះនិយាយភាសាវៀតណាម និងចង់មានមិត្តភក្តិជាជនជាតិវៀតណាម។ ក្រោយមកឪពុករបស់ខ្ញុំបានដឹងរឿងនេះ។ នៅពេលដែលឪពុករបស់ខ្ញុំស្រវឹងស្រា បានវាយធ្វើបាបខ្ញុំយ៉ាងខ្លាំងដោយសារតែខ្ញុំលួចទៅរៀនភាសាវៀតណាម ប៉ុន្តែអ្នកភូមិចូលមកជួយឃាត់។



វាលស្រែប្រាំងនៅក្នុងភូមិព្រែកតាផ ឃុំគោកធ្លក ស្រុកអង្គរបុរី ខេត្តតាកែវ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១។ (លី កុកឆាយ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្នកភូមិបានទិញស្រាឲ្យឪពុកខ្ញុំផឹកថែមទៀត ទើបគាត់ព្រមឈប់វាយខ្ញុំ។ ឪពុករបស់ខ្ញុំដឹងថា ខ្ញុំរៀនភាសាវៀតណាម ដោយសារសាលាតម្រូវឲ្យខ្ញុំស្លៀកពាក់ឯកសណ្ឋានប្រពៃណីវៀតណាម។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមចូលមកគ្រប់គ្រងប្រទេសកម្ពុជាទាំងស្រុង។ ក្រុមគ្រួសាររបស់ខ្ញុំស្ថិតក្នុងបញ្ជីក្បត់របស់អង្គការ ព្រោះមានសមាជិកក្នុងគ្រួសារជាទាហានធ្លាប់បម្រើការឲ្យរបប លន់ នល់។ អង្គការចាប់ផ្តើមជម្លៀសប្រជាជនពីទីក្រុងឲ្យមករស់ក្នុងភូមិ ចំណែកខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅលើកទំនប់ប្រឡាយនៅភ្នំបុរី។ ម្តាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅមើលក្មេងៗរបស់អង្គការនៅវត្តអកយំ ស្ថិតក្នុងឃុំព្រែកប្បាស ស្រុកព្រែកប្បាស ខេត្តតាកែវ ដោយខ្មែរក្រហមចោទគាត់ថាជាប់និន្នាការខ្លាំង ព្រោះមានកូនប្រុសជាគយ នៅក្នុងសម័យ



ព្រែកជីកភ្ជាប់ពីឃុំគោកធ្លក ស្រុកអង្គរបុរី ខេត្តតាកែវ ទៅប្រទេសវៀតណាម។ ក្រៅពីនេសាទត្រី និងទាញយកទឹកក្នុងព្រែកនេះមកបញ្ចូលស្រែប្រាំង ដាំដំណាំ និងប្រើប្រាស់ប្រចាំថ្ងៃ ប្រជាជនក្នុងឃុំគោកធ្លកបានប្រើប្រាស់ព្រែកជីកនេះសម្រាប់ធ្វើពាណិជ្ជកម្ម និងដឹកជញ្ជូនផលិតផលកសិកម្ម សម្ភារប្រើប្រាស់និងទំនិញផ្សេងៗរវាងប្រជាជនខ្មែរ និងវៀតណាម។ ថ្ងៃទី១៧ ខែកុម្ភៈឆ្នាំ២០២១។ (លី កុកឆាយ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

លន់ នល់ ។ ចំណែកខ្ញុំត្រូវបានខ្មែរក្រហមផ្លាស់ឲ្យទៅនៅភូមិផ្សេងៗ ខ្ញុំបានតបទៅអ្នកដែលមកជម្លៀសខ្ញុំថា ខ្ញុំសុំទៅយកខោអាវ ប៉ុន្តែខ្មែរក្រហមទាំងនោះប្រាប់ថាមិនបាច់យកទៅច្រើនទេ។ ពេលនោះខ្ញុំបានមកជួបនិយាយជាមួយម្តាយ ហើយគាត់ក៏ត្រូវបានជម្លៀសចេញទៅជាមួយខ្ញុំដែរ។ អង្គការបានឲ្យសំបុត្រមួយច្បាប់និងហាមមិនឲ្យខ្ញុំហែកសំបុត្រអានឡើយ គឺពេលទៅដល់គោលដៅ ចាំប្រគល់សំបុត្រនោះទៅថ្នាក់លើ។ ខ្ញុំគិតក្នុងចិត្តរួចហើយថា ប្រសិនបើមានឱកាសល្អ ខ្ញុំនឹងហែកសំបុត្ររបស់អង្គការអាន ទោះប្រឈមនឹងការស្លាប់ក៏ដោយ។ ខ្ញុំបានហែកសំបុត្រនោះដោយថ្នមៗនិងប្រុងប្រយ័ត្ន។ ពេលបើកសំបុត្រអានហើយ ទឹកភ្នែករបស់ខ្ញុំក៏ហូរមក ព្រោះមានពាក្យថា «ពេលទៅដល់យប់ឲ្យវាយយប់ ទៅដល់ថ្ងៃឲ្យវាយថ្ងៃ» ។ បន្ទាប់មក ខ្ញុំបិទសំបុត្រភ្ជិតឲ្យដូចដើមវិញដើម្បីកុំឲ្យមានការសង្ស័យ។ ខ្ញុំបានប្រាប់ម៉ែខ្ញុំថា កុំឲ្យទៅតាមខ្ញុំ បើទៅជាមួយខ្ញុំត្រូវអង្គការសម្លាប់ទាំងអស់គ្នា។ ពេលខ្ញុំយកសំបុត្រទៅដល់ខ្មែរក្រហមបានសួរថា មិត្តឯងហូបអីហើយឬនៅ?



*ផ្ទះរបស់ប្រជាជននៅក្នុងឃុំគោកធ្លក ស្រុកអង្គរបុរី ខេត្តតាកែវ។ (លី កុកឆាយ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*



*វត្តកំពង់ហ្លួង ក្នុងឃុំអង្គរបុរី ស្រុកអង្គរបុរី ខេត្តតាកែវ។ (លី កុកឆាយ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

តើគេឲ្យមិត្តឯងមកធ្វើអី? ពេលនោះខ្ញុំឆ្លើយថា មិនដឹងដែរមិនដឹងអង្គការឲ្យខ្ញុំមកធ្វើអីទេ ប៉ុន្តែខ្ញុំឆ្លើយទាំងភ័យញាក់ញ័រ។ ខ្មែរក្រហមនៅទីនោះបានចោទខ្ញុំថា ខ្ញុំមានជាប់និន្នាការក្បត់ ប៉ុន្តែខ្ញុំបាននិយាយបដិសេធ និងបានតបទៅវិញថាខ្ញុំអត់ដឹងនិន្នាការអ៊ីទេ។ ប្រហែលជាម៉ោង៨ល្ងាច ខ្មែរក្រហមឲ្យខ្ញុំហូបបបរ ហើយឲ្យខ្ញុំទៅរកកន្លែងសម្រាក។ រយៈពេល៣ថ្ងៃក្រោយ ខ្មែរក្រហមបានសួរខ្ញុំថា មានដឹងទេថាគេឲ្យមិត្តឯងមកធ្វើអ៊ីទេ? ពេលនោះខ្ញុំបានឆ្លើយថា ខ្ញុំអត់ដឹងទេ ព្រោះខ្ញុំអត់ចេះអក្សរ។ ខ្មែរក្រហមបានចោទខ្ញុំថា ខ្ញុំខសង្សារហ៊ឺឈីញឹកញាប់ មានជាប់ពាក់ព័ន្ធនិន្នាការក្បត់ និងហៀបយកខ្ញុំទៅវាយចោល៣ទៅ៤លើក។ ខ្មែរក្រហមបានចោទខ្ញុំបន្ថែមទៀតថា បងស្រីខ្ញុំយកប្ដីធ្វើគយ។ ពេលនោះ ប្រសិនបើខ្មែរក្រហមដឹងថាក្មួយរបស់ខ្ញុំឈ្មោះ អាហ៊ុ ត្រូវជាកូនមន្ត្រីគយ ខ្មែរក្រហមនឹងយកវាទៅសម្លាប់ចោលហើយ ប៉ុន្តែពេលនោះខ្មែរក្រហមសួរខ្ញុំថា អាហ៊ុហ្នឹងត្រូវជាអ៊ី? ខ្ញុំបានកុហកអ្នកសួរចម្លើយនោះថា ខ្ញុំត្រូវជាម្ដាយរបស់វា។ ទោះបីយ៉ាងណានៅពេលនោះក្មួយរបស់ខ្ញុំ នៅតែហៅថាខ្ញុំមីង១ ព្ធដូច្នេះខ្ញុំបាន ក្ដិច មួល វាយ ទាញថ្ពាល់ក្មួយឲ្យហៅខ្ញុំថាម៉ែជំនួសវិញ។។

ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យលើកទំនប់ និងរែកដីរហូតចប់ការងារទើបអនុញ្ញាតឲ្យហូបបបរ។ នាពេលនោះ ខ្មែរក្រហមសង់រោងសម្រាប់កងពិសេសនារី និងកងបុរស នៅតាមសហករណ៍ផ្សេងៗគ្នា។ នៅវេលាម៉ោង១២ថ្ងៃត្រង់ អង្គការបានវាយជួងហៅកងនារី និងបុរសមកហូបរួមគ្នា ហើយក៏បំបែកជួរគ្នាឲ្យទៅធ្វើការរៀងៗខ្លួន។ សមាជិកកងម្នាក់បានបបររាវៗមួយវែក ប៉ុន្តែប្រសិនបើនរណាធ្វើការខ្លាំង គឺទទួលបានបបរមួយវែកកន្លះ បើនរណាធ្វើការងារខ្សោយ គឺទទួលបានតែទឹកបបរប៉ុណ្ណោះ។ ខ្ញុំវេទនាខ្លាំងណាស់ ប៉ុន្តែមិនដែលហ៊ាននិយាយទេ។ ខ្ញុំហូបអ៊ីៗគ្រប់យ៉ាងដែលខ្មែរក្រហមផ្ដល់ឲ្យ។ យូរៗខ្មែរក្រហមហៅខ្ញុំទៅប្រជុំម្ដង ហើយបានសួរថា សមមិត្តយើងហូបគ្រាន់ទេ? ខ្ញុំបានឆ្លើយថា គ្រប់គ្រាន់ បើសិនឆ្លើយថាមិនគ្រប់ ខ្មែរក្រហមនឹងយកយើងទៅកសាងមិនខាន។ ប្រសិនបើយើងខ្សឹបខ្សៀវថាហូបមិនគ្រប់ ហើយខ្មែរក្រហមដឹងក៏នឹងយកយើងទៅរៀនសូត្រដែរ។ ទោះបីម្ហូបឆ្ងាញ់ ឬមិនឆ្ងាញ់ ក៏ខ្ញុំ



ទ្រាំហូបដែរ។ ថ្ងៃមួយពេលខ្ញុំឃ្លានខ្លាំងពេក ខ្ញុំបានដាច់ចិត្តទៅលួចកាច់ពោតក្នុងចម្ការដែលស្ថិតនៅប្រឡាយលេខ១១២ ។ ពេលដែលខ្ញុំចូលក្នុងចម្ការពោត ខ្ញុំសម្លឹងមើលសព្វគ្រប់លោមានឈ្លបខ្មែរក្រហម បន្ទាប់មកខ្ញុំចាប់ផ្តើមកាច់យកផ្លែពោតធំៗ។ ខ្ញុំកាច់យកតែសាច់ពោតខាងក្នុង ចំណែកសម្បក គឺខ្ញុំទុកនៅលើដើមពោតដដែល។ ខ្ញុំរៀបចំសម្បកពោតឲ្យដូចដើមដែលសម្លឹងមើលពីខាងក្រៅដូចមានសាច់នៅខាងក្នុង។ ខ្ញុំយកសាច់ពោតមកមូរនិងចង្កេះខោបានប្រហែល២០ផ្លែ។ ខ្ញុំគិតក្នុងចិត្ត ប្រសិនបើខ្មែរក្រហមចាប់ខ្ញុំបានហើយសម្លាប់ចោល ក៏ស្លាប់ទៅចុះ។ ខ្ញុំបានលួចកាច់ពោតរបស់ខ្មែរក្រហមជាច្រើនដង។ ក្រោយមក អង្គការបានចាត់តាំងប្រជាជននៅក្នុងកងទៅកាច់ពោត នៅក្នុងចម្ការដោយក្នុងមនុស្សម្នាក់ត្រូវកាច់ពីរជួរ។ ខ្ញុំធ្លាប់បានលួចក្នុងចម្ការនោះ ទើបខ្ញុំដឹងថា ជួរណាដែរខ្ញុំធ្លាប់បានកាច់ ហើយខ្ញុំក៏សុំទៅកាច់ជួរនោះ ព្រោះប្រសិនបើឲ្យអ្នកផ្សេងចូលទៅកាច់ជួរដែលខ្ញុំធ្លាប់លួចកាច់ប្រាកដជាដឹងរឿងថាបាត់ពោត។

ក្រោយមក មានបុរសម្នាក់ឈ្មោះ មឿន បានលួចចូលទៅកាច់ពោតនៅក្នុងចម្ការពោតនោះដែរ ហើយបានឃើញខ្ញុំកំពុងលួចពោត។ ពេលនោះ មឿនបានរត់ទៅប្រាប់ប្រធានកងថា ខ្ញុំលួចពោត។ ប្រធានកងបានឲ្យឈ្លបវាយខ្ញុំស្ទើរស្លាប់។ ឈ្លបដែលវាយខ្ញុំបាននិយាយថា “ដោយសារឃើញខ្ញុំវ័យចាស់ទេ ទើបគេអត់ឱនឲ្យ”។ ពេលខ្ញុំឃើញ មឿន ម្តងៗខ្ញុំស្អប់រហូតដល់សព្វថ្ងៃ។

ក្រោយមក ប្រធានកងបានចាត់តាំងខ្ញុំឲ្យទៅស្ទូងនៅក្នុងស្រែ ដែលមានសត្វឈ្លើងធំៗជាច្រើន។ ប្រធានកងបាននិយាយថា ក្នុងចំណោមសមាជិកកង ៥នាក់ ត្រូវស្ទូងស្រូវឲ្យហើយ។ ពេលនោះមានសមាជិកកង៤នាក់ បានខ្លាចឈ្លើង ហើយរត់ឡើងលើភ្លឺស្រែអស់នៅសល់តែខ្ញុំម្នាក់ប៉ុណ្ណោះ ហើយបើខ្ញុំស្ទូងមិនហើយ ចុងភៅក៏មិនបើករបបឲ្យដែរ។ ខ្ញុំបានមូរជើងខោចុះស្ទូងតែម្នាក់ឯង។ នៅទីនោះ ឈ្លបក៏បម្រុងនឹងយកខ្ញុំទៅសម្លាប់ដែរ ប៉ុន្តែមេភូមិបានអាណិតខ្ញុំ ហើយទៅជួយអង្វរករទើបឈ្លបលើកលែង។ បន្ទាប់មកខ្មែរក្រហមបានបញ្ជូនខ្ញុំទៅដកសំណាបនៅថ្មសរ។ ពេលនោះខ្មែរក្រហម បានចាត់ឲ្យខ្ញុំទៅធ្វើការនៅខាងរោងបាយសហករណ៍វិញ។ ខ្ញុំបានប្រទះឃើញថង់មួយនៅទីនោះ ខ្ញុំស្មានតែស្ករស ក៏បានលួចយកមកដាក់ក្នុងខោជើងអាវរហូតដល់ពេញ ដើម្បីទុកសម្រាប់ហូបបំបាត់ភាពស្រេកឃ្លាន។ ខ្ញុំដើរលបៗដោយទឹកមុខញញឹម រួចយកស្ករសដាក់ចូលមាត់។ ខ្ញុំគិតថា នឹងបានផ្អែមមាត់ម្តង ប៉ុន្តែស្រាប់តែខុសផ្ទុយពីការគិត ព្រោះស្ករសប្រែជាជីអ៊ុយរ៉េ មានជាតិជូរ និងត្រជាក់ៗដែលពិបាកនឹងលេប។ ដោយសារការស្រេកឃ្លាន ខ្ញុំចាប់ផ្តើមលួចអ្វីៗក៏ដោយឲ្យតែអាចហូបបានដើម្បីបំពេញក្រពះ និងអាចរក្សាជីវិតបានរហូតមកដល់សព្វថ្ងៃ។

# ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកទស្សនកិច្ច មជ្ឈមណ្ឌលឯកសារកោះថ្មខេត្តត្បូងឃ្មុំ

ឡុង ដានី



ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាលោក ប៉ាទ្រីក មូហ្វី និងគណៈប្រតិភូបានមកធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅវេលាម៉ោង១១ព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង១១ព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាលោក ប៉ាទ្រីក មូហ្វី (Patrick Murphy) និងគណៈប្រតិភូបានមកធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ខេត្តត្បូងឃ្មុំ។

ដើម្បីអនុវត្តវិធានការរបស់ក្រសួងសុខាភិបាល គណៈប្រតិភូ និងអ្នកចូលរួមទាំងអស់បានពាក់ម៉ាស់ លាងដៃជាមួយអាកុល និងរក្សាគម្លាត ដើម្បីការពារការឆ្លងរាលដាលជំងឺកូវីដ១៩។ ចូលរួមទទួលស្វាគមន៍លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក និងគណៈប្រតិភូរួមមាន៖ លោក ញឹក នៅ អភិបាលរងនៃគណៈអភិបាលស្រុកមេមត់ ខេត្តត្បូងឃ្មុំ លោកដេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំប្រល័យពូជសាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឡុង ដានី អ្នកគ្រប់គ្រងនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សចំនួន២៥រូប។ មុនការអញ្ជើញមកដល់របស់លោកឯកអគ្គរដ្ឋទូតអាមេរិក និងគណៈប្រតិភូ លោក ញឹក នៅ បានមានមតិផ្តាំផ្ញើរដល់សិស្សានុសិស្ស ឲ្យស្វែងយល់បន្ថែមអំពីព្រឹត្តិការណ៍






ពិព័រណ៍រូបថតនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រវត្តិសាស្ត្រដែលបានកើតឡើងនៅតំបន់កោះថ្ម ស្រុកមេមត់ និងសូមឲ្យសួរសំណួរច្រើនចំពោះលោកឯកអគ្គរដ្ឋទូត។ បន្ទាប់មកលោក ដេង ពង្សរ៉ាស៊ី បានធ្វើការពន្យល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ជាពិសេសបានបង្ហាញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៦០ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០ ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សទាំងអស់។

នៅពេលលោកឯកអគ្គរដ្ឋទូត និងគណៈប្រតិភូអញ្ជើញមកដល់ លោកដេង ពង្សរ៉ាស៊ី និងលោក ឡុង ដានី បានធ្វើមគ្គុទ្ទេសក៍ក្នុងការនាំលោកឯកអគ្គរដ្ឋទូត និងគណៈប្រតិភូដើរទស្សនាការតាំងពិព័រណ៍នៃបណ្តុំរូបថត ដែលបន្សល់ទុកពីទសវត្សរ៍ឆ្នាំ១៩៦០ ដល់ទសវត្សរ៍ឆ្នាំ១៩៩០។ រូបថតទាំងអស់នោះបានបង្ហាញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជាដោយចាប់ផ្តើមចេញពីតំបន់កោះថ្ម ឃុំទន្លូង និងតំបន់មួយចំនួននៃឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ រូបថតនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលបានធ្វើឲ្យប្រជាជនកម្ពុជាប្រមាណ ២លាននាក់ បានស្លាប់។ រូបថតភស្តុតាងមួយចំនួនអំពីបទឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមមកលើប្រជាជនកម្ពុជា។ រូបគំនូរបង្ហាញអំពីដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ និងចុងក្រោយគឺរូបថតស្តីអំពីការផ្តួចផ្តើមបង្កើតគោលនយោបាយឈ្នះឈ្នះរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ និងការទទួលបានសន្តិភាពពេញលេញនៅក្នុងឆ្នាំ១៩៩៨។

ជាចុងក្រោយលោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកបានមានមតិសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សទាំង២៥រូប លោកឯកអគ្គរដ្ឋទូតមានប្រសាសន៍ថា លោកមានការរីករាយ ដែលបានមកទស្សនកិច្ចនៅខេត្តត្បូងឃ្មុំ និងមជ្ឈមណ្ឌលឯកសារកោះថ្ម ជាពិសេសបានជួបជាមួយលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សនៅទីនេះ។ លោកឯកអគ្គរដ្ឋទូតបានបន្ថែមថា សហរដ្ឋអាមេរិកបានផ្តល់ជំនួយច្រើនដល់ប្រទេសកម្ពុជា និងខេត្តត្បូងឃ្មុំជាពិសេសទាក់ទងនឹងវិស័យអប់រំ កសិកម្ម បរិស្ថាន និងសុខាភិបាល។ សហរដ្ឋអាមេរិកក៏បានផ្តល់ជំនួយគាំទ្រជាច្រើនឆ្នាំ ដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីឲ្យយុវជនជំនាន់ក្រោយ បានយល់ច្បាស់អំពីប្រវត្តិសាស្ត្រ និងទប់ស្កាត់កុំឲ្យរបបប្រល័យពូជសាសន៍កើតឡើងម្តងទៀត។ បន្ទាប់មកលោកឯកអគ្គរដ្ឋទូតបានផ្តល់ឱកាសឲ្យលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សសួរសំណួរមួយចំនួនពាក់ព័ន្ធនឹងព័ត៌មានផ្ទាល់ខ្លួន អំពីគោលបំណង និងការបំពេញបេសកកម្មរបស់លោកនៅប្រទេសកម្ពុជា។ លោក

ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកបានមានប្រសាសន៍ថា លោកបានកើតនៅអំឡុងពេលសង្គ្រាមវៀតណាម ដែលប្រទេសកម្ពុជាបានទទួលរងផលប៉ះពាល់ពីសង្គ្រាមនោះដែរ។ លោកបានបន្ថែមថា លោកមានសាច់ញាតិបានបាត់បង់ជីវិតនៅក្នុងសង្គ្រាមវៀតណាម។ លោកមានប្រសាសន៍ថា លោកស្រឡាញ់ប្រទេសកម្ពុជា ស្រឡាញ់ប្រជាជនកម្ពុជា ស្រឡាញ់អាកាសធាតុ បរិស្ថាន និងម្ហូបអាហារ។ លោកក៏បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជាចំពោះការសហការយ៉ាងល្អ ក្នុងការស្វែងរកអដ្ឋិធាតុទាហានសហរដ្ឋអាមេរិកដែលបានបាត់ខ្លួននៅក្នុងប្រទេសកម្ពុជាក្នុងសម័យសង្គ្រាមវៀតណាម។ មកដល់ពេលនេះ នៅមានទាហានសហរដ្ឋអាមេរិកចំនួន ៤២នាក់ទៀត ដែលមិនទាន់រកឃើញអត្តសញ្ញាណ។

នៅអំឡុងឆ្នាំ១៩៧០ ទាហានសហរដ្ឋអាមេរិក និងទាហានវៀតកុងបានចូលមកដល់ប្រទេសកម្ពុជា។ នៅពេលនោះទាហានសហរដ្ឋអាមេរិកបានបោះទីតាំងនិងសង់



ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា លោក ប៉ាទ្រីក មូហ៊ី និងគណៈប្រតិភូបានមកធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ នៅវេលាម៉ោង១១ព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



*សិស្សានុសិស្ស ទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកោះថ្ម ក្នុងភូមិកោះថ្ម ឃុំទន្ទឹង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយមានលោក ផេង ពង្សរ៉ាស៊ី បានធ្វើការពន្យល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម រួមទាំងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់ពីទសវត្សរ៍ឆ្នាំ១៩៦០ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០។ (សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*











បន្ទាយនៅក្នុងភូមិកោះថ្ម ភូមិពងទឹក ឃុំទន្លូង និងទីតាំងផ្សេងៗទៀតនៅក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងស្រុកស្នួល នៃខេត្តក្រចេះ គឺដើម្បីប្រយុទ្ធជាមួយកងទ័ពវៀតកុងដែលបានឆ្លងដែនចូលមកក្នុងទឹកដីប្រទេសកម្ពុជា។ ការប្រយុទ្ធគ្នារវាងទាហានសហរដ្ឋអាមេរិក និងកងទ័ពវៀតកុងបានបណ្តាលឲ្យខទ្ធម្ភាគចក្រនៃទាហានសហរដ្ឋអាមេរិក យ៉ាងតិចចំនួន៣គ្រឿងបានធ្លាក់នៅទឹកដីនៃឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខទ្ធម្ភាគចក្រនៃទាហានសហរដ្ឋអាមេរិកដែលធ្លាក់មានដូចខាងក្រោម៖

១) ខទ្ធម្ភាគចក្រ (AH-1G) របស់ទាហានអាមេរិកបានធ្លាក់នៅចម្ងាយ១០០ម៉ែត្រ ប៉ែកខាងលិចភូមិដង្ខិត ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខទ្ធម្ភាគចក្រនេះបានធ្លាក់នៅក្នុងថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៧០។

២) ខទ្ធម្ភាគចក្រស្ទាបពីររបស់ទាហានអាមេរិកបានធ្លាក់នៅខាងជើងភូមិដង្ខិត ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ក្នុងឆ្នាំ១៩៧០។

៣) ខទ្ធម្ភាគចក្រ (OH-6) របស់ទាហានអាមេរិកបានធ្លាក់នៅក្បែរត្រពាំងមួយក្នុងភូមិរបងច្រុះ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ក្នុងឆ្នាំ១៩៧០។ ខទ្ធម្ភាគចក្រនេះបានធ្លាក់នៅចម្ងាយប្រហែល ៥០០ម៉ែត្រ ប៉ែកខាងជើងព្រំដែន កម្ពុជា - វៀតណាម ក្នុងទឹកដីកម្ពុជា ។

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ក៏មានមូលដ្ឋានកងទ័ពវៀតកុងស្ថិតនៅចម្ងាយប្រហែល ១៥០០ម៉ែត្រប៉ែកខាងជើងភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំដែរ។ មូលដ្ឋានកងទ័ពវៀតកុងនេះមានមន្ទីរពេទ្យធំមួយ និងមានឃ្លាំងសម្ភារភស្តុភារមួយ។ មូលដ្ឋានកងទ័ពវៀតកុងនេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៦ និងបានដំណើរការរហូតដល់ឆ្នាំ១៩៦៩។ មេបញ្ជាការមូលដ្ឋានកងទ័ពវៀតកុងនេះមានឈ្មោះ ស៊ិន មកពីវៀតណាម ខាងជើង និងចេះនិយាយភាសាខ្មែរ។ ស៊ិន បានរៀបការជាមួយនារីខ្មែរ ខណៈពេលដែលមូលដ្ឋានកងទ័ពវៀតកុងនេះស្ថិតភូមិគ្រៀង ឬភូមិក្បាលគ្រៀង។ ក្នុងឆ្នាំ១៩៦៩ ប្រពន្ធរបស់ ស៊ិន ត្រូវគ្រាប់រ៉ែកែត និងរបួស។ បន្ទាប់មកប្រពន្ធគាត់ត្រូវបានដឹកយកទៅមន្ទីរពេទ្យ។ នៅមន្ទីរពេទ្យនោះមានវេជ្ជបណ្ឌិត មានគ្រែដេក និងកន្លែងជាំបាយច្រើនកន្លែង។ យូៗម្តងប្រជាជនដែលរស់នៅក្បែរមូលដ្ឋានកងទ័ពវៀតកុងនេះ ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកម្មវិធីជប់លៀងនៅក្នុងមូលដ្ឋានកងទ័ពវៀតកុងនេះដែរ។ ក្នុងឆ្នាំ១៩៦៩ ទាហានអាមេរិកបានទម្លាក់គ្រាប់បែកប៊េ-៥២លើមូលដ្ឋានកងទ័ពវៀតកុងនេះ ដែលបណ្តាលឲ្យមនុស្សជាច្រើនបានស្លាប់។

ចំណែកទីតាំងមូលដ្ឋានកងទ័ពវៀតកុងមួយកន្លែងទៀត ស្ថិតនៅចម្ងាយប្រហែល៧គីឡូម៉ែត្រប៉ែកខាងត្បូងសានភូមិសាទុំ ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ទីតាំងមូលដ្ឋានកងទ័ពវៀតកុងនេះស្ថិតនៅជិតបូសសីពួរភូមិស្នួល និងព្រៃផ្លាវ។ ទីតាំងនេះស្ថិតនៅចម្ងាយប្រហែល ១គីឡូម៉ែត្រពីព្រំដែនកម្ពុជា - វៀតណាម។ ទីតាំងមូលដ្ឋានកងទ័ពវៀតកុងនេះ ក៏ប្រហែលជាមន្ទីរ១០០ ដែល ប៉ុល ពត និងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមផ្សេងៗទៀតបានមកស្នាក់នៅជាលើកដំបូងក្នុងចន្លោះពីឆ្នាំ១៩៦៣ ដល់ឆ្នាំ១៩៦៥។



ផ្លូវលំក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ
(សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



សាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុន សែន កោះថ្ម ក្នុងភូមិកោះថ្ម ឃុំកោះថ្ម ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(សុខ វណ្ណៈ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឯកអគ្គរាជទូតអូស្ត្រាលីទស្សនកិច្ច មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

*សោម ប៊ុនថន*





ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា លោក បាប្លូ កាវង់ និងអ្នកឧកញ៉ា សៀ ឬទ្ធី បានអញ្ជើញទស្សនាមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង សារមន្ទីរប្រវត្តិសាស្ត្រអន្លង់វែង ឬសារមន្ទីរអតីតផ្ទះតាម៉ុក និងទីតាំងបូជាសព ប៉ុល ពត នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១។
(ស្ងួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១ ឯកឧត្តម បាប្លូ កាវង់ ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញមកទស្សនកិច្ចតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ព្រមទាំងជួបសំណេះសំណាលជាមួយ លោក ហោ ជិនវិរយុទ្ធ អភិបាលនៃគណៈអភិបាលស្រុកអន្លង់វែង។ ស្រុកអន្លង់វែង គឺជាអតីតតំបន់តស៊ូចុងក្រោយនៃចលនាខ្មែរក្រហមនេះ ដែលបានធ្វើសមាហរណកម្មចូលមកក្នុងរាជរដ្ឋាភិបាលវិញ កាលពីឆ្នាំ១៩៩៨។

ឯកឧត្តម បាប្លូ កាវង់ និងគណៈប្រតិភូ ដែលរួមមានអ្នកឧកញ៉ា សៀ ឬទ្ធី បានអញ្ជើញមកដល់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានទទួលស្វាគមន៍ និងធ្វើជាមគ្គុទ្ទេសក៍ក្នុងដំណើរទស្សនកិច្ចនេះ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងមានតម្កល់ឯកសារចំនួនប្រមាណជិត៧ម៉ឺនទំព័រ ដោយរាប់ចាប់តាំងពីឯកសារទូរលេខ របាយការណ៍ ចម្លើយសារភាព និងប្រវត្តិរូបនៃអតីតសមាជិកខ្មែរក្រហមនៅក្នុងតំបន់សៀមរាប-ឧត្តរមានជ័យ ដែលបន្សល់ទុកពីជំនាន់ខ្មែរក្រហម(១៩៧៥-១៩៧៩ ព្រមទាំងបទសម្ភាសន៍ជាច្រើនទៀត។

បន្ទាប់មក ឯកឧត្តម ឯកអគ្គរាជទូត និងគណៈប្រតិភូក៏បានបន្តដំណើរទៅកាន់សារមន្ទីរប្រវត្តិសាស្ត្រអន្លង់វែង ឬសារមន្ទីរអតីតផ្ទះតាម៉ុក ដែលមានដាក់តាំងនូវវត្ថុតាងមួយចំនួនរួមមាន៖ អតីតរថយន្តវិទ្យុផ្សាយសំឡេងចល័តរបស់ខ្មែរក្រហមនិងទ្រុងដែកដាក់អ្នកទោស ពិព័រណ៍រូប

ថតប្រវត្តិសាស្ត្រនៃរបបសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥) និងរបបកម្ពុជាប្រជាធិបតេយ្យ ឬខ្មែរក្រហម (១៩៧៥-១៩៧៩) ព្រមទាំងកម្រងរូបថតដែលបង្ហាញពីជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជននិងកងទ័ពខ្មែរក្រហមនៅក្នុងតំបន់អន្លង់វែង កាលពីមុនឆ្នាំ១៩៩៨។ សារមន្ទីរប្រវត្តិសាស្ត្រអន្លង់វែង ឬសារមន្ទីរអតីតផ្ទះតាម៉ុក ដែលហ៊ុមព័ទ្ធដោយផ្ទៃបឹងអូរជីកទំហំ៤១៧ហិកតានេះ បានក្លាយជាចំណុចទាក់ទាញបំផុតសម្រាប់ទេសចរជាតិនិងអន្តរជាតិ។

ទីតាំងបូជាសព ប៉ុល ពត និងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៅលើខ្នងភ្នំដងរែកបានក្លាយជាគោលដៅទស្សនកិច្ចដ៏សំខាន់មួយទៀត។ ឯកអគ្គរាជទូតនិងគណៈប្រតិភូ បានចូលទស្សនាពិព័រណ៍រូបថត នៅក្នុងអតីតផ្ទះប្រជុំរបស់អតីតមេដឹកនាំកំពូលរបស់ចលនាខ្មែរក្រហម។ បច្ចុប្បន្ននេះ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានប្រែក្លាយទីតាំងនេះឲ្យទៅជាថ្នាក់រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង។

ឯកឧត្តម ឯកអគ្គរាជទូត និងគណៈប្រតិភូ បានស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម និងសក្តានុពលទេសចរណ៍ប្រវត្តិសាស្ត្រ។ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បាននិងកំពុងសហការផ្ទាល់ជាមួយ លោក ហោ ជិន វិរយុទ្ធ អភិបាលនៃគណៈអភិបាលស្រុកអន្លង់វែង និងថ្នាក់ដឹកនាំឃុំទាំង ៥ របស់លោកដែរ ដើម្បីបណ្តុះបណ្តាលយុវជននៅតាមឃុំនីមួយៗអំពីការបង្កើត និងគ្រប់គ្រងគេហទំព័រទេសចរណ៍ឃុំ និងការផ្តួចផ្តើមឲ្យមានសកម្មភាពកីឡានៅតាមឃុំជារៀងរាល់ខែ។ លោក អ៊ុច ផា ប្រធានឃុំថ្លាត បានមានប្រសាសន៍ថា៖ «**ខ្ញុំពិតជាគាំទ្រគំនិតផ្តួចផ្តើមនេះ ព្រោះថានេះគឺជាឱកាសល្អក្នុងការបណ្តុះបណ្តាលយុវជននៅតាមឃុំអំពីព័ត៌មានវិទ្យា និងប្រវត្តិសាស្ត្រ ដើម្បីទាក់ទាញទេសចរជាតិ។**»





















# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល៖

truthchenda.s@dccam.org

សូមអរគុណ!












# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

ដារ៉ាវឌ្ឍ មេត្តា

(តពីលេខមុន)

**៣៦៩.** *មន្ទីរស-៧១ ក៏មានអំណាចក្នុងការចាប់ខ្លួននិងបញ្ជូនអ្នកដែលបានចាប់ខ្លួនទៅកាន់មន្ទីរសន្តិសុខស-២១ផងដែរ។ ក្នុងឆ្នាំ១៩៧៨ ឈឹម សំអោក ហៅ ប៉ង់ ខ្លួនឯងក៏ត្រូវបានគេចាប់ខ្លួននិងបញ្ជូនទៅមន្ទីរសន្តិសុខស-២១ ផងដែរចំណែកឯអនុប្រធានរបស់គាត់ ខាន់ លី ហៅ កែន បានបន្តគ្រប់គ្រងដឹកនាំមន្ទីរស-៧១នេះ។ ប៉ង់ ត្រូវបានគេធ្វើជាទារុណកម្មយ៉ាងយូរ ដើម្បីបង្ខំឲ្យឆ្លើយសារភាព ក្រោយមក ឌុច បានបញ្ជាឲ្យគេយក ប៉ង់ ទៅសម្លាប់តាមការណែនាំរបស់ នួន ជា។*

### ៥.១.៧. អង្គភាព ភូមិភាគ តំបន់ ស្រុក និងឃុំ

**៣៧០.** *កម្ពុជាប្រជាធិបតេយ្យត្រូវបានបែងចែកជាតំបន់រដ្ឋបាលជាច្រើនទៅតាមឋានានុក្រម រួមមាន ភូមិភាគ តំបន់ស្រុក និងឃុំ។ កាលដំបូងភូមិភាគត្រូវបានបង្កើតឡើងដោយ ប.ក.ក. នៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធនៅមុនឆ្នាំ១៩៧៥។ ដំបូងឡើយកម្ពុជាប្រជាធិបតេយ្យមានភូមិភាគចំនួន៦គឺ៖ ភូមិភាគឧត្តរ(លេខកូដ៣០៤) ភូមិភាគពាយព្យ(លេខកូដ៥៦០) ភូមិភាគឦសាន (លេខកូដ១០៨ ក្រោយមកប្តូរជា១០៩) ភូមិភាគនិរតី (លេខកូដ៤០៥) ភូមិភាគបូព៌ា(លេខកូដ២០៣) និងភូមិភាគពិសេស (ដែលរួមទាំងតំបន់នៅជុំវិញទីក្រុងភ្នំពេញ)។*

**៣៧១.** *ក្រោយពីចូលកាន់កាប់ក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៧៥ ព្រំប្រទល់ភូមិភាគត្រូវបែងចែកជាថ្មីឡើងវិញ។ ភូមិភាគបស្ចិមថ្មី(លេខកូដ៤០១) ត្រូវបានបង្កើតបន្ថែម ហើយភូមិភាគពិសេសនៅជុំវិញទីក្រុងភ្នំពេញត្រូវបានរំលាយចោល និងកាត់បញ្ចូលទៅក្នុងភាគជិតខាងផ្សេងៗ។ ភូមិភាគទាំងអស់មិនបានកំណត់យកព្រំប្រទល់ខេត្ត ដែលមានស្រាប់ឲ្យបានជាក់លាក់នោះទេ។ ឧទាហរណ៍ ភូមិភាគបូព៌ា រួមមានខេត្តព្រៃវែង ស្វាយរៀង និងផ្នែកខ្លះនៃខេត្តក្រចេះ កណ្តាល និង កំពង់ចាម។*

**៣៧២.** *ភូមិភាគនីមួយៗត្រូវបានបែងចែកនៅក្នុងតំបន់មួយចំនួន ដែលត្រូវបានគេស្គាល់ជាទូទៅតាមរយៈលេខកូដរបស់តំបន់ទាំងនោះ។ តំបន់ត្រូវបានបែងចែកបន្តទៅស្រុក ហើយស្រុកត្រូវបានបែងចែកទៅជាអង្គភាពឃុំ ក្នុងនោះរួមមានទាំងភូមិ។ ភូមិនីមួយៗនៅក្នុងឃុំ ត្រូវបានដាក់បញ្ចូលគ្នាជាបន្តបន្ទាប់ទៅជាសហករណ៍ដែលជាកន្លែងប្រជាជនរស់នៅ ធ្វើការងារ និងហូបរួមគ្នា។ នៅកន្លែងខ្លះ សហករណ៍ត្រូវបានចាត់ទុកជាអង្គភាពចំណុះរបស់ឃុំ ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការឃុំ។ ប៉ុន្តែនៅកន្លែងខ្លះទៀត សហករណ៍ធំត្រូវដាក់ជំនួសឃុំ ដែលជាតំបន់រដ្ឋបាលថ្នាក់ក្រោមបំផុត នៅក្នុងឋានានុក្រមរបស់ ប.ក.ក.។*

**៣៧៣.** *ឋានានុក្រមគ្រប់កម្រិតទាំងអស់ដែលមានភូមិភាគតំបន់ស្រុកឃុំនិងសហករណ៍ត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការរបស់បក្ស។ ជាធម្មតា គណៈកម្មាធិការមានលេខាមួយរូប (ឬប្រធាន) អនុលេខាមួយរូប (ឬអនុប្រធាន) និងយ៉ាងហោចណាស់ក៏មានសមាជិកមួយរូបទៀតសំខាន់ៗត្រូវបានផ្តល់ទៅឲ្យសមាជិកគណៈកម្មាធិការ ឬ អនុគណៈកម្មាធិការថ្នាក់លើបន្ទាប់។ ឧទាហរណ៍ លេខាឃុំត្រូវតែងតាំងដោយគណៈកម្មាធិការស្រុក ហើយលេខាស្រុកត្រូវតែងតាំងដោយគណៈកម្មា-*

ធិការតំបន់ៗ ជាគោលការណ៍ លក្ខន្តិកៈ ប.ក.ក. បាន កំណត់ឲ្យគណៈកម្មាធិការទាំងអស់ធ្វើការប្រជុំនៅក្នុង ចន្លោះពេលមួយទៀងទាត់ដើម្បីជ្រើសរើសសមាជិកថ្មី ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង សមាជិកគណៈកម្មា-ធិការ (ដូចជាលេខា) ជាទូទៅត្រូវបានតែងតាំងដោយ គណៈកម្មាធិការថ្នាក់លើបន្ទាប់ៗ

**៣៧៤.** ជាទូទៅ លេខាគណៈកម្មាធិការនៅតាមថ្នាក់ នីមួយៗក៏ជាសមាជិកមួយរូបផងដែរ (ប្រយ៉ាងហោច ណាស់បានចូលរួមប្រជុំ) នៅក្នុងគណៈកម្មាធិការថ្នាក់លើ បន្ទាន់ ដូច្នេះលេខាឃុំត្រូវចូលរួមប្រជុំនៅក្នុងកិច្ចប្រជុំ គណៈកម្មាធិការស្រុកលេខាស្រុកបានចូលរួមប្រជុំនៅក្នុង កិច្ចប្រជុំរបស់គណៈកម្មាធិការតំបន់ ហើយលេខាតំបន់ បានចូលរួមប្រជុំនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការ ភូមិភាគៗ ជាធម្មតា លេខាភូមិភាគ ដូចជា មូល សំបាត់ ហៅ រស់ ញឹម (លេខាភូមិភាគពាយព្យ) គឺជា សមាជិកនៃគណៈកម្មាធិការមជ្ឈិមៗ លេខាខ្លះទៀត ដូចជា សោ ភឹម(លេខាភូមិភាគបូព៌ា) និង តាម៉ុក (លេខាភូមិភាគនិរតី) ក៏ជាសមាជិកនៃគណៈកម្មាធិការ អចិន្ត្រៃយ៍ផងដែរៗ

**៣៧៥.** នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ មានការ ផ្លាស់ប្តូរថ្នាក់ដឹកនាំភូមិភាគជាបន្តបន្ទាប់ផ្អែកទៅតាម ភាពចាំបាច់នៅក្នុងប្រទេសនិងការសម្រេចចាប់ខ្លួនបក្ខ ជន ដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព នៅមន្ទីរសន្តិសុខស-២១ៗ ជាញឹកញាប់ តួនាទីថ្នាក់ដឹក នាំត្រូវបានផ្តល់ទៅឲ្យក្រុមគ្រួសារសមាជិកគណៈកម្មា ធិការមជ្ឈិមៗ

**៣៧៦.** ភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់)៖ នៅមុន ឆ្នាំ១៩៧៥ លេខាភូមិភាគកណ្តាល (ឧត្តរចាស់) គឺ កុយ ធួន រីឯ កែ ពក ជានុលេខាៗ ក្រោយខែមេសា ឆ្នាំ១៩៧៥ កុយ ធួន ត្រូវបានផ្ទេរមកភ្នំពេញ ហើយត្រូវបានចាត់តាំង ឲ្យទទួលខុសត្រូវខាងពាណិជ្ជកម្ម ចំណែកឯ កែ ពក បាន ក្លាយជាលេខាភូមិភាគកណ្តាល (ឧត្តរចាស់) ដោយគាត់ បន្តកាន់តួនាទីនេះរហូតដល់ចុងរបបកម្ពុជាប្រជាធិប តេយ្យៗ សមាជិកគណៈកម្មាធិការភូមិភាគកណ្តាល (ឧត្តរចាស់) ដទៃទៀតរួមមាន ជ ឆាន ហៅស្រេង (លេខាតំបន់៤១ និងជាអនុលេខាភូមិភាគ), ចាន់ ម៉ុន ហៅ គុល (លេខាតំបន់៤២) និង គាំ ចាន់ ហៅ ចន (លេខាតំបន់៤៣)ៗ នៅអំឡុងខែកុម្ភៈឆ្នាំ១៩៧៧ លេខា តំបន់ទាំងអស់នៅក្នុងភូមិភាគកណ្តាល) (ឧត្តរចាស់) ត្រូវបានគេចាប់ខ្លួនហើយបញ្ជូនមកមន្ទីរសន្តិសុខស-២១ៗ អោ អាន ហៅ តាអាន ជាកម្មាភិបាលភូមិភាគនិរតីបាន ក្លាយជាលេខាតំបន់៤១ ហើយ អឿន ដែលជាប្អូនប្រុស របស់ ស៊ុ សឿន ដែលជាប្រពន្ធ កែ ពក (ហេតុដូច្នេះ គាត់ គឺជាប្អូនថ្លៃ កែ ពក) បានក្លាយជាលេខាតំបន់ ៤២ៗ រីឯ ផែន ហៅ តាផិន ដែលជាកម្មាភិបាលភូមិភាគនិរតីម្នាក់ ផងដែរនោះ បានក្លាយជាលេខាតំបន់៤៣ៗ កែ ពក គឺជា លេខាភូមិភាគពេញមួយរបបកម្ពុជាប្រជាធិបតេយ្យៗ

**៣៧៧.** តំបន់ស្វយ័ត១០៣ និង១០៦ និងភូមិភាគឧត្តរថ្មី៖ នៅក្នុងខែមេសា ឆ្នាំ១៩៧៥ មជ្ឈិមបក្សបានគ្រប់គ្រង ផ្ទាល់លើតំបន់ស្វយ័ត ១០៦ (ដែលរួមមាន សៀមរាប និង ឧត្តរមានជ័យ) និង តំបន់ស្វយ័ត១០៣(គ្របដណ្តប់លើ ព្រះវិហារ)ៗ ប៉ាំ ផល ហៅ សុត គឺជាលេខាតំបន់១០៦ រហូតដល់ពេលគាត់ត្រូវបានគេចាប់ខ្លួន និងបញ្ជូនមកឃុំ ខ្លួននៅមន្ទីរសន្តិសុខស-២១ នៅក្នុងខែកុម្ភៈឆ្នាំ១៩៧៧ៗ នៅក្នុងអំឡុងខែកុម្ភៈ ឆ្នាំ១៩៧៧ តួនាទីរបស់ កង ចាប ហៅ សែ ដែលជាអនុលេខាភូមភាគនិរតីត្រូវបានផ្លាស់ ប្តូរ ហើយគាត់ត្រូវបានផ្ទេរទៅជួយ កែ ពក លើផ្នែក រដ្ឋបាលនៅតំបន់១០៦ៗ នៅពាក់កណ្តាលឆ្នាំ១៩៧៧ តំបន់១០៦ និង តំបន់១០៣ ត្រូវបានបញ្ចូលគ្នាបង្កើតជា ភូមិភាគឧត្តរថ្មី(ភូមិភាគ៨០១)ៗ ដាត ហៅ ហង្ស ដែល ជាលេខាតំបន់១០៣ ត្រូវបានចាប់ខ្លួននៅថ្ងៃទី ០៣ ខែ មករា ឆ្នាំ១៩៧៨ៗ នៅក្នុងអំឡុងពេលជាមួយគ្នានេះផង ដែរ នួន ជា បានបង្កើតដំណើរទៅខេត្តព្រះវិហារ ហើយ បានប្រកាសតែងតាំង កង ចាប ហៅ សែ ជាលេខាភូមិ ភាគឧត្តរថ្មីៗ កង ចាប ហៅ សែ ត្រូវបានចាប់ខ្លួននៅថ្ងៃ ទី២២ ខែសីហា ឆ្នាំ១៩៧៨ ហើយត្រូវបានសម្លាប់នៅ មន្ទីរសន្តិសុខស-២១ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៨ៗ

**៣៧៨.** ភូមិភាគបូព៌ា៖ សោ ភឹម ដែលជាលេខាភូមិភាគ បូព៌ា ក៏ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ចាប់តាំង ពីមហាសន្និបាតបក្សលើកទីមួយនៅក្នុងឆ្នាំ១៩៦០ៗ

គាត់ក៏ជាមេបញ្ជាការកងប្រដាប់អាវុធភូមិភាគផងដែរ។ ភូមិភាគបូព៌ា ត្រូវបានបែងចែកជាតំបន់២០,២១,២២, ២៣ និង ២៤ ប៉ុន្តែមិនមានភាពច្បាស់លាស់ទេដែលថា លេខាតំបន់ទាំងអស់គឺជាសមាជិកគណៈកម្មាធិការភូមិភាគបូព៌ានោះ។ រហូតដល់ខែសីហា ឆ្នាំ១៩៧៦ អនុលេខាភូមិភាគបូព៌ានិង លេខាតំបន់២៤ គឺ សួស ហៅ ឈូក។ លេខាតំបន់ដទៃទៀតនៅភូមិភាគបូព៌ារួមមាន ជាដំបូងគឺ គង់ ជាស៊ិន ហៅ ស៊ុន (លេខាតំបន់២០), ភួង ដែលត្រូវបានជំនួសដោយ តូច ថែម ហៅ សុត (លេខាតំបន់២១) នៅក្នុងឆ្នាំ១៩៧៦, ស៊ាត ឆែ ហៅ ទុំ (លេខាតំបន់២២ និងជាសមាជិកបម្រុងរបស់គណៈកម្មាធិការមជ្ឈិមដែលក្រោយមកធ្វើការនៅសេនាធិការនៅភ្នំពេញ) និង អ៊ុន សាវ៉ាន់ ហៅ សូ (លេខាភូមិភាគបូព៌ាតំបន់២៣)។

**៣៧៩.** នៅពាក់កណ្តាលឆ្នាំ១៩៧៦ ឈូក បានត្រូវចោទថាជាជនក្បត់ ហើយត្រូវបានបញ្ជូន មកមន្ទីរសន្តិសុខស-២១ ដែលទីនោះគាត់ត្រូវបានគេធ្វើទារុណកម្មនិងសម្លាប់។ លេខាតំបន់ផ្សេងទៀតនៅក្នុងភូមិភាគបូព៌ាត្រូវបានចាប់ខ្លួន ហើយបញ្ជូនមកមន្ទីរសន្តិសុខស-២១ នៅចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨។ សេង ហុង ហៅ ចាន់ បានក្លាយជាអនុលេខាភូមិភាគបូព៌ាហើយមានតួនាទីជាលេខាតំបន់២៣ និងលេខាតំបន់២៤ ក្រោយពេលដែលឈូក ត្រូវបានចាប់ខ្លួន។ សោ ភឹម បន្តធ្វើជាលេខាភូមិភាគបូព៌ារហូតដល់ខែ មិថុនា ឆ្នាំ១៩៧៨។

**៣៨០.** ចំពោះភូមិភាគបស្ចិម និងភូមិភាគនិរតី៖ តាម៉ុក គឺជាលេខាភូមិភាគនិរតីពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ហើយគាត់ស្ថិតនៅលំដាប់ទីបីឬ ទីបួននៅក្នុងឋានានុក្រមគណៈកម្មាធិការអចិន្ត្រៃយ៍ដែលស្ថិតនៅក្រោម ប៉ុល ពត និង នួន ជា។ កង ចាប ហៅ សែ គឺជាអនុលេខាភូមិភាគនិរតី រហូតដល់ពេលដែលគាត់បានផ្ទេរទៅភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់) នៅក្នុងខែកុម្ភៈឆ្នាំ១៩៧៧ ដើម្បីទៅកាន់តំណែងនៅតំបន់ស្វយ័ត១០៦។ ជូ ជេត ហៅ ស៊ី គឺជាសមាជិកគណៈកម្មាធិការភូមិភាគនិរតី។ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភូមិភាគនិរតីត្រូវបានបំបែកទៅជាភូមិភាគបស្ចិម (ដែលរួមមានតំបន់១១,៣១,៣២,៣៧) និងភូមិភាគនិរតី (ដែលរួមមានតំបន់១៣,២៥,៣៣ និង៣៥)



មន្ទីរនីរសារភូមិភាគក្នុងរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដោយ ជូ ជេត បានក្លាយជាលេខាភូមិភាគបស្ចិម ចំណែក ឯតាម៉ុក នៅបន្តធ្វើលេខាភូមិភាគនិរតី។ សំ ប៊ិត ក៏មានតួនាទីនៅក្នុងថ្នាក់ដឹកនាំភូមិភាគនិរតីដែរដោយសារគាត់ គឺជាលេខាកងពលលេខ ២ នៃភូមិភាគនិរតី។ នៅពេលដែលតាម៉ុក ក្លាយជាលេខាភូមិភាគពាយព្យជំនួសឲ្យ រស់ ញឹម បន្ថែមពីលើតួនាទីរបស់គាត់នោះ សំ ប៊ិត បានកាន់តួនាទីក្នុងថ្នាក់ដឹកនាំកាន់តែលេចធ្លោជាងមុននៅក្នុងភូមិភាគនិរតី។ ជូ ជេត ហៅ ស៊ី ត្រូវបានចាប់ខ្លួននៅក្នុងខែមេសា ឆ្នាំ១៩៧៨ ហើយត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខ ស-២១។ នៅចុងក្រោយទោះបីជាការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង ស្ថិតនៅភូមិភាគបស្ចិមយ៉ាងណាក្តី ប៉ុន្តែការដ្ឋានការងារនោះត្រូវបានត្រួតពិនិត្យដោយ ស៊ូ ម៉េត ដែលជាមេបញ្ជាការកងពល ៥០២ ស្ថិតនៅទីក្រុងភ្នំពេញ ហើយគាត់បានចុះពិនិត្យការដ្ឋានការងារនេះជាប្រចាំ។

**៣៨១.** ភូមិភាគពាយព្យ៖ មូល សំបាត់ ហៅ រស់ ញឹម គឺជាលេខាភូមិភាគពាយព្យរហូតដល់អំឡុងខែឧសភា-មិថុនា ឆ្នាំ ១៩៧៨។ គង់ សុផល ហៅ កឹ ហៅ កាន គឺជាអនុលេខាភូមិភាគចាប់ពីឆ្នាំ១៩៧៥ ដល់ចុងឆ្នាំ១៩៧៨។ ភូមិភាគនេះត្រូវបានបែងចែកជាតំបន់១ ទៅដល់តំបន់៧។ រស់ ម៉ៅ ហៅ សាយ ហៅ ថន គឺជាសមាជិកនៃគណៈកម្មាធិការភូមិភាគពាយព្យ ជាប្រធានមន្ទីរនៃភូមិភាគពាយព្យ ជាអតីតលេខាតំបន់១ ហើយគាត់ត្រូវចាប់ខ្លួន និងបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ នៅថ្ងៃទី២៦ ខែមិថុនា ឬ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៧៧។ គាត់ត្រូវបានជំនួសដោយ ជា ហួត ហៅ វ៉ាញ ដែលជាលេខាតំបន់១ ហើយគាត់ត្រូវបានគេចាប់ខ្លួនមកមន្ទីរសន្តិសុខស-២១ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧។ ម៉ែន ផុន ហៅ ហ៊ីង គឺជាលេខាតំបន់៥ ដែលមានទីតាំងនៅទំនប់ត្រពាំងថ្ម។ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៧ លេខាតំបន់ទាំងអស់ និងថ្នាក់ដឹកនាំស្រុកជាច្រើននៅក្នុងភូមិភាគពាយព្យ ត្រូវបានចាប់ខ្លួននិងបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ រួមទាំង វ៉ាញ និង ហ៊ីង ដើម្បីសួរចម្លើយនិងត្រូវបានគេសម្លាប់។ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៧ ជៀល ហៅ ឆ្នាំង ដែលជាកូនប្រុសរបស់ រស់ ញឹម បានកាន់កាប់តួនាទីសំខាន់នៅក្នុងតំបន់ ៥ បានរយៈពេលប្រមាណជាពីរទៅបីខែរហូតដល់ពេលដែល ហេង រិន ហៅ ម៉ី ដែលមកពីភូមិភាគនិរតីបានក្លាយជាលេខាតំបន់៥។

**៣៨២.** ភូមិភាគឦសាន៖ ម៉ែន សាន ហៅ ណៃ សារ៉ាន់ ហៅ យ៉ា មានតួនាទីជាលេខាភូមិភាគឦសាន រហូតដល់ពេលត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៦ និងត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខស-២១។ គាត់ត្រូវបានជំនួស ដោយអនុលេខារបស់គាត់ អ៊ុម ណេង ហៅ វី។ នៅជិតចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យជាពិសេសនៅចុងឆ្នាំ១៩៧៨ ភូមិភាគឦសានត្រូវបានគេបោសសម្អាតក្នុងទ្រង់ទ្រាយធំ។

**៣៨៣.** ទោះបីជាមន្ទីរសន្តិសុខអូរកន្សែងស្ថិតនៅក្នុងភូមិភាគឦសានក្តី ប៉ុន្តែមន្ទីរសន្តិសុខនេះស្ថិតក្រោមការគ្រប់គ្រងរបស់កងទ័ព។ ប្រធានមន្ទីរសន្តិសុខអូរកន្សែងត្រូវរាយការណ៍ទៅឲ្យកងវរសេនាតូច ៨០៦ នៃកងពលមជ្ឈិម ៨០១ ក្រោយមកគាត់ត្រូវរាយការណ៍ដោយផ្ទាល់ទៅឲ្យ សូ សារឿន ដែលជាមេបញ្ជាការសេនាធិការ៨០១។ ចំណែក សូ សារឿនបានរាយការណ៍បន្តទៅ សុន សេន នៅទីបញ្ជាការសេនាធិការនៅទីក្រុងភ្នំពេញ ហើយ សុន សេន បញ្ជូនបានរបាយការណ៍បន្តទៅឲ្យគណៈកម្មាធិការអចិន្ត្រៃយ៍។

**៣៨៤.** តំបន់ស្វយ័តដទៃទៀត៖ នៅឆ្នាំ១៩៧៥ មានតំបន់ស្វយ័តមួយចំនួនឬតំបន់ «ដែលត្រូវបានចាត់តាំងជាពិសេស»។ ក្រៅពីខេត្តព្រះវិហារ (លេខកូដ១០៣) និងសៀមរាប-ឧត្តរមានជ័យ (លេខកូដ១០៦) ដូចបានកត់សម្គាល់ខាងលើ ខេត្តមណ្ឌលគិរី (លេខកូដ១០៥) ខេត្តក្រចេះ (លេខកូដ៥០៥) និងកំពង់សោមមិនស្ថិតនៅក្នុងភូមិភាគណាមួយនោះឡើយ។ ហើយតំបន់ស្វយ័តទាំងនេះត្រូវធ្វើទំនាក់ទំនងការងារផ្ទាល់ទៅកាន់មជ្ឈិមបក្ស។

**៣៨៥.** ឈ្មោះ ឡាំង បានកាន់កាប់តួនាទីជាលេខាតំបន់ ១០៥ រហូតដល់ចុងឆ្នាំ១៩៧៧ នៅពេលដែលគាត់ត្រូវបានគេកោះហៅមកភ្នំពេញ ហើយគាត់បានទទួលមរណភាពក្រោមស្ថានភាពគួរឲ្យសង្ស័យ។ ក្រោយពេលនោះបន្តិច ខាំ ភួន ដែលជាអនុលេខាតំបន់១០៥ បានបាត់ខ្លួន។ សាក់ង៉ី សៅ សារុនបានក្លាយជាលេខាតំបន់១០៥។ ការបោសសម្អាតគណៈកម្មាធិការតំបន់១០៥ បានកើតឡើងជាបន្តបន្ទាប់និងបានបន្តពេញមួយឆ្នាំ១៩៧៨។

**៣៨៦.** យ៉ុង យ៉ែម ជាលេខាតំបន់៥០៥ ចាប់ពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៦។ ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨ ប៊ិន

ណាន ហៅ យី គឺជាលេខា។ ដំបូងឡើយ តំបន់៥០៥ ស្ថិតក្រោមការគ្រប់គ្រងរបស់ភូមិភាគឦសាន ប៉ុន្តែក្រោយមកតំបន់នោះបានក្លាយទៅជាតំបន់ស្វយ័ត។ ប៊ិន ណាន ហៅ យី ត្រូវបានចាប់ខ្លួននៅក្នុងខែមីនា ឆ្នាំ១៩៧៨ ហើយបន្ទាប់មក មាស កេត ហៅ មឿន និង ឈឹម ខុន បានក្លាយជាលេខានិងអនុលេខានៃតំបន់នេះ។ កងពល១១៧ មានមូលដ្ឋាននៅក្នុងតំបន់ ៥០៥ ដើម្បីវាយប្រយុទ្ធជាមួយកងទ័ពវៀតណាម និងត្រូវបានរាយការណ៍ផ្ទាល់ទៅខាងសេនាធិការ។ បន្ទាប់ពីកងទ័ពវៀតណាមបានចូលមកកាន់កាប់ស្រុកស្នួល (តំបន់៥០៥) ក្នុងឆ្នាំ១៩៧៨ ហេតុការណ៍នេះនាំឲ្យកងពល១១៧ ស្ថិតក្រោមការសង្ស័យ។ មាស មុត បានធ្វើដំណើរពីកំពង់សោមមកតំបន់នេះ ដើម្បីធ្វើការផ្លាស់ប្តូរថ្នាក់ដឹកនាំតំបន់ និងកងពលទាំងនេះ។ សាក្សី ម៉ឹង វេត ដែលជាអនុប្រធានមន្ទីរកងពល១១៧ បានឃើញលិខិតពីមន្ទីរ៨៧០ បញ្ជាឲ្យកម្មាភិបាលចំនួន ១១នាក់ មកភ្នំពេញតាមយន្តហោះ ដែលក្នុងនោះរួមទាំង យុន រុំ ហៅ រុំ មេបញ្ជាការកងពល១១៧ មាស កេត ហៅ មឿន លេខាតំបន់៥០៥ និង ជុំ ចិន ហៅ ភ័ន លេខាស្រុកស្នួល។ បន្ទាប់មក ម៉ឹង វេត បានឮថា កម្មាភិបាលទាំងនោះត្រូវបានគេចាប់ខ្លួននិងត្រូវបានចោទប្រកាន់ថា ជាជនក្បត់។ ក្នុងចំណោមអ្នកទាំងអស់នោះរួមមាន យុន រុំ ហៅ រុំ និង មាស កេត ហៅ មឿន ត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខស-២១។ សាក្សី ម៉ឹង វេត បានឮថាអ្នកផ្សេងទៀតនៅក្នុងចំណោមបុគ្គលទាំង ១១ នាក់នោះ ប្រហែលជាត្រូវបានគេបញ្ជូនទៅខេត្តកំពង់ឆ្នាំង។ កំណត់ត្រារបស់មន្ទីរសន្តិសុខស-២១បានបញ្ជាក់ថា ពួកគេទាំងនោះត្រូវ បានចាប់ខ្លួននៅក្នុងខែធ្នូឆ្នាំ១៩៧៨។

៣៨៧. មាស មុត ក្នុងនាមជាមេបញ្ជាការកងពលមជ្ឈិម ១៦៤ ទទួលខុសត្រូវលើកំពង់ផែកំពង់សោម។ ហង់ធឿន ហៅ ឌឹម គឺជាអនុបញ្ជាការរបស់ មាស មុត រហូតដល់ពេលដែលគាត់ត្រូវចាប់ខ្លួនបញ្ជូនមកមន្ទីរសន្តិសុខស-២១ នៅក្នុងខែមេសាឆ្នាំ១៩៧៧។ កងពល១៦៤ យ៉ាងហោចណាស់រួមមានវរសេនាធំ៦១, ៦២ និង ៦៣ ហើយបញ្ជាការដ្ឋានរបស់កងពលមានទីតាំងនៅផ្ទង់មូលក្បែរសាលមហោស្រពនៃក្រុងកំពង់សោម។ ធុច រិន ហៅ គ្រិន គឺជាប្រធានកំពង់ផែនៅតំបន់កំពង់សោម រហូតដល់ពេលដែលគាត់ត្រូវបានបញ្ជូនឲ្យនៅធ្វើការនៅហុងកុង ដើម្បីមើលការខុសត្រូវគ្រប់គ្រងក្រុម ហ៊ុនរ៉ុន ហ្វុ (Ren Fung) នៅក្នុងខែធ្នូ ឆ្នាំ១៩៧៨។

## ៥.១.៨. អង្គការ

៣៨៨. ពាក្យថា «អង្គការ» ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយចាប់តាំងពីថ្ងៃដំបូងៗនៃចលនាកុម្មុយនីស្តកម្ពុជា ដោយសំដៅលើបក្សដែលក្រោយមកក្លាយជា ប.ក.ក.។ ទោះបីជាយ៉ាងណាពាក្យថា «អង្គការ» នេះមិនខុសគ្នាពីពាក្យថា «មជ្ឈិមបក្ស» នោះទេ គឺជាពាក្យមួយដែលពិបាកយល់និងមានភាពស្រពិចស្រពិល។ ឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណី រ៉ែម យុន បានហៅគណៈកម្មាធិការដែលត្រូវបានតែងតាំងដោយឃុំក្នុងមូលដ្ឋានថាជា «អង្គការ» ។ ប៉ុន្តែ ចំពោះអ្នកផ្សេងទៀត «អង្គការ» គឺពាក្យសម្ងាត់សំដៅទៅលើ ប.ក.ក។ ឌុច បានលើកឡើងថានៅពេលគាត់ប្រើពាក្យ «អង្គការ» គឺសំដៅទៅលើ **«នេះសំដៅថា ប៉ុល ពត។ ហើយនិយាយមួយម៉ាត់ចំពោះខ្ញុំ ខ្ញុំប្រើអង្គការនេះសំដៅអចិន្ត្រៃយ៍មជ្ឈិមបក្ស។ បុគ្គលណាមួយដែលចុះមកដឹកនាំខ្ញុំក្នុងតំណាង ប៉ុល ពត គឺជាអចិន្ត្រៃយ៍មជ្ឈិមបក្ស»** គាត់បានលើកឡើងបន្ថែមទៀតថាអ្នកផ្សេងបានប្រើពាក្យនេះខុសពីន័យរបស់វា។ ពេលខ្លះពាក្យថា «អង្គការ» នៅក្នុងឯកសារមួយសំដៅទៅលើសមាជិកជាន់ខ្ពស់ណាម្នាក់នៃ ប.ក.ក. ដូចជា សុន សេន ឬ ប៉ុល ពត។ សាក្សី សួគ្រ ឡើង បានផ្តល់សក្ខីកម្មថា តាមគាត់យល់ « អង្គការ» មានន័យថា ជា «អង្គការ» បានជំរុញឲ្យគណៈកម្មាធិការ៨៧០ ចេញក្តីណែនាំមួយ នៅក្នុងឆ្នាំ១៩៧៧ ដោយមានអត្ថន័យដូចខាងក្រោមនេះ៖

១. ***ពាក្យថា«អង្គការ» ឬ «បក្ស» ត្រូវបានប្រើប្រាស់សម្រាប់តែអង្គការចាត់តាំងប៉ុណ្ណោះ។ ពាក្យនេះមិនត្រូវបានប្រើប្រាស់បុគ្គលឡើយ។***

២. ***ចំពោះបុគ្គលត្រូវប្រើពាក្យថា «សមមិត្ត» «ឈ្មោះនេះ» ឬ «សមមិត្តនៅក្នុងតំណែងនេះពាក្យនោះ» ឬ «សមមិត្តតំណាងអ្នកអង្គការថ្នាក់នេះ ថ្នាក់នោះ» ។***

៣៨៩. យ៉ាងណាមិញ មិនមានភាពច្បាស់លាស់ថា តើ

សេចក្តីណែនាំនេះត្រូវបានផ្សព្វផ្សាយនៅក្នុងចំណោមប្រជាជនសាមញ្ញក្នុងកម្រិតណានោះទេ។ ទោះបីជាសាក្សី ពេជ ដឹម អតីតលេខាស្រុកបានចងចាំថា គាត់បានអប់រំប្រជាជនថា «មិនមែនអង្គការទេយើងនោះ យើងបុគ្គលទេ» ពុំមានភាពច្បាស់លាស់ថា សាក្សីជាច្រើននាក់ដែល ក.ស.ច.ស. បានស្តាប់ចម្លើយ ពុំដែលក្តាប់ន័យពាក្យ «អង្គការ» បានពេញលេញនោះទេ ទាំងនៅពេលមុនឬក្រោយឆ្នាំ១៩៧៧។

## ៥.១.៩. ប្រជាធិបតេយ្យប្រមូលផ្តុំ

**៣៩០.** *លក្ខន្តិកៈបក្សឆ្នាំ១៩៧១ និងលក្ខន្តិកៈបក្សឆ្នាំ១៩៧៦ បានចែងថា បក្សផ្តាច់មុខដាច់ខាតនិងគ្រប់មុខ ហើយបក្សគឺជាអង្គការកំពូល និងជាអគ្គបញ្ជាការគ្រប់គ្រងការងារ បដិវត្តន៍គ្រប់បែបយ៉ាង ហើយបក្សស្ថិតនៅជាប់ជិតស្និទ្ធជាមួយមហាជន។ ទោះជាយ៉ាងណា គោលការណ៍នេះត្រូវបានបកស្រាយរួមគ្នាជាមួយនឹងគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ។ ប្រជាធិបតេយ្យប្រមូលផ្តុំ គឺជាមូលដ្ឋានចាត់តាំងរបស់បក្សដែលតម្រូវឲ្យអង្គការដឹកនាំគ្រប់ជាន់ថ្នាក់អនុវត្តការដឹកនាំបែបសមូលហភាព ដោយបុគ្គលមានការទទួលខុសត្រូវដោយឡែកៗ តាមគោលការណ៍នេះ នៅគ្រប់សន្និបាតបក្សទាំងអស់ត្រូវតែគោរពមតិភាគច្រើន ពោលគឺមតិភាគតិចត្រូវតែគោរពតាមមតិភាគច្រើន ចំណែកឯថ្នាក់ក្រោមត្រូវតែគោរពថ្នាក់លើ។*

**៣៩១.** *ប្រជាធិបតេយ្យប្រមូលផ្តុំមានពីរចំណុច។ ចំណុចទីមួយ សេចក្តីសម្រេចទាំងឡាយត្រូវធ្វើឡើងតាមបែបប្រជាធិបតេយ្យ ពោលគឺការសម្រេចត្រូវធ្វើឡើងដោយសមូហភាព ពុំមែនដោយបុគ្គលនោះទេ។ ជារចនាសម្ព័ន្ធ ចំណុចនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈវត្តមានរបស់គណៈកម្មាធិការនៅគ្រប់ទីកន្លែងនៃឋានានុក្រម ប.ក.ក.។ ចំណុចនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរចនាសម្ព័ន្ធដឹកនាំដែលមានទម្រង់ជាពីរ៉ាមីតរបស់បក្ស ដោយមានអំណាចប្រមូលផ្តុំនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍តូចមួយដែលគ្រប់ជាន់ថ្នាក់ទាំងអស់ផ្សេងទៀតត្រូវរាយការណ៍ជូន និងត្រូវទទួលការណែនាំពីគណៈកម្មាធិការនេះ។*

**៣៩២.** *នួន ជា បានបញ្ជាក់ថា គោលការណ៍នៃការធ្វើសេចក្តីសម្រេចជាសមូហភាពត្រូវបានអនុវត្ត «នៅគ្រប់កាលៈទេសៈទាំងអស់» នៅក្នុងប.ក.ក. និងជាពិសេសនៅក្នុងពេលប្រជុំរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ដែលគាត់មានវត្តមាន។ ដូចដែល នួន ជា បានពន្យល់ជូនអង្គជំនុំជម្រះថា៖*



*កម្មាភិបាលខ្មែរក្រហមនៅមន្ទីរកំពុងជម្រះស្មៅ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*



*«សមូហភាព» បានន័យថាប្រមូលផ្តុំរួមគ្នាទាំងអស់ មានមតិជាប្រជាធិបតេយ្យប្រមូលផ្តុំ ប្រជុំអីក៏អញ្ចឹងដែរ។ មិនមែនត្រឹមតែប្រជុំមជ្ឈិម ប្រជុំអចិន្ត្រៃយ៍ទេ ហើយលេខាអចិន្ត្រៃយ៍ឬលេខាមជ្ឈិមបក្សជាអ្នកសរុប ហើយកាលណាសរុបហើយមិនពេញចិត្តអង្គប្រជុំៗមានសិទ្ធិដើម្បីមានមតិតទៅទៀត ឬ មានមតិតវ៉ៃរហូតដល់កាលណាឯកភាពគ្នាជាផ្លូវមួយ ទើបចាត់ទុកជាបានការ។ បើមិនទាន់ឯកភាពគ្នាទេ ពិភាក្សាគ្នាតទៅទៀត។*

ស្រដៀងគ្នានេះដែរ នៅពេលសួរសំណួរនៅក្នុងកិច្ចសម្ភាសន៍ក្នុងឆ្នាំ ២០០៦ អំពីថាតើប៉ុល ពតមានអំណាចផ្តាច់មុខតែម្នាក់ឯងនៅរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ នួន ជា បានច្រានចោលការលើកឡើងដូច្នេះ ហើយបានលើកឡើងថា សេចក្តីសម្រេចត្រូវបានធ្វើឡើងជាសមូហភាព។

**៣៩៣.** ខៀវ សំផន បានបញ្ជាក់ផងដែរថា សេចក្តីសម្រេចសំខាន់ៗត្រូវបានធ្វើជាសមូលហភាព។ ពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គាត់បាននិយាយថា «បើមានសំឡេងតែមួយប្រឆាំងមិនឲ្យជម្លៀស នោះ ក៏អត់ជម្លៀសកើតទេ។ ប៉ុន្តែ អៀង សារី បានអះអាងថា មតិជំទាស់គាត់ជាបុគ្គល ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបញ្ឈប់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងការឈានទៅលុបបំបាត់លុយ នៅក្នុងឆ្នាំ១៩៧៥នោះទេ។

**៣៩៤.** អ្នកជំនាញ David CHANDLER បានផ្តល់សក្ខីកម្មថា ទោះបីជា ប៉ុល ពត អាចជាអ្នក«មានសិទ្ធចុងក្រោយ» នៅក្នុងការធ្វើសេចក្តីសម្រេចក្នុងនាមជាលេខា ប.ក.ក. ក៏ដោយ ក៏គ្មានភស្តុតាងណាមួយបង្ហាញថា គាត់បានធ្វើសេចក្តីសម្រេចតែម្នាក់ឯងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ។

**៣៩៥.** អ្នកជំនាញ Philip SHORT បានពន្យល់អំពីការប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងន័យមួយខុសពីនេះបន្តិច។ នៅក្នុងទស្សនៈរបស់គាត់ ប៉ុល ពត បានប្រមូលយកមតិយោបល់នានាពីសមាជិកផ្សេងៗនៅក្នុងពេលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយបានដាក់បញ្ចូលមតិយោបល់របស់ពួកគេនៅក្នុងសេចក្តីសន្និដ្ឋានរបស់គាត់ ប៉ុន្តែ «គោលនយោបាយដែលចេញមក គឺជាគោលនយោបាយមួយដែលភាគច្រើនបំផុត គាត់បានសម្រេចដោយខ្លួនឯងរួចទៅហើយ តាំងពីមុនមានការប្រជុំចាប់ផ្តើមម្ល៉េះ» ។

**៣៩៦.** លើសពីនេះទៀត អង្គជំនុំជម្រះកត់សម្គាល់នូវចំណុចខុសគ្នាសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងលក្ខន្តិកៈបក្សឆ្នាំ១៩៧១ និងលក្ខន្តិកៈបក្សនៅក្នុងឆ្នាំ១៩៧៦។ កំណត់ត្រាដែលបង្ហាញអំពីខ្លឹមសារនៃលក្ខន្តិកៈបក្សនៅក្នុងឆ្នាំ១៩៧១ បានបង្ហាញថា ថ្នាក់ក្រោមត្រូវបានអនុញ្ញាតឲ្យស្នើសុំការពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់ថ្នាក់លើ។ លក្ខន្តិកៈបក្សឆ្នាំ១៩៧១ ក៏បានកំណត់ផងដែរថា អង្គភាពដឹកនាំបក្សគ្រប់ជាន់ថ្នាក់ត្រូវតែជ្រើសរើសឡើងតាមរយៈការបោះឆ្នោត (លើកលែងតែក្នុងករណីមានការលំបាកពុំអាចបោះឆ្នោតបាន នោះថ្នាក់លើអាចតែងតាំងបាន)។ ដូច្នេះនេះផងដែរ លក្ខន្តិកៈបក្សឆ្នាំ១៩៧១ បានចែងថា អង្គការដឹកនាំមានសិទ្ធិអំណាចនៅក្នុងការដោះស្រាយកិច្ចការដែលស្ថិតនៅក្នុងក្របខណ្ឌរបស់ខ្លួន ដោយអនុវត្តន៍តាមនយោបាយ និងគោលការណ៍ផ្សេងៗរបស់



គិលានដ្ឋានដែលសេសសល់ពីរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បក្ស។ ស្របតាមការណែនាំរបស់ថ្នាក់ដឹកនាំរបស់ថ្នាក់លើ។ លក្ខន្តិកៈបក្សឆ្នាំ១៩៧៦ មិនបានចែងអំពីបទប្បញ្ញត្តិទាំងនេះនោះទេ។ ជាក់ស្តែង មិនមានភស្តុតាងបង្ហាញថា គណៈកម្មាធិការប.ក.ក. នៅថ្នាក់មជ្ឈិម ភូមិភាគ តំបន់ ត្រូវបានជ្រើសរើសដោយការបោះឆ្នោតឡើយ។ ផ្ទុយទៅវិញ ថ្នាក់ដឹកនាំគណៈកម្មាធិការត្រូវបានតែងតាំងដោយគណៈកម្មាធិការថ្នាក់លើបន្ទាប់ក្នុងឋានានុក្រម។ កំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ បានតែងតាំងសមាជិកគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ឲ្យទទួលខុសត្រូវលើផ្នែកផ្សេងៗ ជាច្រើននៃគោលនយោបាយនៅក្នុងរដ្ឋាភិបាល និងផ្នែកសេនាធិការ។ កំណត់ហេតុនៃកិច្ចប្រជុំបានបញ្ជាក់ថាសេចក្តីសម្រេច និងសំណើគម្រោងទាំងអស់ត្រូវឆ្លងកាត់គណៈកម្មធិការអចិន្ត្រៃយ៍។ ហេតុដូច្នេះ ការលុបចោលបទប្បញ្ញត្តិនៅក្នុងលក្ខន្តិកៈបក្សឆ្នាំ ១៩៧១ ដែលតម្រូវឲ្យមានការបោះឆ្នោតចំពោះតួនាទីមួយចំនួននោះ គឺស្របទៅនឹងស្ថានភាពជាក់ស្តែងដែលថា ការសម្រេចនិងការតែងតាំងផ្សេងៗ ត្រូវបានធ្វើនៅគណៈកម្មាធិការអចិន្ត្រៃយ៍។

**៣៩៧.** ចំពោះភស្តុតាងផ្តល់ឲ្យដោយ នួន ជា, ខៀវ សំផន និង អៀង សារី ដែលមានវត្តមានឬបានចូលរួមនៅក្នុងពេលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នោះ អង្គជំនុំជម្រះជឿជាក់ថាសេចក្តីសម្រេចសំខាន់ៗរបស់គណៈកម្មាធិការអចិន្ត្រៃយ៍មិនមែនត្រូវបានធ្វើឡើងដោយ ប៉ុល ពត តែម្នាក់ឯងនោះទេផ្ទុយទៅវិញសេចក្តីសម្រេចទាំងនេះត្រូវបានធ្វើឡើងជាសមូហភាព ដែលមានន័យថា មានមតិយោបល់ និងមានការឯកភាពជាឯកច្ឆ័ន្ទពីគណៈកម្មាធិការទាំងមូល។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថា គណៈកម្មាធិការត្រូវការការឯកភាពជាឯកច្ឆ័ន្ទក្នុងការសម្រេចបុយ៉ាងណានោះទេ។ ហេតុដូច្នេះ អាចមានលទ្ធភាពថាមានពេលខ្លះសមាជិកម្នាក់ៗអាចទំនងជាមិនយល់ស្របជាមួយនឹងសេចក្តីសម្រេចជាក់លាក់ណាមួយផងដែរ។

## ៥.១.១០. សមាជិកភាពរបស់បក្ស

**៣៩៨.** លក្ខន្តិកៈបក្សឆ្នាំ១៩៧១ និងលក្ខន្តិកៈបក្សឆ្នាំ១៩៧៦ មានលក្ខណៈដូចគ្នាខ្លាំងពាក់ព័ន្ធនឹងបុរលក្ខខណ្ឌតម្រូវនានាសម្រាប់បក្ខជន ដែលស្ថិតនៅក្នុងតួនាទីជាថ្នាក់ដឹកនាំ។ លក្ខន្តិកៈបក្សទាំងពីរនេះមិនមានចែងនៅក្នុងលក្ខន្តិកៈបក្សឆ្នាំ១៩៦០នោះទេ ប៉ុន្តែថ្នាក់ដឹកនាំបក្សតម្រូវឲ្យមានជំហរបដិវត្តន៍រឹងមាំចំពោះ៖ (១)មាគ៌ានយោបាយ (២)សតិអារម្មណ៍ធអន (៣) សាមគ្គីភាពឯកភាពផ្ទៃក្នុងបក្ស (៤) មាគ៌ាចាត់តាំងដឹកនាំ និងធ្វើការងារ (៥) ការប្រុងប្រយ័ត្នរក្សាការសម្ងាត់ និងការពារកម្លាំងបដិវត្តន៍របស់បក្ស (៦) ឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន និងខ្លួនធ្វើម្ចាស់លើខ្លួនឯង (៧) ការធ្វើនិងត្រួតពិនិត្យប្រវត្តិរូបនិងជីវទស្សនៈបដិវត្ត (៨) វណ្ណៈភាព (៩) សីលធម៌រស់នៅស្អាតស្អំ និងស្អាតស្អំខាងនយោបាយ និង (១០) លទ្ធភាពកសាងខ្លួននិងទទួលតួនាទីដឹកនាំនាពេលអនាគត។ នៅក្នុងលក្ខន្តិកៈបក្សឆ្នាំ១៩៦០ ដើម្បីក្លាយជាបក្ខជនអាយុបក្សរបស់បក្ខជនម្នាក់ៗត្រូវបានយកមកពិចារណា ប៉ុន្តែលក្ខន្តិកៈបក្សបន្តបន្ទាប់មកទៀតនោះ

មិនមានការកំណត់អាយុបក្ខជនម្នាក់ៗត្រូវបានយកមកពិចារណា ប៉ុន្តែលក្ខន្តិកៈបក្សបន្តបន្ទាប់ទៀតនោះ មិនមានការកំណត់អាយុបក្ខជនទៀតនោះទេ។ ឌុច បានផ្តល់សក្ខីកម្មថា ការកំណត់បែបនេះធ្វើឲ្យការជ្រើសរើសបក្ខជនត្រូវពឹងផ្អែកទៅលើការវាយតម្លៃរបស់លេខាបក្សតាមបែបអត្តនោម័ត ពោលគឺពឹងផ្អែកលើ «សាមគ្គីភាព» របស់បក្ខជនជាមួយនឹងមាគ៌ានយោបាយរបស់បក្ស។

៣៩៩. សមាជិកពេញសិទ្ធិរបស់បក្សទទួលបានសិទ្ធិអំណាចនានាដូចជា សិទ្ធិក្នុងការចូលរួមធ្វើសេចក្តីសន្និដ្ឋានសម្រេចអនុលោមតាមមូលដ្ឋាននៃប្រជាធិបតេយ្យប្រមូលផ្តុំ និងការណែនាំអ្នកដទៃឲ្យចូលក្នុងបក្ស។ ប្រសិនបើបក្ខជនប្រព្រឹត្តខុសលក្ខន្តិកៈបក្សមានកំណត់ពីវិធានការវិន័យរួមមានៈ (១) ការទិតៀន(២) ការផ្លាស់ប្តូរការងារ (៣) ការបណ្តេញចេញពីបក្ស។ ដាក់ស្តែង កុយ ធួន ត្រូវបានផ្លាស់ប្តូរតួនាទី និងត្រូវបានបណ្តេញចេញពីបក្ស មុនពេលគាត់ត្រូវបានយកទៅសម្លាប់នៅក្នុងមន្ទីរសន្តិសុខស-២១។

៤០០. អង្គជំនុំជម្រះបានស្តាប់ភស្តុតាងដែលបានមកពីសក្ខីកម្មរបស់សាក្សីបុ្ក ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដែលពួកគេត្រូវបានណែនាំចូលបក្ស។ សួង ស៊ីគឿន ត្រូវបានណែនាំចូលបក្សដោយ លោក គាត ឈន់ និង ជួន ប្រសិទ្ធិ នៅផ្ទះរបស់ អៀង សារី នៅទីក្រុងប៉េកាំងក្នុងឆ្នាំ១៩៧១។ ពេជ្រ ដឹម ត្រូវបាន សោម ដែលជាលេខាតំបន់ណែនាំឲ្យចូលបក្ស។ នឹម សែម ត្រូវបាន ហ៊ូ នឹម ណែនាំ។ លើសពីនេះទៀត ខៀវ សំផន ត្រូវបាន តាម៉ុក ណែនាំ។

៤០១. នៅពេលដែលគាត់ត្រូវបានសួរដេញដោលថា តើបក្ខជនមានចំនួនប៉ុន្មាននាក់ ជាដំបូង ឌុច បានផ្តល់សក្ខីកម្មថា គាត់មិនបានដឹងនោះទេ ប៉ុន្តែក្រោយមកគាត់បានប៉ាន់ប្រមាណថា បក្ខជនមានប្រមាណជាប្រាំភាគរយនៃចំនួនប្រជាជនសរុប។ អង្គជំនុំជម្រះមិនដែលឃើញបញ្ជីដាក់លាក់នៃចំនួនបក្ខជននោះឡើយ។ ប៉ុន្តែ ភស្តុតាងបានបង្ហាញថា នៅពេលដំបូងចំនួនបក្ខជនមានចំនួនតិចតួចប៉ុណ្ណោះ ប៉ុន្តែបក្ខជនមានចំនួនកើនឡើងបន្តិចម្តងៗ។

៤០២. ទស្សនាវដ្តីទង់បដិវត្តន៍ជាច្រើនបានបញ្ជាក់ថា នៅពាក់កណ្តាល ឆ្នាំ១៩៧៤ គណៈកម្មាធិការមជ្ឈិមនៃ ប.ក.ក. បានសម្រេចឈប់ទទួលពាក្យបក្ខជនថ្មីហើយ (លើកលែងតែក្នុងជួរកងទ័ព) ដើម្បីការពារទប់ទល់កុំឲ្យគិញបង្កប់ស៊ីរូងផ្ទៃក្នុងចូលក្នុងជួរបក្ស។ នួន ជា បានផ្តល់សក្ខីកម្មថាការទទួលយកបក្ខមិនត្រូវបានបញ្ឈប់នោះទេនៅក្នុងអំឡុងពាក់កណ្តាលឆ្នាំ១៩៧៤ ប៉ុន្តែគាត់ទទួលស្គាល់ថា មូលហេតុសំខាន់ដែលបានលើកឡើងនៅក្នុងទស្សនាវដ្តីទង់បដិវត្តទាំងអស់នោះ គឺដោយសារតែមាន «ខ្មាំងយ៉ាងច្រើន» នៅក្នុងជួរបក្ស។ អង្គជំនុំជម្រះយល់ឃើញថាចំនួនបក្ខជនទំនងជាបានថយចុះ ដោយសារតែការភ័យខ្លាចពីបញ្ហាខ្មាំងផ្ទៃក្នុងកាន់តែមានច្រើនឡើងៗ នៅអំឡុងពាក់កណ្តាលឆ្នាំ១៩៧៤។

៤០៣. យ៉ាងណាមិញ នៅក្នុងឆ្នាំ១៩៧៧ ប.ក.ក. បានផ្តួចផ្តើមគំនិតក្នុងការអនុវត្តការកសាងបក្សដើម្បីបង្កើតចំនួនបក្ខជន។ ទស្សនាវដ្តីទង់បដិវត្ត ប្រចាំខែមេសា ឆ្នាំ១៩៧៧ បានចេញផ្សាយថាសេចក្តីសម្រេចដែលបានធ្វើឡើងនៅក្នុងសន្និបាតខែកុម្ភៈ ឆ្នាំ១៩៧៧ នៅខេត្តកំពង់ឆ្នាំ អំពីការកសាងបក្ខជននៅក្នុងសហករណ៍ នៅក្នុងឆ្នាំ១៩៧៧ ដើម្បីឲ្យបក្ខជនមានចំនួន ៣០នាក់ ក្នុងចំណោមគ្រួសារ១.០០០គ្រួសារ។ ទស្សនាវដ្តីនេះបានសង្កត់ធ្ងន់ថា ការជ្រើសរើសបក្ខជនថ្មីចាំបាច់ត្រូវតែប្រុងប្រយ័ត្ននិងផ្អែកលើលក្ខណៈវិនិច្ឆ័យទាំង១០ នៅក្នុងការជ្រើសរើស។ ទស្សនាវដ្តីនេះបានកត់សម្គាល់បន្ថែមទៀតថា ការបញ្ចូលសមាជិកថ្មី គឺធ្វើឡើងផ្អែកលើសេចក្តីសម្រេចរបស់គណៈកម្មាធិការភូមិភាគនិងខាងមជ្ឈិមបក្ស។ នៅក្នុងទស្សនាវដ្តីទង់បដិវត្តប្រចាំខែមិថុនា និងខែកក្កដា ឆ្នាំ១៩៧៧ ការកសាងជួរបក្សនៅតែជាបញ្ហាកង្វល់មួយ ដែលជំរុញឲ្យមានការបង្កើតចំនួនបក្ខជនថ្មី ប៉ុន្តែការជ្រើសរើសបក្ខជនថ្មីត្រូវធ្វើឡើងដោយប្រុងប្រយ័ត្នដើម្បីជៀសវាងខ្មាំងបង្កប់នៅក្នុងអង្គការស្នូលរបស់បក្ស។

៤០៤. ទស្សនាវដ្តីទង់បដិវត្ត ប្រចាំខែសីហា ឆ្នាំ១៩៧៧ បានបង្ហាញអំពីការលំបាកក្នុងការបង្កើនចំនួនបក្ខជនរបស់បក្ស ព្រោះកម្មាភិបាល បក្ខជន និងអង្គការបក្សស្នូល ត្រូវបានគេ «ដកចេញបណ្តេញចេញ និងរំលាយ ហើយឃ្លាតចាកពីចលនា» ។ អង្គជំនុំជម្រះកត់សម្គាល់ថា បញ្ហានេះបានកើតឡើងស្របគ្នាជាមួយនឹងការបោសសម្អាតទ្រង់

ទ្រាយធំនៅទូទាំងប្រទេស នៅពាក់កណ្ដាលឆ្នាំ១៩៧៧។ ហេតុដូច្នេះការចាប់ខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់បក្ខជន ដោយសារមូលហេតុដែលថាបុគ្គលទាំងនោះក្បត់នឹងបដិវត្តន៍ បានធ្វើឲ្យប៉ះពាល់ដល់ការខិតខំប្រឹងប្រែងបង្កើនចំនួនបក្ខជន។ សេចក្ដីសម្រេចមួយត្រូវបានរៀបចំឡើង ដើម្បីជ្រើសរើសបេក្ខជនដែលមកពីតំបន់ដែលមិនមានពួកក្បត់និងផ្អាកការជ្រើសរើសបក្ខជនដែលមកពីតំបន់ដែលមានពួកក្បត់។ តំបន់ ៣១, ៣២ និង ៣៧ ក្នុងភូមិភាគបស្ចិម ត្រូវបានគេចាត់ទុកថាជាតំបន់ដែលមានសមាសភាពល្អ ហើយតំបន់នេះត្រូវបានកំណត់បង្កើតបក្ខជនថ្មីចំនួន៣០០នាក់នៅត្រឹមបំណាច់ឆ្នាំ១៩៧៧។

**៤០៥.** ចំណុចនេះបង្ហាញអំពីមូលហេតុដែលថានៅក្នុងអំឡុងពាក់កណ្ដាលឆ្នាំ១៩៧៧ កម្មាភិបាលភូមិភាគនិរតីមិនត្រូវបានគេឆ្លៀយដាក់នៅក្នុងអំឡុងពេលបោសសម្អាតទ្រង់ទ្រាយធំនោះទេ ហើយពួកគេត្រូវបានតែងតាំងឲ្យធ្វើជាអ្នកដឹកនាំភូមិភាគដទៃទៀតទូទាំងប្រទេស ដូចជា ភូមិភាគកណ្ដាល (ឧត្តរចាស់), ភូមិភាគឧត្តរថ្មី, ភូមិភាគពាយព្យ និងភូមិភាគបូព៌ា។ ទស្សនាវដ្ដីទង់បដិវត្តប្រចាំខែមីនា ឆ្នាំ១៩៧៨ បានរាយការណ៍ថា ជាក់ស្ដែងចំនួនបក្ខជនដែលត្រូវបានបង្កើតក្នុង «ចំនួនសមស្រប» ចាប់តាំងពីខែកក្កដា ឆ្នាំ១៩៧៧ ហើយបានលើកឡើងថានេះគឺជាជ័យជម្នះដ៏សំខាន់ ដោយសារតែការងារនេះត្រូវបានសម្រេចនៅក្នុងពេលបោសសម្អាតបុគ្គលទាំងឡាយដែលមិនស្មោះត្រង់នឹងបក្ស។

**៤០៦.** នួន ជា បានផ្ដល់សក្ខីកម្មថា ចាប់តាំងពីការបង្កើតសន្និបាតលើកទីមួយ នៅក្នុងឆ្នាំ១៩៦០ មកថ្នាក់ដឹកនាំភូមិភាគទាំងអស់គឺសុទ្ធតែជាបក្ខជន។ លើសពីនេះទៀតភស្តុតាងដែលបានមកពីសក្ខីកម្មដែលអាចជឿជាក់បានបានឲ្យដឹងថា លេខាតំបន់ និងស្រុក និងសមាជិកគណៈកម្មាធិការ ព្រមទាំង បុគ្គលិកមន្ទីរសន្តិសុខមួយចំនួនគឺជាបក្ខជនឬ បក្ខជនត្រៀម។ ផ្អែកលើភស្តុតាងដែលអត្ថិភាព អង្គជំនុំជម្រះមិនអាចកំណត់បានពីរចំនួនបក្ខជន ប.ក.ក. នោះឡើយ។ ប៉ុន្តែបេក្ខជនត្រូវបានបង្ហាញយ៉ាង

**(តនៅលេខក្រោយ)**



កម្មករនៅរោងចក្រក្រឡឹងក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# «វេទិកាប្រវត្តិសាស្ត្រគ្រួសារ» ក្នុងស្រុកអន្លង់វែង

ស្ងួត វិចិត្រ



ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជួបជាមួយនឹងប្រជាជន ៥៣នាក់ ក្នុងស្រុកអន្លង់វែង នៅក្នុង «វេទិកាប្រវត្តិសាស្ត្រគ្រួសារ» ចាប់ពីថ្ងៃទី១៦ ដល់ទី២២ ខែកុម្ភៈ ឆ្នាំ២០២១។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

«វេទិកាប្រវត្តិសាស្ត្រគ្រួសារ» ត្រូវបានរៀបចំឡើងជាមួយនឹងប្រជាជន ៥៣នាក់ ( ប្រុស២១នាក់ និងស្រី ៣២នាក់) ក្នុងស្រុកអន្លង់វែង ចាប់ពីថ្ងៃទី១៦ ដល់ទី២២ ខែកុម្ភៈ ឆ្នាំ២០២១ ដោយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។

វេទិកានេះ បង្កើតឡើងក្នុងគោលបំណងជំរុញឲ្យមានការពិភាក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងលើកកម្ពស់ការកសាងសន្តិភាព និងការផ្សះផ្សា។

វេទិកាប្រវត្តិសាស្ត្រគ្រួសារ ជាមួយ១៤គ្រួសារនេះ បង្កលក្ខណៈឲ្យឪពុកម្តាយ ឬសាច់ញាតិក្រុមគ្រួសារនិយាយរៀបរាប់ពីរឿងរ៉ាវផ្ទាល់ខ្លួនកាលពីរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហមទៅកាន់កូនចៅរបស់ខ្លួន ថាតើឪពុកម្តាយធ្លាប់បាននិយាយរឿងរ៉ាវអ្វីខ្លះទៅ

កាន់កូនចៅរបស់ខ្លួន និងថាតើយុវជនធ្លាប់បានដឹងពីរឿងរ៉ាវអ្វីខ្លះពីឪពុកម្តាយរបស់ខ្លួនទាក់ទងនឹងរបបខ្មែរក្រហម។ ការជជែកពិភាក្សារវាងជំនាន់ពីរផ្សេងគ្នានេះ បានក្លាយជារបៀបរបបនៃការសិក្សាស្វែងយល់ថ្មីមួយដើម្បីជំរុញឲ្យយុវជនជ្រួតជ្រាបពីប្រវត្តិសាស្ត្រនៃក្រុមគ្រួសាររបស់ខ្លួន។

ឃុំចំនួន៤ ដែលរួមមាន ឃុំថ្លាត, ឃុំលំទង, ឃុំត្រពាំងប្រិយ៍ និងឃុំត្រពាំងតាវ បានក្លាយជាទីតាំងដ៏សំខាន់ក្នុងការចុះជួបប្រជាជនដែលមានអាយុចន្លោះពី៥២ឆ្នាំ រហូតដល់ជាង ៧៥ឆ្នាំ ដែលជាប្រភពឯកសាររស់ដ៏សំខាន់ ដែលជំរុញឲ្យមានការឈ្វេងយល់រឹតតែទូលំទូលាយជាងមុន។ ប្រជាជនភាគច្រើនធ្លាប់មានប្រវត្តិរត់ភៀសខ្លួនចេញពីទីកន្លែងផ្សេងៗគ្នា រួមមាន ខេត្តតាកែវ, កំពង់ចាម,សៀមរាប និងព្រៃវែង លើកលែងតែ ១គ្រួសារប៉ុណ្ណោះ ដែលមានទីកន្លែងកំណើតនៅក្នុងតំបន់អន្លង់វែងផ្ទាល់។

យោងតាមបទពិសោធន៍ផ្ទាល់ ប្រជាជនភាគច្រើនបានចែករំលែករឿងរ៉ាវទៅកាន់កូនចៅរបស់ខ្លួន អំពីការរស់នៅក្នុងកងកុមារ និងការធ្វើកិច្ចការងារនៅក្នុងពេលនោះ។ ការកាប់ដើមទន្ទ្រានខែត្រ, រើសអាចម៍គោ និងការធ្វើជី បានក្លាយជាការងារប្រចាំថ្ងៃរបស់កុមារ។ ប្រជាជនមួយចំនួនទៀត បានរំឭកអំពីការធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញនៅក្រោយពេលជម្លៀស ដើម្បីធ្វើការចាប់ពីឆ្នាំ១៩៧៦-១៩៧៩។





ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ជួបជាមួយនឹងប្រជាជន ៥៣នាក់ ក្នុងស្រុកអន្លង់វែង នៅក្នុង «វេទិកាប្រវត្តិសាស្ត្រគ្រួសារ» ចាប់ពីថ្ងៃទី១៦ ដល់ទី២២ ខែកុម្ភៈ ឆ្នាំ២០២១។
(ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

**អ៊ុន ណាម** ភេទស្រី អាយុ៥៦ មានទីកន្លែងកំណើតនៅក្នុងស្រុកពួក ខេត្តសៀមរាប បាននិយាយរៀបរាប់ពីជីវិតទៅកាន់ទីក្រុងភ្នំពេញថា៖ «នៅក្នុងឆ្នាំ១៩៧៦ ខ្ញុំបានធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញជាមួយម្តាយ។ នៅពេលនោះ ខ្មែរក្រហមបានស្នើរឲ្យខ្ញុំចូលបម្រើការងារនៅក្នុងឃ្លាំងរដ្ឋនៅទីនោះ។ ខ្ញុំមានតួនាទីចងធ្មេញឈើ នៅក្នុងរោងចក្រតម្បាញ និងរើសគ្រាប់ស្រូវចេញពីអង្ករ ដើម្បីចម្រាញ់យកអង្ករសុទ្ធលេខមួយលក់ទៅកាន់ប្រទេសចិន។ យើងបានរស់នៅដោយការហូបចុកល្អប្រសើរ និងទទួលបានការឈប់សម្រាកចំនួន៣ថ្ងៃជារៀងរាល់ខែ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំរស់នៅស្ថិតនៅក្នុងស្ថានភាពកំព្រាឪពុកម្តាយនៅក្នុងជំនាន់ខ្មែរក្រហម។»

ការរស់នៅ និងធ្វើការងាររបស់ប្រជាជនក្នុងរបបខ្មែរក្រហមមានភាពខុសប្លែកគ្នាទៅតាមតំបន់ និងតាមសហករណ៍។ សហករណ៍មួយចំនួនហាក់មានភាពរឹតត្បិត និងបង្កការលំបាក អាស្រ័យហេតុនេះហើយការបាត់ខ្លួន និងការសម្លាប់បានបង្កនូវភាពអសោច និងក្តីរន្ធត់

ឥតពិពណ៌នាបានឡើយ។ ប្រជាជនមួយចំនួនបានជួបនូវហេតុការណ៍ដ៏រន្ធត់ ហើយបន្តដិតដាមនៅក្នុងអារម្មណ៍រហូតដល់ពេលបច្ចុប្បន្ន។



ដែនជម្រកសត្វព្រៃ សង្ឃរុក្ខាវ័នស្ថិតនៅក្នុងក្រុងសំរោង ខេត្តឧត្តរមានជ័យ។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

**ម៉ន យាន** *ភេទស្រី អាយុ៥៨ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិចម្ការអណ្តូង នៃខេត្តកំពង់ចាម បានរៀបរាប់ថា ខ្លួនធ្លាប់ឃើញពីសាកសពមនុស្សជាច្រើនបានស្លាប់បាត់បង់ជីវិតនៅក្នុងអណ្តូងទឹកនៅក្នុងជំនាន់ខ្មែរក្រហម។ គាត់កើតមានក្តីរន្ធត់ និងតក់ស្លុតជាខ្លាំង ហើយមិនចង់ជួបរឿងរ៉ាវទាំងនោះទៀតទេ។ គាត់បាននិយាយថា គាត់មិនចង់ឲ្យកូនរបស់ខ្លួនបានដឹងពីរឿងរ៉ាវនេះទេ ពីព្រោះហាក់មានភាពតក់ស្លុតខ្លាំងពេក។*

*តាមរយៈ «វេទិកាប្រវត្តិសាស្ត្រគ្រួសារ» ក្រុមការងារសង្កេតឃើញថា យុវជនមួយចំនួនតូចប៉ុណ្ណោះដែលធ្លាប់បានស្តាប់ឮ និងសួរនាំពីរឿងរ៉ាវតស៊ូរបស់ឪពុកម្តាយ ខណៈដែលយុវជនមួយចំនួនធំទៀត មិនធ្លាប់បានដឹងឬចាប់អារម្មណ៍ទាល់តែសោះទៅលើរឿងរ៉ាវរបស់ឪពុកម្តាយខ្លួន។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ខាំ នឿន ភេទប្រុស មានវ័យ៦៣ឆ្នាំ នៅតែជឿជាក់ថា វេទិកាប្រវត្តិសាស្ត្រគ្រួសារ ឬការរៀបរាប់សាច់រឿងទៅកាន់កូន គឺជាកត្តាជំរុញដ៏សំខាន់សម្រាប់បង្កើតឲ្យមានការពិភាក្សាជាអន្តរជំនាន់ ហើយយុវជននឹងអាចងាកមកចាប់អារម្មណ៍ផ្នែក*





ផ្ទះរបស់ប្រជាជននៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)






ផ្លូវលំនៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។
(ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ផ្លូវក្រាលកៅស៊ូតាមបណ្ដោយមាត់បឹងតាម៉ុក ឬបឹងអន្លង់វែង ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។
(ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ផ្លូវឡើងទៅច្រកព្រំដែនអន្តរជាតិជាំស្រងាំ ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



រោងម៉ាស៊ីនកិនស្រូវ ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។
(ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រវត្តិសាស្ត្រឡើងវិញ ទោះបីមកទល់ពេលនេះយុវជនមួយចំនួនហាក់មិនទាន់ជឿទៅលើរឿងរ៉ាវដែលបានកើតឡើងពិតប្រាកដក្នុងសម័យកាលនោះយ៉ាងពេញលេញក៏ដោយ។

# គម្រោងប្រវត្តិសាស្ត្រគ្រួសារ នៅខេត្តព្រៃវែង ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១

សោម ប៊ុនថន, អ៊ុន សុដាវី និង ដារ៉ារដ្ឋ មេត្តា

## គោលបំណង

ប្រវត្តិសាស្ត្រគ្រួសារមានគោលបំណងលើកទឹកចិត្តឪពុកម្តាយ យាយតា និងចាស់ទុំ និយាយរៀបរាប់ពីរឿងរ៉ាវក្នុងរបបខ្មែរក្រហម ដែលខ្លួនធ្លាប់បានឆ្លងកាត់ប្រាប់ដល់កូនចៅជំនាន់ក្រោយៗ គម្រោងនេះនឹងផ្តល់ការយល់ដឹងកាន់តែច្បាស់លាស់អំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងគ្រួសារ ក្រៅពីការសិក្សារៀនសូត្រនៅក្នុងកម្មវិធីសិក្សាផ្លូវការនៅតាមសាលាចំណេះទូទៅរបស់រដ្ឋ ដែលជាមធ្យោបាយដើម្បីការពារក្រុមគ្រួសារ សហគមន៍ និងប្រទេសជាតិពីអំពើប្រល័យពូជសាសន៍។



ស៊ុំ សុភាព អាយុ៩៨ឆ្នាំ ជាមួយចៅទួតនៅផ្ទះរបស់គាត់ស្ថិតនៅក្នុងភូមិជើងទឹកក សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។ (សោម ប៊ុនថន, អ៊ុន សុដាវី, ដារ៉ា រដ្ឋមេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



១- ផ្លូវលំនៅក្នុងភូមិជើងទឹកខ សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។
២- ផ្ទះរបស់ មុំ សាមុត នៅក្នុងភូមិជើងទឹកខ សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។
៣- ប្តីរបស់ មុន សាមុត ទៅទទួលចៅៗត្រឡប់មកពីសាលារៀន។
៤- កញ្ចប់ រួមមាន នំ, ម៉ាស់, សាប៊ូលាងដៃ និងសៀវភៅទស្សនាវដ្តីស្វែងរកការពិត សម្រាប់យកទៅចែកជូនប្រជាជនដែលបានចូលរួមក្នុងគម្រោងប្រវត្តិសាស្ត្រគ្រួសារនៅខេត្តព្រៃវែង។

## ការជ្រើសរើសទីតាំង

ក្រុមការងារប្រវត្តិសាស្ត្រគ្រួសារបានជ្រើសរើសយកសង្កាត់ជើងទឹកនៅក្នុងក្រុងព្រៃវែង ខេត្តព្រៃវែង។ សង្កាត់ជើងទឹកមានចម្ងាយប្រមាណ៥គីឡូម៉ែត្រពីក្រុងព្រៃវែង និងធ្លាប់ជាតំបន់ប្រទាញប្រទង់ និងជាព្រំប្រទល់ខណ្ឌចែករវាងតំបន់គ្រប់គ្រងដោយរដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់ លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមនៅអំឡុងទសវត្សរ៍ឆ្នាំ១៩៧០។ ប្រជាជននៅក្នុងសង្កាត់ជើងទឹកបានទទួលរងគ្រោះដោយសារការទម្លាក់គ្រាប់បែក និងមួយចំនួនត្រូវបានខ្មែរក្រហមកៀរឲ្យទៅរស់នៅក្នុងតំបន់រំដោះ និងត្រូវបានចាត់តាំងឲ្យធ្វើការងារជាទម្ងន់ៗ បន្ទាប់ពីកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានអនុញ្ញាតឲ្យប្រជាជនដែលត្រូវបានជម្លៀសចេញពីផ្ទះចូលមករស់នៅសង្កាត់

ជើងទឹកវិញៗ នៅអំឡុងពេលមានការចោទប្រកាន់ពីមជ្ឈិមថា កងទ័ព និងកម្មាភិបាលភូមិភាគបូព៌ាមានគំនិតក្បត់ជាមួយវៀតណាម ប្រជាជនក្នុងសង្កាត់ជើងទឹកមួយចំនួនត្រូវបានសម្រិតសម្រាំង និងមួយចំនួនទៀតត្រូវបានជម្លៀសឲ្យទៅនៅដីខ្វាញ់ ក្នុងខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ។ ប្រជាជនដែលជម្លៀសទៅទាំងនោះ ត្រូវបានខ្មែរក្រហមប្រើឲ្យធ្វើការងារធ្ងន់ធ្ងរ ហើយមួយចំនួនត្រូវបានខ្មែរក្រហមចោទប្រកាន់ និងយកទៅសម្លាប់ចោល។

## ការធ្វើដំណើរ និងការជួបអាជ្ញាធរមូលដ្ឋាន



ជិន សុវណ្ណា អាយុ៦៦ឆ្នាំ បានរៀបរាប់ពីបទពិសោធន៍ផ្ទាល់ខ្លួននៅក្នុងរបបខ្មែរក្រហម រួមទាំងព្រឹត្តិការណ៍នៅក្នុងរបប លន់ នល់ និងការគ្រប់គ្រងរដ្ឋបាលក្នុងសង្កាត់ជើងទឹកប្រាប់ដល់ក្រុមការងារគម្រោងប្រវត្តិសាស្ត្រគ្រួសារ។ ស្រេង ម៉ាប់ (រូបឆ្វេង) ក្រុមប្រឹក្សាសង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។

### ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១

នៅវេលាម៉ោង៧ព្រឹកថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារគម្រោងប្រវត្តិសាស្ត្រគ្រួសាររួមមាន សោម ប៊ុនថន, អ៊ុន សុដាវី, ដារ៉ារដ្ឋ មេត្តា និង ឡុង អូន បានរៀបចំសៀវភៅទស្សនាវដ្ដីស្វែងរកការពិត, ម៉ាស់, សាប៊ូលាងដៃ និង នំ ដាក់លើរថយន្តដើម្បីយកទៅចែកជូនប្រជាជនដែលនឹងចូលរួមក្នុងគម្រោងប្រវត្តិសាស្ត្រគ្រួសារនៅខេត្តព្រៃវែង។ ក្រុមការងារបានធ្វើដំណើរតាមបណ្ដោយផ្លូវជាតិលេខ៨ បន្ទាប់មកបានបន្តមកផ្លូវជាតិលេខ ១១ ឆ្ពោះមកក្រុងព្រៃវែង។ ដោយសារអាកាសធាតុប្រែប្រួលក្នុងរយៈពេលពីរថ្ងៃកន្លងមក បុគ្គលិកក្នុងក្រុមការងារម្នាក់មានអាការៈគ្រុនផ្ដាសាយធំ ដូច្នេះនៅអំឡុងពេលធ្វើដំណើរ ក្រុមការងារបានពាក់ម៉ាស់ និងលាងដៃជាមួយអាកុលដើម្បីការពារការឆ្លងជំងឺគ្រុនផ្ដាសាយធំ និងជំងឺកូវីដ-១៩។

ក្រុមការងារបានមកដល់ទីរួមខេត្តព្រៃវែងនៅវេលាម៉ោង ១១៖០០ ដោយសុវត្ថិភាព។ បន្ទាប់មក សោម ប៊ុនថន អ្នកដឹកនាំក្រុមបានទំនាក់ទំនងទៅចៅសង្កាត់ជើងទឹកក្នុងក្រុងព្រៃវែង ដើម្បីសុំអនុញ្ញាតណាត់ជួប និងសុំការណែនាំពីចៅសង្កាត់ទៅសម្ភាសន៍ប្រជាជននៅក្នុងមូលដ្ឋានសង្កាត់ជើងទឹក។ បន្ទាប់ពីហូបអាហារថ្ងៃត្រង់រួច ក្រុមការងារបានរៀបចំច្រក នំ, ម៉ាស់, សាប៊ូលាងដៃ និងសៀវភៅបានចំនួន ១០ កញ្ចប់។

នៅវេលាម៉ោង ២៖៣០ រសៀល ក្រុមការងារគម្រោងប្រវត្តិសាស្ត្រគ្រួសារ បានទៅជួប ចៅសង្កាត់ជើងទឹកឈ្មោះ ជិន សុវណ្ណា នៅសាលាសង្កាត់។ នៅក្នុងឱកាសនោះ ក្រុមការងារបានជួប ស្រេង ម៉ាប់ ក្រុមប្រឹក្សាសង្កាត់ជើងទឹក (ស្រេង ម៉ាប់ គឺជាកូនរបស់ ប៊ួយ ស្រេង អតីតអ្នកបោះពុម្ពការសែត និងត្រូវជាប្អូនថ្លៃរបស់ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទីស្ដីការគណរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលធ្លាប់បានផ្ដល់បទសម្ភាសន៍អំពីរឿងរ៉ាវគ្រួសាររបស់គាត់ក្នុងរបបខ្មែរក្រហមដល់ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីសរសេរអត្ថបទ និងចងក្រងជាសៀវភៅដែលមានចំណងជើងថា «ដេះដង់ធូលី» ហើយក្រុមការងារបានជូនអត្ថបទ និងរូបថតក្រុមគ្រួសាររបស់គាត់ ដល់គាត់នៅពេលនោះ) លោកប៊ូ ហ៊ានជំនួយការសង្កាត់ជើងទឹក និងលោក សួង ថុន មេភូមិជើងទឹក។ អ្នកទាំង៤នាក់បានសង្ខេប និងរៀបរាប់ពីបទពិសោធន៍ផ្ទាល់ខ្លួននៅក្នុងរបបខ្មែរក្រហម រួមទាំងព្រឹត្តិការណ៍នៅក្នុងរបប លន់ នល់ និងការគ្រប់គ្រងរដ្ឋបាលក្នុងសង្កាត់ជើងទឹកប្រាប់ដល់ក្រុមការងារគម្រោងប្រវត្តិសាស្ត្រគ្រួសារ។

ជិន សុវណ្ណា អាយុ៦៦ឆ្នាំ គឺជាចៅសង្កាត់ជើងទឹក បានមានប្រសាសន៍ថា សង្កាត់របស់គាត់មានប្រជាជនចំនួន១៨៣២ គ្រួសារ ស្មើនឹង ៦០៩០នាក់។ ជិន សុវណ្ណា បានបន្តថា ថ្មីៗនេះមានប្រជាពលរដ្ឋដែលបានទៅធ្វើការនៅប្រទេសថៃបានវិលត្រឡប់មកសង្កាត់ជើងទឹកវិញ ក្នុងចំណោមពលករចំណាកស្រុកត្រឡប់មកវិញទាំងនោះ លោកបានរាយការណ៍ទៅថ្នាក់លើឲ្យយកទៅធ្វើចត្តាឡីស័កបានចំនួន ៦០នាក់ ដោយសារលោកមានការបារម្ភនិងភ័យខ្លាចការឆ្លងរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងសហគមន៍របស់លោក។ លោកបានបន្ថែមថា សង្កាត់ជើងទឹកមាន ៥ភូមិ គឺ ១) ភូមិជើងទឹកក ២) ភូមិជើងទឹកខ ៣) ភូមិស្វាយសុខោ ៤) ភូមិកំពង់អាទុង និង៥) ភូមិឯករាម។ នៅក្នុងសង្កាត់ជើងទឹក មានអនុវិទ្យាល័យមួយ និងសាលាបឋមសិក្សាពីរកន្លែង។

លោក ជិន សុវណ្ណា បានបន្តថានៅក្នុងរបប លន់ នល់ គាត់គឺជាសិស្សសាលានៅក្រុងព្រៃវែង។ នៅពេលរបបខ្មែរក្រហមឡើងគ្រប់គ្រងអំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គាត់ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅនៅភូមិខ្មោក ឃុំពពឹស ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង ដោយខ្មែរក្រហមបានចោទគាត់ថា គឺជាប្រជាជន ១៧ មេសា និងជាអនុធនសិស្ស។ មួយរយៈក្រោយមកគាត់ត្រូវបានជម្លៀសឲ្យទៅនៅដីខ្សាញ់ ក្នុងខេត្តពោធិ៍សាត់ ភូមិភាគពាយព្យ។ នៅទីនោះ គាត់ត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើការងារយ៉ាងធ្ងន់ធ្ងរ។ បងបង្កើតរបស់គាត់ពីរនាក់ រួមទាំងបងថ្លៃរបស់គាត់ពីរនាក់ទៀតបានស្លាប់នៅទីនោះ។ នៅដើមឆ្នាំ១៩៧៩ បន្ទាប់ពីកងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាវាយចូលមក គាត់ត្រូវបានខ្មែរក្រហមរៀបចំឲ្យមានគ្រួសារ។ នៅក្នុងឱកាសរៀបចំពិធីរៀបការរបស់គាត់ ខ្មែរក្រហមបានរៀបចំរៀបការឲ្យប្រជាជនចំនួន១៩គូផ្សេងទៀត។ នៅក្នុងចំណោមគ្រួសារ ទាំង២០គូ រួមទាំងគាត់នៅពេលនោះ នៅសល់តែពីរគូប៉ុណ្ណោះ ដែលនៅរស់រានមានជីវិតមកដល់សព្វថ្ងៃ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ។




១- ស្រេង ម៉ាប់ អាយុ១២ឆ្នាំ នៅឆ្នាំ១៩៧៤។
២- បួយ ស្រេង អាយុប្រហែល៤០ឆ្នាំ អំឡុងពេលឈរឈ្មោះជាតំណាងរាស្ត្រក្នុងរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់។
៣- កង សុជាត ប្រពន្ធរបស់ បួយ ស្រេង។
៤- កង សុជាត និងកូនៗចំនួន៣នាក់ នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៦០។



ប៊ូ ហ៊ាន ជំនួយការសង្កាត់ជើងទឹក, ស្រេង ម៉ាប់ ក្រុមប្រឹក្សាសង្កាត់ជើងទឹក, ជិន សុវណ្ណា ចៅសង្កាត់ជើងទឹក និង សួង ថុន មេភូមិជើងទឹកខ ជួបជាមួយក្រុមការងារគម្រោងប្រវត្តិសាស្ត្រគ្រួសារ។



សាលាសង្កាត់ជើងទឹក។

# ការចុះទៅសម្ភាសន៍ និងការសន្ទនារឿងរ៉ាវប្រជាជន

ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារគម្រោងប្រវត្តិសាស្ត្រគ្រួសារ បានសម្ភាសន៍៖

## ហ៊ិន អូន ត្រូវជាកូនរបស់ មិន ហុង៖

ហ៊ិនអូនមានអាយុ៥១ឆ្នាំ រស់នៅភូមិជើងទឹក១ សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។ ហ៊ិន អូន បានរៀបការជាមួយ ទ្រៀ ប្រាំង អាយុ៥៣ឆ្នាំ ប្រកបរបរធ្វើស្រែ។ ហ៊ិន អូន បានរៀបរាប់ថា ខ្ញុំបានទៅរៀនជាមួយក្មេងៗផ្សេងទៀត ដោយមានខ្មែរក្រហមគឺជាអ្នកបង្រៀន។ គ្រូបានបង្រៀនខ្ញុំឲ្យអានព្យញ្ជនៈ ក, ខ ប៉ុន្តែខ្ញុំមិនចេះច្រើនទេ។ រាល់ថ្ងៃខ្ញុំដឹងតែទៅរៀន ប៉ុន្តែខ្ញុំមិនសូវចងចាំ ព្រោះខ្ញុំនៅតូចពេក។ ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យជញ្ជូនអាចម៍ក្របី។ កងកុមាររបស់ខ្ញុំមានគ្នាប្រហែលជា ៣០នាក់។ មានក្មេងខ្លះឈឺដេកស្លាប់ ទាំងម្តាយមិនដឹងផង។ ជំនាន់នោះ ខ្ញុំមិនសូវនឹកនាម្តាយរបស់ខ្ញុំទេ ព្រោះការងាររបស់ខ្ញុំលំបាកខ្លាំងពេក។ អ្នកគ្រប់គ្រងនៅកន្លែងដែលខ្ញុំរស់នៅគឺមានប្រធានកងស្រី និងប្រធានកងប្រុស។ ខ្ញុំនៅចងចាំតិចតួចតែប៉ុណ្ណោះ។ សព្វថ្ងៃនេះ ខ្ញុំមានអាយុ៥១ឆ្នាំហើយ។ ខ្ញុំត្រូវបានជម្លៀសឲ្យទៅរស់នៅក្នុងខេត្តពោធិ៍សាត់រហូតដល់ពេលកងទ័ពវៀតណាមវាយចូលមក។ បងប្រុសរបស់ខ្ញុំបានមកយកខ្ញុំចេញពីកង ព្រោះគាត់ស្គាល់កន្លែងដែលខ្ញុំរស់នៅ រួចយើងនាំគ្នាដើរទៅរកម្តាយជាមួយគ្នា។ ខ្ញុំកើតទាន់របបខ្មែរក្រហម ប៉ុន្តែខ្ញុំមិនសូវដឹងនិងចងចាំរឿងរ៉ាវទាំងអស់នោះទេ។ សព្វថ្ងៃនេះកូនច្បងរបស់ខ្ញុំមានអាយុ២៧ឆ្នាំ។ ខ្ញុំមានកូនចំនួន៥នាក់ ស្រី១នាក់ និងប្រុស៤នាក់។ កូនរបស់ខ្ញុំ២នាក់កំពុងរៀននៅសាលា ក្រៅពីនោះកូនរបស់ខ្ញុំចេញទៅធ្វើការងារនៅក្រៅផ្ទះ។ ខ្ញុំមិនចង់ឲ្យរបបខ្មែរក្រហមកើតឡើងទេ។ ទោះបីជាខ្ញុំកើតទាន់របបខ្មែរក្រហមក៏ដោយ ប៉ុន្តែខ្ញុំមិនដែលដឹងរឿងអ្វីអំពីឪពុកម្តាយរបស់ខ្ញុំទេ ព្រោះខ្ញុំនៅតូចពេក។ ពេលខ្ញុំនឹកឃើញដល់សម័យខ្មែរក្រហម គឺខ្ញុំនឹកឃើញការលំបាកខ្លាំង។ ពីមុនខ្ញុំមិនដឹងសុខទុក្ខឪពុកយ៉ាងណានោះទេ ខ្ញុំទើបតែដឹងនៅពេលម្តាយខ្ញុំនិយាយ។ ខ្ញុំមិនដឹងថាម្តាយខ្ញុំទៅដកប្រឡាយ ឬរែកដីទេ ហើយខ្ញុំក៏មិនដឹងថាម្តាយរបស់ខ្ញុំនឹកខ្ញុំដែរ។ ខ្ញុំទើបតែដឹងរឿងរ៉ាវពីឪពុករបស់ខ្ញុំច្បាស់នៅថ្ងៃនេះ និងមិនដឹងថាខ្មែរក្រហមបានយកឪពុករបស់ខ្ញុំទៅសម្លាប់ទេ។ ខ្ញុំនៅចងចាំថាឪពុកខ្ញុំមានកង់មួយគ្រឿងឌុបអីវ៉ាន់ នៅពេលដែលយើងត្រូវបានខ្មែរក្រហមជម្លៀសចេញពីភ្នំពេញមកកាន់ខេត្តព្រៃវែង។ ឪពុករបស់ខ្ញុំធ្វើជាប៉ូលិសនៅក្នុងជំនាន់សម្តេចព្រះនរោត្តម សីហនុ និងក្រោយមកផ្លាស់ប្តូរទៅធ្វើជាទាហាននៅក្នុងរបប លន់ នល់ វិញ។



១- ហ៊ិន អូន មានអាយុ៥១ឆ្នាំ រស់នៅភូមិជើងទឹក១ សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។
២-មិន ហុង អាយុ៧៥ឆ្នាំ ត្រូវជាម្តាយរបស់ ហ៊ិន អូន រស់នៅភូមិជើងទឹក១ សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។
៣-មិន ហុង និង ហ៊ិន អូន រៀបរាប់ពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមប្រាប់ដល់ក្រុមការងារគម្រោងប្រវត្តិសាស្ត្រគ្រួសារ។

## មិន ហុង

មិន ហុង អាយុ៧៥ឆ្នាំ ត្រូវជាម្តាយរបស់ ហ៊ិន អូន រស់នៅភូមិជើងទឹក១ សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង បានរៀបរាប់ថា ខ្ញុំត្រូវបានជម្លៀសពីភ្នំពេញមកនៅស្រុកស្វាយអន្ទរ នៅពេលយោធាខ្មែរក្រហមចូលមកក្រុងភ្នំពេញ ឆ្នាំ១៩៧៥។ នៅទីនោះខ្ញុំគ្មានអ្វីហូបគ្រប់គ្រាន់នោះទេ។ ខ្ញុំបានទៅជីកប្រឡាយដោយមានមេភូមិដឹកនាំ។ ខ្ញុំធ្វើការនៅទីនោះលំបាកណាស់។ ជួនកាល ខ្ញុំ




១- ផ្ទះរបស់ មិន ហុង។
២-មិន ហុង ចិញ្ចឹមក្របីសម្រាប់ភ្ជួររាស់ និងលក់ផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ។
៣- គោយន្តសម្រាប់ភ្ជួររាស់ និងដឹកជញ្ជូនស្រូវ និងផលិតផលកសិកម្មនៅផ្ទះរបស់គាត់។

បានទៅស្ទូង និងទៅប្រមូលស្រូវនៅវាលស្រែនៅពេលថ្ងៃ និងពេលយប់ដោយគ្មានពេលទំនេរឡើយ។ ថ្ងៃមួយ ខ្ញុំបានឈឺសម្រាកព្យាបាលនៅពេទ្យភូមិ ហើយខ្មែរក្រហមបានបញ្ជូនខ្ញុំបន្តមកពេទ្យធំ នៅស្រុកស្វាយអន្ទរ។ ខ្ញុំដេកពេទ្យរយៈពេលកន្លះខែដោយសារខ្ញុំឈឺរាកមួល។ ពេទ្យយកថ្នាំបុរាណមួយត្រឡោកមកឲ្យខ្ញុំលេប។ ថ្នាំទាំងនោះមិនសូវត្រូវជាមួយជំងឺរបស់ខ្ញុំទេ។ ខ្ញុំឈឺស្គម ហូបបាយមិនបានឡើយ។ ខ្ញុំគ្មានសាច់ញាតិទៅមើលថែទាំខ្ញុំទេ។ ខ្ញុំសម្រាកព្យាបាលនៅពេទ្យជាមួយអ្នកជំងឺផ្សេងទៀត។ ពេលត្រឡប់ទៅផ្ទះវិញ ប្រធានភូមិមិនឲ្យខ្ញុំសម្រាកឡើយ។ ឪពុកខ្ញុំស្លាប់ហើយនៅពេលនោះ។ គាត់ឈឺជំងឺទឹកនោមផ្អែម។ ពេលនោះ ម្តាយនិងឪពុករបស់ខ្ញុំរស់នៅជាមួយគ្នានៅក្រុងព្រៃវែង ចំណែកខ្ញុំរស់នៅក្រុងភ្នំពេញជាមួយប្តី។ ខ្ញុំបានមកលេងឪពុកម្តាយរបស់ខ្ញុំម្តង ហើយពេលមកដល់ ខ្ញុំឃើញអ្នកទាំងពីរធ្វើកូនខ្ទមតូចមួយរស់នៅ។ ខ្ញុំបានសួរឪពុកម្តាយរបស់ខ្ញុំថាមូលហេតុអ្វីបានជាមកស្នាក់នៅខ្ទម ហើយគាត់បានប្រាប់ខ្ញុំថា ផ្ទះបានឆេះអស់ដោយសារការទម្លាក់គ្រាប់បែក។ ខ្ញុំបានមកលេងឪពុកម្តាយខ្ញុំបានតែម្តងប៉ុណ្ណោះ ហើយបានបែកគ្នារហូតមក។

មួយរយៈក្រោយមក ខ្មែរក្រហមបានជម្លៀសខ្ញុំចេញពីស្រុកស្វាយអន្ទរឲ្យទៅរស់នៅខេត្តពោធិ៍សាត់វិញ ដោយខ្មែរក្រហមបានឃោសនាថា នៅទីនោះសម្បូរហូប និងសម្បូរផ្លែឈើ។ ខ្ញុំបានដើរកាត់តាមក្រុងព្រៃវែង ឆ្ពោះទៅអ្នកលឿង រួចហើយដើរបន្តទៅភ្នំពេញ។ បន្ទាប់មកខ្ញុំជិះរថភ្លើងទៅខេត្តពោធិ៍សាត់។ ពេលទៅដល់ទីនោះ ខ្ញុំឃើញមានរោងវែងៗសម្រាប់ទុកឲ្យប្រជាជនជម្លៀសស្នាក់នៅ។ ប្រជាជននៅទីនោះភាគច្រើនមកពីខេត្តព្រៃវែង ប៉ុន្តែគ្រួសាររបស់ខ្ញុំរួមមាន កូនប្រុសច្បង កូនស្រី និង ខ្ញុំ ត្រូវបានបំបែកឲ្យរស់នៅដាច់ដោយឡែកពីគ្នា។ បើប្រៀបធៀបយើងរស់នៅស្វាយអន្ទរ គឺស្វាយអន្ទរប្រសើរជាង។

ពេលនៅពោធិ៍សាត់ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យទៅលើកអាងទំនាញ។ បន្ទាប់មកខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យជញ្ជូនស្បៀងដាក់ក្នុងជង្រុកស្រូវ ស្ថិតនៅក្បែរអាងទំនាញ។ ខ្ញុំមិនស្គាល់ប្រធានកង ប្រធានភូមិនៅទីនោះទេ។ មួយថ្ងៃខ្ញុំទទួលបានរបបអាហារពីរពេល។ ពេលខ្លះខ្ញុំបានយករបបអាហាររបស់ខ្ញុំដែលមានបាយមួយវែកទៅចែកគ្នាជាមួយកូន ៣ នាក់ទៀត។ នៅពេលខ្ញុំបែកពីកូន ខ្ញុំនឹកពួកវាខ្លាំងណាស់ ប៉ុន្តែមិនដឹងធ្វើយ៉ាងម៉េច។ កូនរបស់ខ្ញុំបានមកលេងខ្ញុំចំនួន ២ដង។

ខ្ញុំបាននឹកឃើញរឿងមួយពេលខ្ញុំរស់នៅស្រុកស្វាយអន្ទរ គឺខ្ញុំបានវាយកូនច្បងរបស់ខ្ញុំដោយសារខ្ញុំខឹងវា ដែលហាមមិនឲ្យទៅមើលគេប្រជុំ ហើយវាមិនស្តាប់ខ្ញុំ។ ខ្មែរក្រហមបានហៅខ្ញុំទៅអប់រំ និងហាមមិនឲ្យខ្ញុំវាយកូនទៀត។

នៅពេលកងទ័ពវៀតណាមវាយចូលមកប្រទេសកម្ពុជា ខ្ញុំមិនដឹងថា ទៅតាមរកកូននៅទីណាឡើយព្រោះយើងធ្វើការបែកពីគ្នា។ ខ្ញុំបានជួបកូនខ្ញុំទាំងពីរនាក់នៅតាមផ្លូវត្រឡប់មកស្រុកកំណើតវិញ។ នៅតាមផ្លូវ យើងបានដើរសុំអង្ករពីប្រជាជននៅតាមភូមិដើម្បីដាំហូប រហូតដល់យើងមកដល់ស្រុកកំណើតនៅខេត្តព្រៃវែង។

ដំបូងខ្ញុំបានមកស្នាក់នៅផ្ទះអ៊ំស្រីរបស់ខ្ញុំបណ្តោះអាសន្នសិន។ រយៈពេលប្រហែល ២ទៅ ៣ថ្ងៃ ក្រោយមក

ខ្ញុំបាននាំកូនទៅកាប់ដើមឈើតូចៗដើម្បីធ្វើគ្រែ និងធ្វើខ្ទមរស់នៅជាមួយកូន ៣នាក់ទៀត។ ខ្ញុំបានធ្វើស្រែជាមួយកូនៗ ក្រោយមកកូនៗរបស់ខ្ញុំបានចូលរៀន ដោយកូនស្រីបានរៀនដល់ថ្នាក់ទី៥ ទើបឈប់មកជួយការងារខ្ញុំវិញ។ ចំណែកកូនប្រុសរៀនបានចប់ថ្នាក់ទី១២។

សព្វថ្ងៃ ខ្ញុំមានចៅ៨នាក់។ ខ្ញុំតែងតែនិយាយរឿងរ៉ាវរបស់ខ្ញុំប្រាប់ចៅៗ ប៉ុន្តែចៅៗ មិនសូវជឿខ្ញុំឡើយ។

## ឌី ដួប ភេទស្រី អាយុ៧៥ឆ្នាំ ត្រូវជាយាយរបស់ ម៉ុន សម័យ

ឌី ដួប រស់នៅភូមិជើងទឹក២ សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង បានរៀបរាប់ថា ខ្ញុំមានម្តាយឈ្មោះ អ៊ួង នាង និងឪពុកឈ្មោះ សក់ ឌី។ ខ្ញុំមិនចេះអក្សរទេ។ ម្តាយរបស់ខ្ញុំមានកូនចំនួន៧នាក់ គឺ ១) ឈ្មោះ សក់ ដុង ប្រុស (ស្លាប់) ២) សក់ ហុង ប្រុស (ស្លាប់), ៣) សក់ ហ៊ន, ៤) សក់ ហឿន ប្រុស (ស្លាប់), ៥) ខ្ញុំ, ៦) សក់ លន និង ៧) ប្អូនរបស់ខ្ញុំម្នាក់ទៀតស្លាប់តាំងពីកើតមក។ ក្នុងចំណោមបងប្អូនទាំងអស់នោះមានម្នាក់ឈ្មោះ ហ៊ន ធ្វើពេទ្យ និង លន ធ្វើជាគ្រូបង្រៀន រៀនបានច្រើនជាងគេ។ សម័យនោះ ខ្ញុំនៅឃ្វាលក្របី និងបេះបន្លែយកទៅលក់នៅផ្សារ ចំណែកម្តាយ និងឪពុករបស់ខ្ញុំបានស្លាប់ដោយសារជំងឺ។ ខ្ញុំមានកូនចំនួន៣នាក់ ស្រី២នាក់ និងប្រុស១នាក់។ ប្តីរបស់ខ្ញុំឈ្មោះ គេង វន។ ខ្ញុំនិងប្តី គឺជាជីដូនមួយនឹងគ្នា។ ខ្ញុំរៀបការតាំងពីអាយុ ១៥ឆ្នាំ នៅក្នុងសម័យសង្គមរាស្ត្រនិយម។ នៅពេលរបបខ្មែរក្រហមគ្រប់គ្រងអំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជននៅក្នុងក្រុងព្រៃវែង ត្រូវបានខ្មែរក្រហមចាត់ទុកថា គឺជាប្រជាជន ១៧ មេសា ដែលត្រូវជម្លៀសឲ្យទៅនៅភូមិខ្វាក ឃុំពពឺស ស្រុកស្វាយអន្ទរ។

ប្តីរបស់ខ្ញុំធ្វើជាទាហាន លន់ នល់។ ពេលខ្ញុំកំពុងតែនៅធ្វើស្រែប្រាំង ខ្ញុំបានឃើញទាហានម្នាក់ឈ្មោះ ចន ដោតទង់ជ័យស នៅកណ្តាលវាលស្រែ។ ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសចេញដោយមានតែអាវនិងខោប៉ុណ្ណោះ។ ម្តាយក្មេករបស់ខ្ញុំគឺជាអ្នកយកអីវ៉ាន់ទុកឲ្យខ្ញុំ។ នៅពេលខ្មែរក្រហមជម្លៀសប្រជាជនចេញជិតអស់ហើយ ទើបខ្ញុំត្រឡប់មកពីធ្វើស្រែប្រាំងវិញ។ កងទ័ពរំដោះខ្មែរក្រហមបានបោះទីតាំងជិតក្រុងព្រៃវែង។ កងទ័ពរំដោះទាំងនោះមិនបានធ្វើបាបខ្ញុំទេ ប៉ុន្តែបានចង្អុលបង្ហាញទិសដៅឲ្យខ្ញុំទៅ។ ខ្ញុំបានដើរសួរប្រជាជនថា មានឃើញប្តី កូនៗ និងម្តាយក្មេកខ្ញុំទេ។ ប្រជាជនបានប្រាប់ខ្ញុំថា ប្តីរបស់ខ្ញុំទៅចាំខ្ញុំនៅស្ពានលេខ ១ ។ ខ្ញុំបានបែកប្តីរបស់ខ្ញុំតាំងពីពេលនោះមក។ ខ្ញុំបានជួបម៉ែក្មេកនៅវត្តថ្នល់ជ័យ។ ខ្ញុំមានកូនពីរនាក់ហើយ គឺកូនម្នាក់ក្នុងពោះមានអាយុ៣ខែ។ ពេលនោះខ្ញុំមិនដឹងថាខ្ញុំមានផ្ទៃពោះទេ ខ្ញុំស្មានតែខ្ញុំធាត់។ រយៈពេលប្រាំខែក្រោយមកទើបខ្ញុំដឹងថា ខ្ញុំមានទម្ងន់កូន។ ខ្ញុំបានដេកនៅវត្តមួយយប់ បន្ទាប់មកទៅនៅព្រៃកិច ក្នុងភូមិខ្វាក ឃុំពពឺស ស្រុកស្វាយអន្ទរ។ មេភូមិចែកអង្ករឲ្យ ខ្ញុំហូបរយៈពេលមួយអាទិត្យ បន្ទាប់មកបន្ថយរបបបន្តិចម្តងៗ ហើយក្រោយមកយើងហូបបាយរួមៗ ម្តាយក្មេករបស់ខ្ញុំនៅជាមួយខ្ញុំនៅពេលនោះ។ ប្រជាជននៅទីនោះបានខសត្វពស់ឲ្យខ្ញុំហូប។ កន្លះខែ ឬមួយខែម្តង ប្រធានរោងបាយធ្វើបង្អែម និងស៊ុបឲ្យខ្ញុំហូបដែរ។ ខ្ញុំបានហូបឆ្អែត។ នៅភូមិខ្វាកសម្បូរផ្លែឈើណាស់។

ពេលទៅដល់ដំបូង មេភូមិបានសាកល្បងឲ្យខ្ញុំជាន់រហាត់ទឹក ហើយបានប្រកាសថា ប្រសិនបើនរណាជាន់បានលេខមួយនឹងទទួលបានរង្វាន់ក្រមាមួយ។ ខ្ញុំទទួលបាន




១- ក្រុមការងារគម្រោងប្រវត្តិសាស្ត្រគ្រួសារជួប ឌី ដួប និងចៅស្រីនៅផ្ទះរបស់គាត់ស្ថិតនៅភូមិជើងទឹក២ សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។

២- ឌី ដួប ភេទស្រី អាយុ៧៥ឆ្នាំ ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ក្រុមការងារគម្រោងប្រវត្តិសាស្ត្រគ្រួសារ។

៣-អ៊ុន សុដាវី សមាជិកក្រុមការងារជូនកញ្ចប់រួមមាន នំ, ម៉ាស់, សាប៊ូលាងដៃ និងសៀវភៅទស្សនាវដ្តីស្វែងរកការពិត ដល់លោកយាយ ឌី ដួប។

ក្រមាចំនួន ២ ព្រោះខ្ញុំទៅដាន់ទឹក២ដងៗ ពេលខ្ញុំទទួលបានក្រមាខ្ញុំសប្បាយចិត្តខ្លាំងណាស់ៗ នៅពេលប្រជុំប្រធានភូមិបានលើកសរសើរខ្ញុំនៅក្នុងអង្គប្រជុំៗ បន្ទាប់មកប្រធានកងឲ្យសម្រាកការងារមួយថ្ងៃៗ តាណម គឺជាមេភូមិរបស់ខ្ញុំ ប៉ុន្តែគាត់ស្លាប់ហើយៗ ពេលមេភូមិដឹងថាខ្ញុំមានផ្ទៃពោះ គាត់ក៏មិនសូវប្រើខ្ញុំឲ្យធ្វើការដែរៗ

យាយ ចឹង គឺជាឆ្មបបុរាណដែលជួយបង្កើតកូនឲ្យខ្ញុំៗ ខ្ញុំបានអាំងភ្លើងដោយសារមានអ្នកជិតខាងជួយរកខសឲ្យ បន្ទាប់មកទើបខ្ញុំបានទៅសុំថ្នាំពីពេទ្យមកលេបៗ កាលខ្ញុំឆ្លងទន្លេម្ដាយក្មេករបស់ខ្ញុំក៏នៅជាមួយខ្ញុំដែរៗ

ក្រោយមក មេភូមិហៅខ្ញុំទៅធ្វើការវិញ ប៉ុន្តែកូនខ្ញុំយំមិនឈប់ ហើយគ្មាននរណាអាចមើលថែវាបាន ទើបខ្ញុំសុំប្រធានភូមិចេញពីទីនោះទៅនៅកន្លែងផ្សេងវិញៗ តាណម មានតួនាទីធំជាងគេនៅក្នុងភូមិៗ ខ្ញុំបានលួចដាំដំណាំ និងលួចស្ងោរមាន់ដាក់នៅក្នុងកំសៀវៗ

ខ្ញុំនៅមើលកូនរបស់ខ្ញុំ ហើយមិនយូរប៉ុន្មានខ្ញុំត្រូវបានចាត់តាំងឲ្យទៅកាប់ខសដោយមានមនុស្ស ៤ទៅ៥នាក់ និងមានរទេះ២គ្រឿងៗ

ពេលមានព្រឹត្តិការណ៍តាមចាប់ សោ ភឹម ខ្មែរក្រហមបានហៅប្រជាជនមកប្រជុំនៅវត្តថ្នល់ជ័យ ហើយបានប្រកាសប្រាប់ប្រជាជនថា ប្រសិនបើទៅរស់នៅខេត្តពោធិ៍សាត់ នឹងមិនខ្វះអាហារហូបឡើយៗ ក្រុមគ្រួសាររបស់ខ្ញុំចុះឈ្មោះទាំងអស់គ្នាទៅរស់នៅខេត្តពោធិ៍សាត់ៗ នៅពេលនោះខ្មែរក្រហមបានយករទេះគោមកដឹកក្រុមគ្រួសារខ្ញុំទៅដាក់ត្រឹមអ្នកលឿង ខ្ញុំបានជិះកប៉ាល់បន្តទៅច្បារអំពៅៗ ខ្មែរក្រហមបានដាំបាយឲ្យខ្ញុំហូប ហើយពេលល្ងាច ខ្មែរក្រហមយកឡានមកដឹកខ្ញុំពីក្បាលថ្នល់ទៅដាក់នៅចំណតរថភ្លើង ក្នុងក្រុងភ្នំពេញៗ ខ្ញុំបានជិះរថភ្លើងទៅពោធិ៍សាត់ៗ នៅវេលាម៉ោង ៦ យប់ ខ្ញុំបានទៅដល់ព្រៃស្វាយៗ ខ្ញុំទៅដល់ទីនោះចំរដូវច្រូតកាត់ៗ អ្នកស្វាយរៀងលួចប្រាប់ថា ពេលច្រូតស្រូវរួច ខ្មែរក្រហមនឹងសម្លាប់យើងមិនខានៗ បន្ទាប់មក ខ្ញុំត្រូវបានផ្លាស់ឲ្យទៅរស់នៅម្តុំចាមរអាវិញៗ ខ្ញុំមានការលំបាកខ្លាំងណាស់ ព្រោះមិនបានហូបគ្រប់គ្រាន់ដូចខ្មែរក្រហមបានឃោសនាឡើយៗ ប្រជាជនជាច្រើនគ្រួសារមកពីខេត្តស្វាយរៀងត្រូវបានសម្លាប់នៅទីនោះៗ




១- អង្ករដំណើបជាមួយត្នោតដែលកូររួចដើម្បីទុកវេចនំៗ
២- ត្នោតទុំសម្រាប់ទុកធ្វើនំៗ
៣- ចៅប្រុសយាយ ឌី ដួប កូរអង្ករដំណើរលាយជាមួយត្នោតដើម្បីទុកវេចនំៗ
៤- ឆ្នាំងស់ម្រាប់ស្ងោរនំត្នោតៗ

ម្តាយក្មេករបស់ខ្ញុំបានស្លាប់នៅព្រៃស្វាយ ដោយសារជំងឺចាស់ជរា បន្ទាប់ពីរបបខ្មែរក្រហមដួលរំលំរយៈពេល ៣ថ្ងៃៗ សាកសពរបស់គាត់ត្រូវបានកប់នៅវត្តព្រៃស្វាយ ចំណែកឪពុកធំរបស់ខ្ញុំបានស្លាប់នៅចាមរអាៗ បន្ទាប់មកខ្មែរក្រហមបានផ្លាស់ខ្ញុំចេញពីចាមរអា ឲ្យទៅនៅបឹងស្គាស្ថិតនៅក្បែរភ្នំ ១០០ ស្រទាប់វិញៗ ខ្ញុំទទួលបានបាយក្នុងម្នាក់៣ដុំៗ ខ្ញុំទៅបឹងស្គាបានរយៈពេល៣ថ្ងៃ ទើបកងទ័ពវៀតណាមវាយចូលមកដល់ៗ ខ្ញុំបានដើរដោយគ្មានទ្រនាប់ជើង ដូច្នេះបាតជើងរបស់ខ្ញុំឡើងក្រហមដូចរលាកភ្លើងៗ ខ្ញុំជាមួយកូនបានដើររយៈពេល ៣ខែ ចេញពីព្រៃស្វាយ មកដល់ក្រុងព្រៃវែងៗ មានប្រជាជនខ្លះបានស្លាប់នៅតាមផ្លូវៗ ខ្ញុំនៅតែខ្លាចយោធាខ្មែរក្រហមបាញ់ប្រហារនៅពេលព្រលប់ៗ នៅពេលថ្ងៃត្រង់យើងមិនអាចដើរបានទេព្រោះអាកាសធាតុក្តៅខ្លាំងណាស់ៗ យើងរុញរទេះដាក់អីវ៉ាន់មួយរហូតដល់ស្រុកកំណើតនៅក្រុងព្រៃវែងៗ ពេលខ្ញុំមកដល់ភូមិជើងទឹកខនេះ ជំបូងមិនមានផ្ទះសម្បែងនៅសេសសល់ឡើយៗ គ្រួសាររបស់ខ្ញុំខ្វះខាតខ្លាំងណាស់ៗ ខ្ញុំបានសង់ខ្ទមនៅជាមួយបងថ្លៃ ហើយក្រោយមកបែកមកនៅផ្ទះខ្លួនឯងរហូតមកដល់សព្វថ្ងៃនេះៗ

(តនៅលេខក្រោយ)

# វេទិកាសហគមន៍ភូមិទំនប់លើ

ហ៊ាន ពិសី



*ប្រជាជនចំនួន ១៨នាក់ នៅភូមិទំនប់លើ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ចូលរួមវេទិកាសហគមន៍ដើម្បីលើកកម្ពស់ការយល់ដឹង និងពិភាក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលហៅកាត់ថា (អ.វ.ត.ក ឬសាលាក្តីខ្មែរក្រហម)។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅព្រឹកថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំវេទិកាសហគមន៍នៅក្នុងភូមិទំនប់លើ នៃស្រុកអន្លង់វែង ដោយមានការចូលរួមពីសំណាក់ប្រជាជនចំនួន ១៨នាក់ ( ប្រុស៩នាក់ និងស្រី៩នាក់)។ វេទិកានេះត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់ការយល់ដឹង និងពិភាក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ព្រមទាំងលើកយកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលហៅកាត់ថា (អ.វ.ត.ក ឬសាលាក្តីខ្មែរក្រហម)។ វេទិកានេះបង្កលទ្ធភាពឲ្យអ្នកភូមិសំដែងមតិយោបល់អំពីបញ្ហាប្រឈមនានានៅក្នុងសហគមន៍។ ការពិភាក្សាអំពីផ្នែកប្រវត្តិសាស្ត្រនេះក៏បានរំលេចឡើងតាមរយៈការចែករំលែកជាមួយសាច់រឿង ក៏ដូចជាបទពិសោធន៍ជីវិតរបស់ប្រជាជនដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម។

នៅមុនពេលវេទិកា អ្នកចូលរួមមួយចំនួនបានអញ្ជើញមកដល់មុនកម្មវិធី និងអញ្ជើញមកជាបន្តបន្ទាប់ និងស្វាគមន៍រាក់ទាក់គ្នាទៅវិញទៅមក។ ក្រុមការងារមជ្ឈ-

មណ្ឌលសន្តិភាពអន្លង់វែង ក៏ចាប់ផ្តើមចែកកាហ្វេ តែ និងនំដើម្បីពិសារ ខណៈដែលអាកាសធាតុធ្លាក់ចុះជាង ១០ អង្សាសេ នៅក្នុងស្រុកអន្លង់វែងដែលស្ថិតនៅជាប់ជើងភ្នំដងរែក ព្រំប្រទល់ដែនខ្មែរ និងថៃ។

នៅវេលាម៉ោង៨ និង៣០នាទី លោក សោម ច័ន្ទ ដែលជាប្រធានភូមិទំនប់លើ មានមតិសំណេះសំណាលជាមួយអ្នកចូលរួមទាំងអស់ និងប្រកាសបើកកម្មវិធីវេទិកាសហគមន៍។ បន្ទាប់មក វេទិកាបានផ្តោតការពិភាក្សាលើកបញ្ហាទាំងបីចំណុចខាងលើ ដែលពេលខ្លះអ្នកចូលរួមក៏បានរៀបរាប់អំពីដំណើរជីវិតរបស់ខ្លួនយ៉ាងវែងអន្លាយអំពីការចូលរួមជាមួយបដិវត្តន៍ខ្មែរក្រហម និងការងារនៅតាមសហករណ៍ជាដើម។

ជាក់ស្តែង យូ សារឹម ភេទប្រុស អាយុ ៦៣ ឆ្នាំ មានទីកន្លែងកំណើតនៅខេត្តកំពង់ចាម។ សារឹម ដែលធ្លាប់ជាយោធាខ្មែរក្រហមបាននិយាយថា គាត់បានចូលនៅក្នុងបដិវត្តន៍ខ្មែរក្រហម នៅឆ្នាំ១៩៧២។ គាត់ត្រូវបានខ្មែរក្រហមយកទៅលត់ដំមុនពេលចូលជាកងទ័ពអស់រយៈពេលជាច្រើនខែ។ ក្រោយមកខ្មែរក្រហមបានបញ្ជូនគាត់ទៅកាន់សមរភូមិមុខប្រយុទ្ធតទល់ជាមួយកងទ័ពលន់ នល់។ គាត់បានពិការជើងនៅក្នុងអំឡុងពេលមានសង្គ្រាម ព្រមទាំងរងរបួសពេញខ្លួនប្រាណដោយសារអំបែងគ្រាប់មីន។ សមាជិកគ្រួសាររបស់គាត់ចំនួន៥នាក់ រួមទាំងម្តាយគាត់ ត្រូវបានគេសម្លាប់នៅក្នុងរបបដ៏យោរយៅនោះ។ ទាក់ទងនឹងការលើកឡើងអំពីការបង្កើតឲ្យមានតុលាការស្វែងរកយុត្តិធម៌ គាត់បានឆ្លើយដោយមិនស្ទាក់ស្ទើរថា ការបង្កើតឲ្យមានតុលាការស្វែងរកយុត្តិធម៌គឺជារឿងមួយដែលត្រឹមត្រូវ។ ការកាត់ទោសមេដឹកនាំខ្មែរក្រហមពិតជាមានសារសំខាន់ នៅក្នុងការរស់នៅរបស់ប្រជាជនទាំងអស់គ្នា មិនថានរណាម្នាក់នោះទេ គឺសុទ្ធតែចង់បាននូវការរស់នៅដោយយុត្តិធម៌ សេរីភាព និងមានភាពស្មើគ្នាចំពោះមុខច្បាប់។ កន្លងមកយើងដឹងហើយថា ប្រជាជនខ្មែរប្រមាណជាពីរលាននាក់ បានក្លាយទៅជាជនរងគ្រោះ និងស្លាប់បាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍។ ជីវិតប្រជាជនហាក់ដូចជាគ្មានតម្លៃសម្រាប់



ប្រជាជនចំនួន ១៨នាក់ នៅភូមិទំនប់លើ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ចូលរួមវេទិកាសហគមន៍ដើម្បីលើកកម្ពស់ការយល់ដឹង និងពិភាក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលហៅកាត់ថា (អ.វ.ត.ក ឬសាលាក្តីខ្មែរក្រហម)។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

របបដឹកនាំនេះ។ គាត់បាននិយាយទៀតថា ជីវិតគាត់ត្រូវរស់ក្រោមការបង្គាប់បញ្ជារបស់ខ្មែរក្រហម ហើយកំហុសដែលមាន គឺត្រូវបានចាត់ទុកថាជាខ្មាំង ដែលត្រូវទទួលរងទារុណកម្ម ឬការសម្លាប់ចោល។ ភាពយុត្តិធម៌គឺមានសារសំខាន់ណាស់ចំពោះប្រជាជន។ រាជរដ្ឋាភិបាលបានបង្កើតឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមគឺជារឿងមួយដ៏ត្រឹមត្រូវ ហើយដែលអាចជួយសម្រាលដល់ផ្លូវចិត្តរបស់ជនរងគ្រោះ និងផ្តល់នូវភាពយុត្តិធម៌





សម្រាប់ជនរងគ្រោះ និងអ្នកដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបនោះៗ ប៉ុន្តែ សារីម នៅតែគិតថាវាហាក់ដូចជានៅមានភាពខ្វះចន្លោះមួយចំនួនដែលគាត់តែងតែគិត និងមិនអស់ចម្ងល់ៗ ចំពោះរឿងដែលកន្លងមកមិនមែនមានតែខ្មែរក្រហមមួយទេដែលចាប់ផ្តើមប្តុបង្កផលប៉ះពាល់ដល់អាយុជីវិតរបស់ប្រជាជនៗ នៅសម័យសាធារណរដ្ឋខ្មែរដែលគ្រប់គ្រង និងដឹកនាំដោយសេនាប្រមុខ លន់ នល់ ដែលមានការទម្លាក់គ្រាប់បែកបានប៉ះពាល់ និងសម្លាប់ប្រជាជនខ្មែរច្រើននាក់ដែរៗ ចុះហេតុអ្វីមិនធ្វើការកាត់ក្តីចំពោះរឿងនេះ? ដូច្នេះការបង្កើតឲ្យមានការចងក្រងប្រវត្តិសាស្ត្រនេះឡើង គឺពិតជាមានសារសំខាន់ណាស់ ជាពិសេសសម្រាប់កូនចៅជំនាន់ក្រោយៗ ប្រជាជនខ្មែរទាំងអស់ត្រូវតែដឹងអំពីប្រវត្តិសាស្ត្រនេះៗ

នៅក្នុងចំណោមប្រជាជនទាំង១៨នាក់ លោក សោម ច័ន្ទ គឺជាមនុស្សតែម្នាក់គត់ដែលបានចូលរួមនៅក្នុងសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមៗ សោម ច័ន្ទ បានថ្លែងថា ចំពោះការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះជារឿងមួយដែលត្រឹមត្រូវៗ ទោះបីជាការកាត់ក្តីនេះមិនបានបំពេញការខ្វះខាតមួយរយភាគរយក៏ដោយ សម្រាប់គាត់គឺមិនមានការជំទាស់ដំណើរការនេះទេៗ ប៉ុន្តែតុលាការធ្វើឡើងក្រោមបំណងស្វែងរកការពិតដែលនៅពីក្រោយនៃរបបប្រល័យពូជសាសន៍នេះ ជាពិសេសជួយសម្រាលដល់ផ្លូវចិត្ត និងស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះៗ មិនតែប៉ុណ្ណោះ គាត់មិនចង់វិលទៅរកអតីតកាលនៅក្នុងរបបនោះទៀតទេ ដោយសាររបបខ្មែរក្រហម គឺជារបបដឹកនាំមួយដែលគាត់ព្រមទាំងប្រជាជនខ្មែរទាំងអស់ពិបាកនឹងទទួលយកៗ ការគាបសង្កត់ ការបំបិទសិទ្ធិសេរីភាពគ្រប់បែបយ៉ាង នាំឲ្យមានការបែកបាក់គ្រួសារ និងលុបបំបាត់ភាពជាឯកជនៗ លើសពីនេះ សោម ច័ន្ទ បានសន្និដ្ឋានថា ដើម្បីឲ្យប្រទេស ឬសហគមន៍មិនវិលត្រឡប់ទៅរកអតីតកាលដ៏ឃោរឃៅ ពលរដ្ឋខ្មែរទាំងអស់ចាំបាច់ត្រូវរស់នៅដោយមានមេត្តាធម៌ក្នុងខ្លួន ចេះអត់ឱន ចេះអធ្យាស្រ័យៗ វេទិកានេះបានបញ្ចប់ទៅដោយក្តីសប្បាយរីករាយ និងស្និទ្ធស្នាលៗ

### «ផេះផង់ធូលី»

## រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# មាស សារិន ៖ លេខាធិការ

នៅពេលដែលខ្ញុំរៀននៅវិទ្យាល័យក្នុងរាជធានីភ្នំពេញ ខ្ញុំចូលចិត្តកីឡាដូចជាកីឡាបាល់បោះ។ ឪពុករបស់ខ្ញុំបានគាំទ្រនៃការស្រឡាញ់កីឡារបស់ខ្ញុំ ហើយនាពេលមួយខ្ញុំបានជាប់ចំណាត់ថ្នាក់ជាអ្នកលេងបាល់បោះស្រីឆ្នើមលំដាប់ថ្នាក់ទី២ នៅក្នុងប្រទេស។ បន្ទាប់ពីខ្ញុំបានបញ្ចប់ការសិក្សាខ្ញុំក៏បានក្លាយទៅជាលេខាធិការនៅក្រុម ហ៊ុន សេងថៃ ហើយបានបន្តការរស់នៅជាមួយគ្រួសាររបស់ខ្ញុំ។ ផ្ទះរបស់យើងគឺនៅទល់មុខកាស៊ីណូនៅទន្លេចតុមុខ។

នៅថ្ងៃទី១៧ ខែមេសា ម្ដាយនិងឪពុករបស់ខ្ញុំបានរៀបចំរបស់របររបស់យើងនៅពេលដែលយោធាខ្មែរក្រហមស្រែកសំឡុតមកកាន់ពួកយើង «ហេតុអ្វីបានជាអ្នកចំណាយពេលច្រើនជាមួយនឹងរបស់របររបស់យូរដូច្នេះ?» តើអ្នកចង់ឲ្យគ្រាប់បែកទម្លាក់មកចំអ្នកប្តីក៏យ៉ាងម៉េច?» ម្ដាយរបស់ខ្ញុំដែលមានជំងឺសរសៃឈាមបេះដូងស្ទើរតែគាំងបេះដូងដោយសារតែការស្រែកសំឡុតខ្លាំងៗ។

យើងបានធ្វើដំណើរឆ្ពោះទៅភាគខាងត្បូង។ ដោយសារតែវាគឺជារដូវប្រាំងបងប្អូនប្រុសស្រីរបស់ខ្ញុំបានស្រែកយំរកអាហារ និងទឹកនាំឲ្យពន្យារពេលដល់ការធ្វើដំណើររបស់យើង។ ឪពុកម្ដាយរបស់ខ្ញុំបានសួរទៅកាន់យោធាខ្មែរក្រហមថា «តើយើងនឹងទៅទីណា?» យោធាខ្មែរក្រហមបានឆ្លើយតប «គ្រាន់តែចាកចេញពីទីក្រុង» ។ យើងបាន



មាស សារិន ជាមួយគ្រួសាររបស់នាង និងម្ដាយមិត្តភក្តិរបស់នាង ថតនៅអង្គរវត្ត ឆ្នាំ១៩៦៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សម្រាកនៅក្នុងភូមិមួយអស់រយៈពេល ៤ ឬ៥ថ្ងៃដើម្បីរង់ចាំអង្គការកោះហៅពួកយើងឲ្យវិលត្រឡប់ទៅភ្នំពេញវិញ ហើយបន្ទាប់មកបែរជាទៅខេត្តព្រៃវែងទៅវិញ។ វាគឺជាការធ្វើដំណើរដែលហត់នឿយបំផុត ហើយឪពុកម្ដាយរបស់ខ្ញុំក៏បានបង្ខំចិត្តប្តូរវត្ថុមានតម្លៃរបស់គាត់ដើម្បីដោះដូរយកអាហារ។

បងស្រីរបស់ខ្ញុំឈ្មោះ ប៉ៅ គាយ បានរកឃើញមាសមួយកញ្ចប់តូចនៅក្បែរច្រាំងទន្លេ។ ពីរបីថ្ងៃក្រោយមកគាត់បាននិយាយថាលាហើយទៅកាន់ពួកយើង ហើយគាត់ក៏បានចាកចេញទៅជាមួយប្តីរបស់គាត់ ដែលពួកគាត់នឹងទៅស្រុកកំណើតរបស់គាត់។ ពេលនោះគឺជាពេលចុងក្រោយដែលយើងបានឃើញពួកគាត់។

នៅខេត្តព្រៃវែង យើងគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រជាជនមូលដ្ឋាន។ ប្រជាជនចាស់មួយចំនួនបាននិយាយថា ស្ថានភាពគឺដូចពុទ្ធទំនាយថា «មានផ្ទះគ្មានមនុស្សរស់នៅ មានផ្លូវគ្មានមនុស្សដើរ »។

អង្គការតែងតែធ្វើការអប់រំយើង។ នៅពេលដែលប្អូនប្រុសរបស់ខ្ញុំឈ្មោះ ស៊ីសុផុន ឈឺគ្រុនក្ដៅ ខ្លាំង គាត់បាន

សុំអនុញ្ញាតសម្រាកនៅផ្ទះ។

គាត់ត្រូវបានខ្មែរក្រហមបដិសេធ ប៉ុន្តែនៅទីបំផុតក៏មានកម្មាភិបាលម្នាក់បានយកគាត់ទៅមន្ទីរពេទ្យដោយជិះរទេះគោ។ ឪពុកម្តាយរបស់ខ្ញុំចង់ទៅមើលថែគាត់នៅទីនោះ ប៉ុន្តែអង្គការបានប្រាប់រួចហើយថា «អង្គការគឺជាឪពុកម្តាយ។ ប្រសិនបើមានកូនៗណាឈឺ អង្គការអាចមើលថែពួកគេបាន ដូច្នេះមិនចាំបាច់ឪពុកម្តាយរបស់ពួកគេទៅសួរសុខទុក្ខនោះទេ»។ ឪពុកម្តាយរបស់ខ្ញុំស្ងាត់ស្ងៀម ហើយបានសុំការលើកលែងទោសពីអង្គការ។

ប្អូនបង្កើតរបស់ខ្ញុំពីរនាក់ ឈ្មោះ ស៊ីថា និង បាន់ណាកា ពួកគេទាំងពីរនាក់នេះគឺខ្ជិលច្រអូសខ្លាំងណាស់ ហើយក៏មិនដែលបានបំពេញកិច្ចការដែលអង្គការចាត់តាំងបានដែរ។ ប្រធានអង្គភាពរបស់ពួកគេបានអប់រំឪពុកម្តាយខ្ញុំជាញឹកញាប់ចំពោះបញ្ហានេះ។ អង្គការបានស្តីបន្ទោសខ្ញុំផងដែរ៖ ក្នុងនាមជាបងស្រីគួរតែមានទំនួលខុសត្រូវគ្រប់គ្រាន់ក្នុងការអប់រំប្អូនៗរបស់ខ្ញុំ។

ដោយសារតែយើងខ្វះស្បៀងអាហារ ទើបសុខភាពរបស់យើងកាន់តែយ៉ាប់យឺនទៅៗ។ យើងពិបាកក្នុងការចំណាំគ្នាខ្លាំងណាស់ ដោយសារយើងមានសភាពស្គមស្គាំងពេក។ យើងក៏ត្រូវបានគ្របដណ្តប់ដោយភាពកខ្វក់និងភក់ផងដែរ ដោយសារតែយើងមិនមានសាប៊ូ។ ប្រជាជនមូលដ្ឋានបានបង្រៀនយើងដោយយកស្លឹកជីអង្គាមហាលក្រោមកម្តៅថ្ងៃឲ្យស្ងួតហើយលាយជាមួយនឹងដីឥដ្ឋ។ ជាលទ្ធផលវានឹងក្លាយទៅទឹកដែលយើងអាចប្រើប្រាស់ដូចជាសាប៊ូបាន។

នៅឆ្នាំ១៩៧៦ អង្គការបានផ្លាស់យើងឲ្យទៅរស់នៅក្នុងស្រុកមួយទៀត។ ឪពុករបស់ខ្ញុំបានធ្លាក់ខ្លួនឈឺធ្ងន់ ដូច្នេះម្តាយខ្ញុំបានសួរថា តើយើងអាចពន្យារពេលការធ្វើដំណើររបស់យើងរហូតដល់គាត់បានជាសះស្បើយបានទេ។ ការស្នើសុំរបស់គាត់ត្រូវបានបដិសេធហើយឪពុករបស់ខ្ញុំក៏បានស្លាប់បាត់បង់ជីវិត។ យើងមិនមានសម្ភារណាមួយសម្រាប់គ្របខ្លួនរបស់គាត់នោះទេគឺមានតែកន្ទេង។

អង្គការ ជាធម្មតាមានការប្រជុំបីដងក្នុងមួយខែ។ ខ្មែរក្រហមបានដាក់សញ្ញាសម្គាល់នៅលើជញ្ជាំងផ្ទះប្រជុំដោយនិយាយថា «ជយោ! ជ័យជម្នះ! កម្ពុជារំដោះដ៏រុងរឿង។ ជយោ! ជ័យជម្នះ! ត្រូវអប់រំខ្លួនឯងដើម្បីក្លាយទៅជាអ្នករំដោះដ៏បរិសុទ្ធ។ ជយោ! ជ័យជម្នះ! ប្តេជ្ញាខិតខំធ្វើការដើម្បីបង្កបង្កើនផលឲ្យកាន់តែច្រើនឡើង សម្រាប់ការបោះជំហានទៅមុខដ៏ធំធេង និងដើម្បីកម្ចាត់សត្រូវទាំងអស់ ដើម្បីបង្កើតរបបគ្មានអ្នកមានគ្មានអ្នកក្រ»។ បន្ទាប់ពីមានការប្រជុំនីមួយៗប្រធានអង្គភាពបានបែងចែកប្រជាជន សម្រាប់ការប្រជុំក្រុមតូចៗ ដោយតម្រូវឲ្យយើងធ្វើស្វ័យទិតៀនខ្លួនឯងទៅវិញទៅមក ហើយអង្គការបានប្រាប់ថាត្រូវខំប្រឹងធ្វើការបង្កបង្កើនផលថែមទៀត។

ប្អូនប្រុសរបស់ខ្ញុំ ស៊ីសូផុន បានធ្លាក់ខ្លួនឈឺធ្ងន់នៅខេត្តព្រៃវែង។ បេះដូងរបស់គាត់ឈឺចាប់ប្រហែលមកពីលើករបស់របរធ្ងន់ៗ។

បន្ទាប់ពីគាត់បានស្លាប់ទៅ ខ្ញុំបានឃើញសម្លៀកបំពាក់របស់គាត់នៅក្នុងកាបូប ហើយបានឃើញកាតសម្គាល់ខ្លួននិស្សិត និងសៀវភៅរបស់គាត់។ គាត់បានរក្សាទុកវាព្រោះគាត់សង្ឃឹមថា ថ្ងៃណាមួយគាត់នឹងបានវិលត្រឡប់មកសាលារៀនវិញ។

នៅចុងឆ្នាំ១៩៧៨ ខ្ញុំបានឮស្នូរកាំភ្លើង និងគ្រាប់បែកពីទិសខាងកើត។ ប្រជាជនបានលួចស្តាប់តាមវិទ្យុហើយខ្សឹបប្រាប់ថា រណសិរ្សសង្គ្រោះជាតិនឹងមកដល់ឆាប់ៗនេះ។ នៅពេលនោះកម្មាភិបាលខ្មែរក្រហមបានបង្កើនសន្តិសុខទ្វេដង ហើយការកាប់សម្លាប់បានកើនឡើងយ៉ាងឆាប់រហ័ស។ ខ្ញុំបានប្រាប់ប្អូនៗខ្ញុំឲ្យគោរពតាមវិន័យរបស់អង្គការយ៉ាងម៉ឺងម៉ាត់ដើម្បីឲ្យពួកគេមានជីវិតរស់។

នៅពេលដែលគ្រាប់បែក និងកាំភ្លើងផ្ទុះឡើងកាន់តែជិតមកដល់ កម្មាភិបាលខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនឆ្លងកាត់ទន្លេ។ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៨ ខ្ញុំបានឮវិទ្យុប្រកាសថានៅខេត្តក្រចេះ ត្រូវបានរំដោះរួចហើយ។ ប្រជាជនបានស្រែកហ៊ោជាមួយនឹងក្តីរំភើបរីករាយនៅពេលដែលបានឮព័ត៌មាននេះ ហើយបន្ទាប់មកក៏ចាប់ផ្តើមដណ្តើមស្រូវអង្ករគ្នានៅក្នុងរោងម៉ាស៊ីន។ ខ្ញុំមានគោពីរក្បាលនិងរទេះគោមួយសម្រាប់ម្តាយខ្ញុំជិះ។ សមាជិកគ្រួសារដែលនៅសេសសល់ចាប់ផ្តើមដើរត្រឡប់ទៅផ្ទះវិញ។ នៅពេលដែលខ្ញុំបានមកដល់ទីក្រុងក្រចេះ រណសិរ្សសង្គ្រោះជាតិកម្ពុជាមិនអនុញ្ញាតឲ្យយើងចូលទៅទេ។ ជើងរបស់ម្តាយខ្ញុំកាន់តែហើមទៅៗ ហើយគាត់បានព្យាយាមរកគ្រូ អាបធ្មប់ដើម្បីព្យាបាលគាត់ ដូច្នេះយើងក៏អាចវិលត្រឡប់មកភ្នំពេញវិញ។ ខណៈពេលដែលគាត់កំពុងតែព្យាបាល ខ្ញុំបានរកការងារមួយគឺជាលេខាធិការនៅក្នុងការិយាល័យព័ត៌មានហើយក្រោយមកខ្ញុំក៏បានរៀបការ។ យើងបានរស់នៅក្នុងខេត្តក្រចេះជារៀងរហូត។

**ប៊ាង ពីច័ន្ទ និង ខេនី ខកហ្មៀល**

*រូបក្របមុខ៖*

*ស៊ុំ  សុភាព បានផ្តល់បទសម្ភាសន៍ដល់ក្រុមការងារគម្រោងប្រវត្តិសាស្រ្តគ្រួសារ នៅផ្ទះរបស់គាត់។*

*(ដារ៉ាវិរដ្ឋ មេត្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

*រូបក្របក្រោយ ៖*

*ថុន ចាន់ថន បានទទួលសៀវភៅទស្សនាវដ្តីស្វែងរកការពិត ក្រុមការងារគម្រោងប្រវត្តិសាស្រ្តគ្រួសារ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។*

*(អ៊ុន សុដាវី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា  ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 254, February 2021 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.